សៀវភៅ ជំនួយស្មារតី

# ការកសាងភាពជាដៃគូ



## មគ្គុទ្ទេសក៏ដ៏សំខាន់សំរាប់កសាងភាពជាដៃគូអន្តរវិស័យ

# សៀវភៅជំនួយស្មារតី **ការកសាងភាពជាដៃគូ**

រៀបរៀងដោយ : រ៉ូស ថេនីសុន នាយិកា
កម្មវិធីផ្តួចផ្តើមភាពជាដៃគូ
នៃវេទិកាអ្នកដឹកនាំធុរកិច្ចអន្តរជាតិ (IBLF)

សំរួលខ្លឹមសារៈ បាបារា ថូគ្លី

សំរួលបច្ចេកទេស : អាណា ហ៊ីល

រចនាក្រប : អាលីសុន បៀនឡៃន

រូបភាព : គុយ វេនណាប៊ិល

រចនា : ក្រុមហ៊ុន ប្លូស ឪ ប្លូស

បោះពុម្ពដោយ : ក្រុមហ៊ុនក្រាភិចរូត ខូ អិល ធី ឌី

ចុះបញ្ជីជាអន្តរជាតិ ISBN: 978-1-899159-16-1

រក្សាសិទ្ធិឆ្នាំ ២០០៣-២០០៧, ២០០៩ ដោយស្ថាប័នផ្តួចផ្តើមភាពជាដៃគូ

បោះពុម្ពលើកទី ១ ឆ្នាំ ២០០៣
បោះពុម្ពលើកនេះ ឆ្នាំ ២០០៩

# អារម្ភកថា

ការកសាងភាពជាដៃគូ ជាការងាយស្រួលក្នុងការនិយាយ ប៉ុន្តែជារឿងលំបាកនៅពេលអនុវត្តន៏ ។ វាទាមទារឱ្យមានសេចក្តីក្លាហាន អត់ធ្មត់ និង ពុះពារគ្រប់ពេលវេលា ។ វាកម្រជាដំណោះស្រាយទាន់ពេលវេលាសំរាប់បញ្ហាមួយ ហើយជួនកាលអាចក្លាយទៅជារឿងខកចិត្តមានន័យថា សេចក្តីសង្ឃឹម និង ការរំពឹងទុកនៅពេលចាប់ផ្តើម មិនបានបំពេញគ្រប់គ្រាន់ ។

ក៏ប៉ុន្តែ វាក៏មិនមែនសុទ្ធតែអញ្ចឹងទាំងអស់នោះទេ ។

មានភស្តុតាងគួរឱ្យទុកចិត្តបានជាច្រើនពីកម្មវិធីភាពជាដៃគូ ដែលកំពុងបង្កើតឡើងក្នុងតំបន់ផ្សេងៗជុំវិញពិភពលោកបានបង្ហាញច្បាស់ថា កិច្ចសហប្រតិបត្តិការអន្តរវិស័យបែបនេះអាចមានប្រសិទ្ធភាពខ្ពស់ និង មាននិរន្តរភាពពេល ដែលវាត្រូវបានគេរៀបចំផែនការអភិវឌ្ឍ និងគ្រប់គ្រងក្នុងលក្ខណៈជាប្រព័ន្ធ ។

សៀវភៅជំនួយស្មារតីនេះ បានរៀបរៀងចេញពីបទពិសោធន៏របស់ក្រុមដែលឈានមុខគេក្នុងការកសាងភាពជាដៃគូតាមវិធីសាស្ត្រថ្មីៗ និង ផ្តល់នូវទិដ្ឋភាពរួមនៃធាតុសំខាន់ៗ ដែលជួយធ្វើឱ្យការកសាងភាពដៃគូមានប្រសិទ្ធភាព ។

យើងសង្ឃឹមថា អ្នកដែលប្រើប្រាស់សៀវភៅនេះនឹងទទួលបានទំនុកចិត្ត និង ការលើកទឹកចិត្ត ។ លើសពីនេះទៅទៀត យើងសង្ឃឹមថា សៀវភៅនឹងជួយពួកគេឱ្យកសាងបាននូវភាពជាដៃគូប្រកបដោយភាពរឹងមាំ និង ជោគជ័យ ហើយគោលដៅអភិវឌ្ឍន៏ដែលសំរេចបាន មិនត្រឹមតែមាននិរន្តរភាពប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងជួយរួមចំណែកក្នុងការបញ្ចប់ភាពក្រីក្រក្នុងពិភពលោកយើងនេះផងដែរ ។

# មាតិកា


## ១
បញ្ហាប្រឈមក្នុងភាពជាដៃគូ
បុព្វហេតុសំរាប់ការកសាងភាពជាដៃគូ
ឧបសគ្គចំពោះការកសាងភាពជាដៃគូ
គុណតំលៃជាគន្លឹះក្នុងការកសាងភាពជាដៃគូ
បញ្ហាប្រឈមក្នុងភាពជាអ្នកដឹកនាំ

## ២
ការកសាងភាពជាដៃគូ
ការស្វែងរកដៃគូ
ប៉ាន់ប្រមាណហានិភ័យ និង រង្វាន់
ផែនទីធនធាន

## ៣
កិច្ចព្រមព្រៀងកសាងភាពជាដៃគូ
បង្កើតការប្ដេជ្ញាចិត្តរបស់ដៃគូ
ការចរចាផ្ដែកលើផលប្រយោជន៍
អភិបាលកិច្ច និង គណនេយ្យភាព

## ៤
គ្រប់គ្រងដំណើរការកសាងភាពជាដៃគូ
តួនាទីក្នុងភាពជាដៃគូ
ដៃគូជាអ្នកដឹកនាំ
ជំនាញសំរាប់កសាងភាពជាដៃគូ
ប្រតិបត្តិល្អក្នុងការកសាងភាពជាដៃគូ

## ៥
ការអនុវត្តគំរោងប្រកបដោយជោគជ័យ
គ្រប់គ្រងអន្តរកាល
ផ្ដោតលើការងារ
ការរាយការណ៍ ការពិនិត្យមើលឡើងវិញ និង ការកែតំរូវ

## ៦
និរន្តរភាពក្នុងការកសាងភាពជាដៃគូ
រៀបចំផែនការសំរាប់រយៈពេលយូរ
ធានាការចូលរួមកាន់តែប្រសើរ
កសាងសមត្ថភាពស្ថាប័ន

## ៧
ការកសាងភាពជាដៃគូដ៏ជោគជ័យ
កំណត់ពីភាពជោគជ័យ
ចែករំលែកបទពិសោធន៍ល្អៗ
កិច្ចសហប្រតិបត្តិការក្នុងពិភពប្រកួតប្រជែង

# ១ បញ្ហាប្រឈមក្នុងការកសាងភាពជាដៃគូ

## បុព្វហេតុសំរាប់ការកសាងភាពជាដៃគូ

មហាសន្និបាតអង្គការសហប្រជាជាតិឆ្នាំ ១៩៩២ ស្តីអំពីបរិដ្ឋាន និង ការអភិវឌ្ឍ (កិច្ចប្រជុំកំពូលអំពីភពផែនដីនៅឯទីក្រុងរីយ៉ូ) បានសន្និដ្ឋានថា ភាពជាដៃគូរវាងរដ្ឋាភិបាល ផ្នែកឯកជន និង សង្គមស៊ីវិល ជាមូលដ្ឋានចំបងដើម្បីឈានទៅសំរេចគោលដៅអភិវឌ្ឍពិភពលោកប្រកបដោយនិរន្តរភាព ។

បញ្ហានេះ ត្រូវបានលើកឡើងជាបន្តបន្ទាប់ក្នុងកិច្ចប្រជុំកំពូលស្តីពីកំណើនប្រជាជន ការអភិវឌ្ឍទីក្រុង យេនឌ័រ ការអភិវឌ្ឍសង្គម និង ក្នុងពេលថ្មីៗកន្លងទៅនេះ នៅក្នុងកិច្ចប្រជុំកំពូលស្តីពីការតាមដានការអនុវត្តការសំរេចចិត្តនានារបស់កិច្ចប្រជុំកំពូលទីក្រុងរីយ៉ូ ដែលប្រារព្ធធ្វើឡើងនៅទីក្រុងយ៉ូហានីស្បឺកនៅឆ្នាំ ២០០២ ។

ប៉ុន្តែ ហេតុអ្វីបានជាតំរូវឱ្យមានភាពជាដៃគូ ?

សម្មតិកម្មដែលបង្កប់ក្នុងអភិក្រមភាពជាដៃគូ បញ្ជាក់ថា មានតែការកិច្ចសហប្រតិបត្តិការអន្តរវិស័យប្រកបដោយភាពទូលំទូលាយ និង គ្រប់ជ្រុងជ្រោយប៉ុណ្ណោះ ដែលយើងអាចធានាបានថា ផែនការអភិវឌ្ឍប្រកបដោយនិរន្តរភាពមានលក្ខណៈរួមបញ្ចូលគ្នា និង ប្រទាក់ក្រឡាបានរឹងមាំ ដើម្បីដោះស្រាយបញ្ហាដ៏ស្មុគ្រស្មាញ ។

អភិក្រមនៃវិស័យតែមួយ ត្រូវបានធ្វើការសាកល្បងរួចហើយ ដោយទទួលលទ្ធផលគួរឱ្យខកចិត្ត ។ការធ្វើការដាច់ដោយឡែកពីគ្នា ដូចជាវិស័យ ឬភ្នាក់ងារអភិវឌ្ឍន៍នីមួយៗ បង្កើតផែនការអនុវត្តសកម្មភាពដោយឡែកពីគ្នា ជួនកាលបង្កឱ្យមានការប្រកួតប្រជែងគ្នា អនុវត្តកម្មវិធីត្រួតគ្នា និង ខ្ជះខ្ជាយធនធាន ។ ការធ្វើការដោយមិនមានការសហការគ្នាជាញឹកញាប់ នាំទៅរក "វប្បធម៌ស្តីបន្ទោស" ដែលក្នុងនោះ ការធ្វេសប្រហែស ឬភាពរើករវល់ណាមួយបានកើតឡើង ជានិច្ចកាល ត្រូវបានគេចាត់ទុកថាជាកំហុសអ្នកដទៃទៅវិញ ។

ដូច្នេះ ភាពជាដៃគូបានផ្តល់ឱ្យនូវឱកាសថ្មីសំរាប់ការអភិវឌ្ឍមួយ ដែលមានភាពប្រសើរជាងនេះ ដោយទទួលស្គាល់នូវគុណភាព និង សមត្ថភាពរបស់វិស័យនីមួយៗ ហើយស្វែងរកមធ្យោបាយដើម្បីធានាឱ្យដៃគូទាំងអស់ទទួលបានជោគជ័យដូចគ្នា ។

តើអ្វីខ្លះដែលវិស័យនីមួយៗ (រដ្ឋាភិបាល : ផ្នែកឯកជន និង សង្គមស៊ីវិល) ត្រូវនាំយកមក ? ធុរកិច្ចស្នូលរបស់វិស័យនីមួយៗបង្កើតឱ្យមានភាពខុសគ្នាលើអាទិភាព គុណតំលៃ និង លក្ខណៈសម្បត្តិ ។ ទាំងអស់នេះអាចសង្ខេបបានក្នុងតារាងខាងក្រោម :

| វិស័យ | ធុរកិច្ចស្នូល | លក្ខណៈសម្បត្តិ |
|---|---|---|
| **រដ្ឋាភិបាល** | *អនុវត្តច្បាប់ដោយ :*<br>• បង្កើតក្របខ័ណ្ឌសំរាប់សិទ្ធិ សេដ្ឋកិច្ច នយោបាយ និង សង្គម និង ការតាំងចិត្តចំពោះលើនយោបាយអភិវឌ្ឍន៍<br>• បង្កើតបទបញ្ជា និង បទដ្ឋាននានា ដូចជា រៀបចំយន្តការ និង ការអនុលោមតាមកាតព្វកិច្ចអន្តរជាតិ<br>• ផ្តល់សេវាសាធារណៈដើម្បីធានាថា សេចក្តីត្រូវការ និង សិទ្ធិជាមូលដ្ឋាន ត្រូវបានទទួល និង គោរព ។ | "សិទ្ធិ" ជាមូលដ្ឋានរដ្ឋាភិបាលផ្តល់លទ្ធភាព ព័ត៌មាន ស្ថេរភាព និងភាពស្របច្បាប់ |
| **ផ្នែក ឯកជន** | *ធ្វើវិនិយោគ និង ពាណិជ្ជកម្មដោយ :*<br>• ការផលិតទំនិញ និង សេវាកម្ម<br>• ការផ្តល់ឱកាសការងារ នវានុវត្តន៍ និង កំណើនសេដ្ឋកិច្ច<br>• ការបង្កើនផលចំណេញជាអតិបរមាសំរាប់វិនិយោគិន ដើម្បីធានាឱ្យមានការបង្កើនវិនិយោគ ដែលនឹងសំរួលឱ្យធុរកិច្ចបន្តបញ្ចូលនូវវិធីសាស្ត្រថ្មីៗបន្ថែមទៀត ។ | "ផលចំណេញ" ជាមូលដ្ឋានវិស័យឯកជន ត្រូវមានផលិតភាពខ្ពស់ ការបង្កើតថ្មីជានិច្ច ឆាប់រហ័ស និង ការយកចិត្តទុកដាក់ខ្ពស់ |
| **សង្គម ស៊ីវិល** | *អភិវឌ្ឍសង្គមដោយ :*<br>• បង្កើតឱកាសសំរាប់ការច្នៃប្រឌិត និង ការរីកចំរើនរបស់មនុស្ស<br>• ផ្តល់ការគាំទ្រ និង សេវាដល់អ្នកខ្សត់ខ្សោយ ឬ អ្នកដែលមិនបានទទួលការយកចិត្តទុកដាក់ពីសង្គម<br>• ធ្វើសកម្មភាពការពារប្រយោជន៍សង្គម | "គុណតំលៃ" ជាមូលដ្ឋានផ្នែកសង្គមស៊ីវិលបញ្ចេញមតិឆ្លើយតបនឹងតំរូវការ គៀងគរការចូលរួម និង មានប្រឌិតញាណ |

# ប្រអប់ ១

## ១២ ដំណាក់កាលក្នុងដំណើរការកសាងភាពជាដៃគូ




**ចំណាំ**

នេះគ្រាន់តែជាដំណើរការគំរូប៉ុណ្ណោះ ។ ភាពជាដៃគូនីមួយៗអាចអនុវត្តតាមដំណើរការជាក់លាក់មួយរបស់ខ្លួន ។ ប្រការសំខាន់គួរដឹងថា ដំណាក់កាលនីមួយៗដែលបានបង្ហាញខាងលើមានសារៈសំខាន់ និង មិនគួរមើលរំលងប្រសិនបើភាពជាដៃគូនៅរក្សាបានតុល្យភាព និង ឋិតលើមាគ៌ាឆ្ពោះទៅសំរេចគោលដៅរបស់ខ្លួន ។

លើសពីនេះទៀត វិស័យនីមួយៗមានសមត្ថភាព បំណងប្រាថ្នា និង របៀបប្រតិបត្តិការខុសៗគ្នា ។ ប៉ុន្តែតាមរយៈការកសាងភាពជាដៃគូប្រកបដោយជោគជ័យ គេអាចច្របាច់បញ្ចូលគ្នានូវភាពខុសគ្នាទាំងអស់នោះ ដើម្បីឈានទៅសំរេចនូវទស្សនវិស័យរួមមួយ ។

តាមរយៈការធ្វើការរួមគ្នា ភាពជាដៃគូសំរាប់ការអភិវឌ្ឍមាននិរន្តរភាព អាចផ្តល់នូវ :

- អភិក្រមបែបថ្មី ចំពោះបញ្ហាប្រឈមនានានៃការអភិវឌ្ឍប្រកបដោយនិរន្តរភាព និង សេចក្តីសង្ឃឹមក្នុងការបញ្ចប់ភាពក្រីក្រនៅលើពិភពលោក ។
- យន្តការមួយចំនួនដែលជួយឱ្យវិស័យនីមួយៗ អាចចែករំលែកនូវសមត្ថភាព និង លទ្ធភាព ដើម្បីធ្វើឱ្យសំរេចគោលដៅរួម និង គោលដៅដែលបំពេញឱ្យគ្នាទៅវិញទៅមក បានកាន់តែមានប្រសិទ្ធភាព មានភាពស្របច្បាប់ និង មាននិរន្តរភាពជាងពេលដែលវិស័យនីមួយៗធ្វើការដាច់ដោយឡែកពីគ្នា ។
- លទ្ធភាពទទួលបានធនធានច្រើនជាងមុនដោយទាក់ទាញបាននូវធនធានបច្ចេកទេស មនុស្ស ចំណេះដឹង ធនធានជារូបវន្ត និង ហិរញ្ញវត្ថុ ដែលអាចរកបាននៅក្នុងគ្រប់វិស័យ ។
- បណ្តាញការងារថ្មីហើយសកម្ម ផ្តល់ឱ្យវិស័យនីមួយៗនូវផ្លូវសំរាប់ការចូលពាក់ព័ន្ធជាមួយសហគមន៍បានទូលាយជាងមុន និង សមត្ថភាពខ្ពស់ជាងមុន ដើម្បីមានឥទ្ធិពលលើរបៀបវារៈគោលនយោបាយផ្សេងៗ ។
- ការយល់ដឹងកាន់តែច្រើនអំពីតំលៃ គុណតំលៃ និង លក្ខណៈសម្បត្តិរបស់វិស័យនីមួយៗ ដែលតាមរយៈនោះនឹងកសាងបានសង្គមជាតិមួយមានលក្ខណៈរួបរួមគ្នា និង មានស្ថេរភាពប្រសើរជាងមុន ។

ខណៈដែលភាពជាដៃគូអាចកើតមានក្នុងគ្រប់លំដាប់ (ចាប់ពីថ្នាក់ជាតិ ឬ សម្ព័ន្ធភាពជាយុទ្ធសាស្ត្រអន្តរជាតិ នៅលំដាប់គោលនយោបាយ ស្ថិតលើចុងប៉ូលម្ខាងនៃដំណាក់កាលកសាងភាពជាដៃគូរហូតទៅដល់កំរិតថ្នាក់មូលដ្ឋានដែលនៅចុងប៉ូលម្ខាងទៀត) នេះជាបទពិសោធន៍ទូទៅនៃការកសាង និង រក្សាដំណើរការកសាងភាពជាដៃគូ និង អនុវត្តបានសំរាប់ការកសាងភាពជាដៃគូគ្រប់ប្រភេទ (សូមមើលប្រអប់ ១ ក្នុងទំព័រ ៦) ។

## ឧបសគ្គចំពោះការកសាងភាពជាដៃគូ

ទោះបីជាមានហេតុផលល្អៗជាច្រើនសំរាប់ការបង្កើតភាពជាដៃគូដើម្បីដោះស្រាយបញ្ហាអភិវឌ្ឍចំបងៗក៏ដោយ ក៏នៅមិនទាន់មានវិធីណាដែលល្អបំផុតសំរាប់ឱ្យយើងជ្រើសរើសយកទៅអនុវត្តបន្តនោះទេ ។ ជានិច្ចកាលមិនសុទ្ធតែជាការងាយស្រួលទេក្នុងការបង្កើតឱ្យមានកិច្ចសហប្រតិបត្តិការគ្នា ជាពិសេសនៅក្នុងបរិបទមួយ ដែលមាន វប្បធម៌ នយោបាយ ឬ សេដ្ឋកិច្ច ដែលមិនជួយគាំទ្រ ។

ឧបសគ្គចំពោះការកសាងភាពជាដៃគូ អាចលេចចេញមកច្រើនបែបយ៉ាងដូចជា :

| ប្រភពនៃឧបសគ្គ | ឧទាហរណ៍ |
|---|---|
| **សាធារណៈទូទៅ** | • ឥរិយាបថសង្ស័យនិយម<br>• ឥរិយាបថរឹងត្អឹង ឬ បុរេវិនិច្ឆ័យចំពោះដៃគូ<br>• បំប៉ោងការរំពឹងទុកនូវអ្វីដែលអាចទៅរួច |
| **ចរិតលក្ខណៈបែបអវិជ្ជមានតាមវិស័យ**<br>**(ជាក់ស្តែង ឬ ការយល់ឃើញ)** | • រដ្ឋាភិបាល : ការិយាធិបតេយ្យ និង មិនបត់បែន<br>• ផ្នែកឯកជន : គិតជាឯកតោភាគី និង មានការប្រកួតប្រជែង<br>• ផ្នែកសង្គមស៊ីវិល : តស៊ូប្រឈមមុខ និង ប្រកាន់យកតែគុណតំលៃរបស់ខ្លួន |
| **ភាពខ្វះខាតផ្ទាល់ខ្លួន**<br>**(របស់ដៃគូដែលដឹកនាំភាពជាដៃគូ)** | • មិនមានជំនាញគ្រប់គ្រាន់សំរាប់ការកសាងភាពជាដៃគូ<br>• អំណាចទាំងខាងក្នុង និង ខាងក្រៅនៅមានកំរិត<br>• ផ្តោតលើការងារ និង តួនាទីបែបចង្អៀតពេក<br>• ខ្វះជំនឿលើប្រសិទ្ធភាពនៃការកសាងភាពជាដៃគូ |

| | |
|---|---|
| **ការចាត់ចែងនៅមានកំរិត (របស់អង្គភាពជាដៃគូ)** | • មានវិវាទលើអាទិភាព<br>• មានការប្រកួតប្រជែង (ខាងក្នុងវិស័យ)<br>• ខ្វះការអត់ធ្មត់ (របស់វិស័យដទៃទៀត) |
| **ការរាំងស្ទះពីមជ្ឈដ្ឋានខាងក្រៅ** | • បរិយាកាសនយោបាយ សេដ្ឋកិច្ច និង សង្គមនៅមូលដ្ឋាន<br>• កំរិតនៃបញ្ហាប្រឈម និង ល្បឿននៃការផ្លាស់ប្តូរ<br>• អសមត្ថភាពក្នុងការរកធនធានពីខាងក្រៅ |

នៅពេលដែលមានឧបសគ្គរាំងស្ទះច្រើនពេកចំពោះភាពជាដៃគូ ជាការល្អបំផុតត្រូវបោះបង់ចោលគំនិតនោះសិន ហើយរងចាំឱកាសដែលប្រសើរជាងនេះ ។ ប៉ុន្តែឧបសគ្គភាគច្រើនអាចជំនះបាន ប្រសិនបើមានការអត់ធ្មត់ ការតាំងចិត្ត និង កិច្ចខិតខំប្រឹងប្រែងគ្រប់គ្រាន់ ។ ទោះបីជាបញ្ហាប្រឈមចំពោះភាពជាដៃគូទាំងនោះឈានដល់ចំណុចចែកផ្លូវគ្នាក៏ដោយ ក៏គេអាចប្រែក្លាយវាឱ្យទៅជាអ្វីមួយដែលមានភាពប្រសើរ និង រឹងមាំជាងនេះ ។ ជម្លោះខ្លះ (ភាពជាដៃគូភាគច្រើនបានជួបប្រទះ) គឺជាការចែកផ្លូវគ្នា ឬវិបត្តិនោះអាចបង្កើតឱ្យមានការឆ្លើយតបថ្មី និង មិនបានរំពឹងទុកកើតឡើង ពីព្រោះវាបង្ខំឱ្យដៃគូដែលចូលរួមមានការយកចិត្តទុកដាក់ជាថ្មី ហើយសំលឹងមើលរឿងរ៉ាវនោះ ប្រកបដោយប្រាជ្ញាញាណច្រើនជាងមុន ។

ជាការពិត ផ្តើមចេញពីទស្សនៈនេះ ឧបសគ្គមួយអាចផ្តល់ឱ្យភាពជាដៃគូនូវចំណុចរបត់មួយដ៏មានតំលៃមិនអាចកាត់ថ្លៃបាន ។

## គុណតំលៃគន្លឹះសំរាប់ការកសាងភាពជាដៃគូ

ដូចគ្នាជាមួយនឹងគោលដៅដែលមានការព្រមព្រៀងគ្នាដែរ ភាពជាដៃគូទាំងអស់នឹងត្រូវការគុណតំលៃ ដើម្បីជួយពួកគេឱ្យរួបរួម និង ធ្វើការជាមួយគ្នា ។ គុណតំលៃ គួរតែបង្កើតឱ្យមានឡើងក្នុងតំណាក់កាលនៃការបង្កើតភាពជាដៃគូ និង មានការព្រមព្រៀងគ្នាពីគ្រប់ដៃគូទាំងអស់ ។ ប្រសិនបើគុណតំលៃទាំងនោះ ផ្តល់ជាមូលដ្ឋានគ្រឹះដើម្បីកសាងភាពជាដៃគូ អញ្ចឹងក្នុងពេលដែលអ្វីៗកំពុងដំណើការទៅ វានឹងបន្តផ្តល់ការផ្សារភ្ជាប់គ្នា (ដូចជាស៊ីម៉ង់) ជាបន្តបន្ទាប់ ដើម្បីឱ្យភាពជាដៃគូនៅឋិតថេរតទៅមុខទៀត ។

វិស័យនីមួយៗមានអាទិភាពរៀងខ្លួនៗ ហើយគេអាចមានការលំបាកក្នុងការទទួលយកអាទិភាពថ្មីពីដៃគូផ្សេងៗ ប៉ុន្តែការពិភាក្សាពន្យល់យ៉ាងតឹងតែងអំពីមូលហេតុ ដែលគុណតំលៃមិនស្របគ្នានឹងគុណតំលៃរបស់ដៃគូមួយ ឬ ដៃគូផ្សេងទៀត អាចនឹងបន្តជាហូរហែរហូតដល់មានដំណោះស្រាយសំរាប់ភាពខុសគ្នាទាំងនោះ និង ឈានទៅសំរេចបានការសំរុះសំរួលមួយ ។

គុណតំលៃ ៣ ចំបងៗ បានលេចឡើងជារឿយៗនៅក្នុងភាពជាដៃគូអន្តរវិស័យនៅកន្លែងផ្សេងៗជុំវិញពិភពលោកនោះ គឺគុណតំលៃសមធមិ តម្លាភាព និង ផលប្រយោជន៍ទ្វេទិស ។ គុណតំលៃទាំងនោះ មានលក្ខណៈដូចខាងក្រោម :




**សមធមិ ?**
តើសមធមិមានអត្ថន័យដូចម្តេច ក្នុងទំនាក់ទំនងដែលមានគំលាតពីគ្នាដ៏ធំនៃអំណាច ធនធាន និង ឥទ្ធិពល ? សមធមិគឺមិនមានន័យដូចពាក្យសមភាពទេ ។ សមធមិ សំដៅលើសិទ្ធិស្មើគ្នាលើតុពិភាក្សា និង ការធ្វើឱ្យមានសុពលភាពសំរាប់ការរួមចំណែកទាំងឡាយ ដែលមិនអាចវាស់វែងដោយតំលៃជាប្រាក់ ឬ កិត្តិនាមសាធារណៈ ។

**តម្លាភាព ?**
ភាពបើកចំហ និង ភាពស្មោះត្រង់ក្នុងទំនាក់ទំនងការងារ ជាបុរេលក្ខខណ្ឌនៃការទុកចិត្តគ្នាដែលមនុស្សជាច្រើនយល់ឃើញថា ការទុកចិត្តគ្នាជាធាតុដ៏សំខាន់នៃភាពជាដៃគូដែលទទួលជោគជ័យ ។ មានតែធ្វើការប្រកបដោយតម្លាភាពប៉ុណ្ណោះ ដែលអាចធ្វើឱ្យភាពជាដៃគូមួយមានគណនេយ្យភាពពិតប្រាកដចំពោះភ្នាក់ងារផ្តល់ហិរញ្ញប្បទាន និង អ្នកពាក់ព័ន្ធ ។





**ផលប្រយោជន៍ទ្វេទិស ?**

ប្រសិនបើដៃគូទាំងអស់ចូលរួមចំណែកក្នុងការកសាងភាពជាដៃគូនោះ គេនឹងទទួលបានប្រយោជន៍ពីភាពជាដៃគូវិញ ។ ភាពជាដៃគូដែលរឹងមាំនឹងធ្វើការ ដើម្បីសំរេចបាននូវផលប្រយោជន៍ជាក់លាក់សំរាប់ដៃគូនីមួយៗបានច្រើនជាងធម្មតា ។ មានតែតាមវិធីនេះទេ ដែលភាពជាដៃគូអាចធានាបានការតាំងចិត្តជាបន្តទៀតរបស់ដៃគូ ហើយដែលប្រការនេះនឹងធ្វើឱ្យមាននិរន្តរភាព ។

គុណតំលៃគន្លឹះទាំង ៣ នេះ អាចជាចំណុចចាប់ផ្តើមពិភាក្សាដ៏មានប្រយោជន៍រវាងដៃគូដែលមានសក្តានុពល មុននឹងចាប់ផ្តើមកសាងភាពជាដៃគូជាមួយគ្នាជាផ្លូវការ ទោះបីជាពេលក្រោយមកគោលការណ៍ទាំងនោះ ត្រូវផ្លាស់ប្តូរដោយគោលការណ៍ផ្សេងទៀតដែលបង្កើតឡើងពីក្រុមក៏ដោយ ។ អ្វីដែលសំខាន់ គឺថាគ្រប់ដៃគូទាំងអស់ទទួលយក និង ព្រមព្រៀងអនុវត្តតាមនូវអ្វីដែលក្រុមបានសំរេច ។

## បញ្ហាប្រឈមក្នុងភាពជាអ្នកដឹកនាំ

ការដោះស្រាយឧបសគ្គចំពោះការកសាងភាពជាដៃគូ និង ការធានាថាគុណតំលៃដែលបានព្រមព្រៀងត្រូវបានគោរពជាបន្តបន្ទាប់នោះនឹងបង្កើតបញ្ហាប្រឈមធំៗខ្លះសំរាប់ភាពជាអ្នកដឹកនាំក្នុងភាពជាដៃគូ ។ បញ្ហាប្រឈមផ្សេងទៀត គឺទាក់ទងនឹងការគ្រប់គ្រងប្រចាំថ្ងៃលើកិច្ចការរបស់គំរោង និង សកម្មភាពដែលអនុវត្តជាដៃគូ ។ ជារួមអ្វីដែលម្នាក់ៗកំពុងប្រតិបត្តិក្នុងភាពជាដៃគូគិតអំពីគ្នាទៅវិញទៅមកនោះ គឺ (តើគេមានអារម្មណ៍ផ្សារភ្ជាប់ជាមួយនឹងគោលបំណងរួមឬទេ ?) និង អារម្មណ៍របស់ពួកគេចំពោះភាពជាដៃគូ គឺ (តើគេចែករំលែកការប្តេជ្ញាចំពោះការធ្វើការងារជាមួយគ្នាឬទេ ?) មានសារៈសំខាន់ខ្លាំងណាស់ ។ ការកសាងភាពជាដៃគូតំរូវឱ្យមានឥរិយាបថត្រឹមត្រូវ ហើយមានការប្តេជ្ញាចិត្តខ្ពស់ ក៏ដូចជារចនាសម្ព័ន្ធ ជំនាញ និង វិធានការត្រឹមត្រូវផងដែរ ។ ហើយបញ្ហាប្រឈមនៃភាពជាអ្នកដឹកនាំក្នុងការធ្វើការជាដៃគូ គឺមានទំនាក់ទំនងជាមួយនឹងប្រការទាំងនេះឯងហើយបញ្ហានេះនឹងលើកមកបរិយាយលំអិតនៅជំពូកទី ៤ ។

**ចំណាំ**

ភាពជាដៃគូ ត្រូវការកិច្ចខិតខំប្រឹងប្រែងជាច្រើនពីសមាជិកដែលចូលរួម ជាពិសេស គេត្រូវវិនិយោគពេលវេលាយ៉ាងច្រើនដើម្បីកសាងគុណភាពទំនាក់ទំនងការងារ ដែលជួយជំរុញឱ្យមានកិច្ចសហការល្អ ។ ហានិភ័យដែលអាចមាននៅត្រង់ចំណុចនេះ គឺថាវាអាចនាំទៅការផ្តោតលើតែភាពជាដៃគូក្នុងគោលបំណងទាញយកប្រយោជន៍រៀងៗខ្លួនជាជាងសមត្ថភាពក្នុងការអនុវត្តកម្មវិធីដែលមានសារប្រយោជន៍ ។ ការកសាងភាពជាដៃគូ គឺជាយន្តការមួយសំរាប់ការអភិវឌ្ឍប្រកបដោយនិរន្តរភាពក្នុងវិស័យសេដ្ឋកិច្ច បរិដ្ឋាន សង្គម គឺមិនមែនបញ្ចប់នៅត្រឹមតែធ្វើឱ្យវាកើតមានឡើងនោះទេ ។

# កំណត់ត្រា

# ២ ការកសាងភាពជាដៃគូ

## ការកំណត់រកដៃគូ

ភាពជាដៃគូដែលមានភាពរឹងមាំបំផុត គឺជាភាពជាដៃគូទាំងឡាយណា ដែលរួមគ្នាបង្កើតចេញជាសំនុំល្អបំផុតនៃអង្គភាពជាដៃគូមួយចំនួន ។ ក្នុងដំណាក់កាលដំបូងបន្ទាប់ពី "ការកំណត់វិសាលភាព" ក្នុងភាពជាដៃគូមួយ ជាការសំខាន់ត្រូវ :

- កំណត់រកអង្គភាពដៃគូប្រភេទណា ដែលអាចជួយបន្ថែមតំលៃ
- រកជំរើសនានាដែលអាចមានដោយការបង្កើតចេញពីដៃគូដែលមានអសយដ្ឋានទំនាក់ទំនងស្រាប់ ឬ ដោយការស្វែងរកដៃគូថ្មីទៀត
- ជ្រើសរើសយកដៃគូដែលសមស្របបំផុត និង ត្រូវធ្វើឱ្យគេចូលរួមយ៉ាងសកម្ម

វាមានតម្លៃសំរាប់ការចំណាយពេលវេលាដើម្បីធ្វើការងារនេះ ហើយរកព័ត៌មានឱ្យបានច្រើនតាមដែលអាចរកបានដើម្បីជួយដល់ការធ្វើការសំរេចចិត្តយ៉ាងត្រឹមត្រូវ រួមទាំងការសិក្សាស្រាវជ្រាវដើម្បីបញ្ជាក់ពីកំណត់ត្រាសាវតាររបស់អង្គភាពមួយ ។ ការនេះអាចធ្វើដោយ ការអាននូវរបាយការណ៍ប្រចាំឆ្នាំ មើលគេហទំព័រ ធ្វើការស្វែងរកការពិតដោយការទៅទស្សនកិច្ច ឬ ក៏សាកសួរមនុស្សផ្សេងទៀត ដែលស្គាល់ប្រវត្តិអង្គភាពនោះ ដើម្បីដឹងអំពីទស្សនៈរបស់គេ ។ ការសន្ទនាជាដំបូង អាចធ្វើជាមួយអ្នកដឹកនាំថ្នាក់កំពូលៗរបស់អង្គភាពនោះ ។ នេះមិនមែនមានន័យថា ជួបគ្នាដើម្បីបង្កើតជាដៃគូទេ តែវាជួយផ្តល់ឱកាសឱ្យទាំងពីរភាគីអាចធ្វើការប្រមើលមើលក្នុងដំណាក់កាលដំបូង តើគួរបន្តទៅមុខទៀត ឬ អត់ ។ ជាការល្អ ភាគីទាំងពីរអាចលើកអ្វីដែលជាកង្វល់មកដោះស្រាយ និង បញ្ជាក់ឱ្យច្បាស់ពីទំនាស់ផលប្រយោជន៍ផ្សេងៗដែលអាចមាន ។

វាចាំបាច់ត្រូវពន្យល់គោលគំនិតនៃភាពជាដៃគូ និង បង្កើតករណីមួយសំរាប់រកហេតុផលដែលអង្គភាពទាំងនេះអាចមានដើម្បីចូលរួមចំណែកក្នុងភាពជាដៃគូ និង របៀបដែលអង្គភាពអាចទទួលផលប្រយោជន៍ ។ ដំណើរការនេះអាចត្រូវចំណាយពេលយូរដើម្បីបញ្ចុះបញ្ចូលមនុស្សក្នុងអង្គភាពទាំងនោះបានយល់ថា ភាពជាដៃគូត្រូវការលះបង់ពេលវេលា និង ការខិតខំប្រឹងប្រែង ។

ឧបករណ៍ទី ១
ទម្រង់ប៉ាន់ប្រមាណដៃគូ : ផ្តល់ការគូសលើសំណួរដែលសួរអំពីដៃគូនីមួយៗ

វាអាចមានការរៀបចំសកម្មភាពពិសេសៗ (សិក្ខាសាលា ទស្សនកិច្ច ការផ្លាស់ប្តូរ) រវាងអង្គភាពជាដៃគូសំខាន់ៗ ដើម្បីស្វែងរកគំនិតក្នុងការកសាងភាពជាដៃគូឱ្យបានពេញលេញ និង ប្រកបដោយការសហប្រតិបត្តិការច្រើនថែមទៀត មុននឹងមានការព្រមព្រៀងគ្នាលើការតាំងចិត្តជាក់លាក់ណាមួយ ។ ជាការល្អ ត្រូវបែងចែកការងារតាមដានសំរាប់ម្នាក់ៗ ដើម្បីប៉ាន់ប្រមាណសមត្ថភាពរបស់ខ្លួន និង ដើម្បីឱ្យប្រាកដថា គេអាចប្រែក្លាយការតាំងចិត្តជាពាក្យសំដីរបស់គេឱ្យទៅជាសកម្មភាពបាន ។

ក្នុងករណីខ្លះ អាចមានតិចតួច ឬ គ្មានជំរើសសំរាប់រកដៃគូ ។ ឧទាហរណ៍ ប្រសិនបើជាករណីចាំបាច់ត្រូវតែធ្វើការជាមួយអាជ្ញាធរមូលដ្ឋាន នោះត្រូវការខំប្រឹងប្រែងដើម្បីបញ្ចុះបញ្ចូលពួកគេឱ្យមានការចូលរួមយ៉ាងសកម្ម ដោយបង្ហាញនូវរបៀបដែលគេអាចទទួលបានផលប្រយោជន៍ (ដូចជាគោលដៅរបស់គេអាចបានសំរេច) តាមរយៈការធ្វើការក្នុងកិច្ចសហប្រតបត្តិការមានលក្ខណៈស្ថាបនាល្អជាមួយវិស័យផ្សេងៗទៀត ។

ទោះជាយ៉ាងណាក៏ដោយ ក្នុងគ្រប់ស្ថានភាពទាំងអស់ ជាការសំខាន់ត្រូវធ្វើឱ្យមានភាពពិតប្រាកដនូវអ្វីដែលភាពជាដៃគូអាចសំរេចបានជោគជ័យ និង ការបើកចំហទទួលយកនូវបញ្ហាប្រឈមដែលកើតមាន ។

**ចំណាំ**

គ្មានដៃគូណាមួយ (រួមទាំងលោកអ្នក និង អង្គភាពលោកអ្នកដែរ) ល្អឥតខ្ចោះនោះទេ ។ អ្វីដែលលោកអ្នកកំពុងស្វែងរក គឺអង្គភាពដៃគូមួយ ដែលអាចផ្តល់ឱ្យលោកអ្នកនូវការស៊ីសង្វាក់ល្អមួយ ដែលនឹងជួយឱ្យភាពជាដៃគូអាចសំរេចគោលដៅរបស់វាបាន ។ សំខាន់ជាងនេះទៀត លោកអ្នកស្វែងរកដៃគូដែលមានលក្ខណៈសម្បត្តិសមស្របឱ្យបានច្រើន និង មានសក្តានុពលច្បាស់លាស់ ដើម្បីធ្វើឱ្យចំរើនពេញលេញក្នុងតួនាទីជាដៃគូតទៅពេលខាងមុខទៀត

## ការប៉ាន់ប្រមាណហានិភ័យ និង រង្វាន់

ភាគីនីមួយៗត្រូវប៉ាន់ប្រមាណនូវហានិភ័យ និង រង្វាន់ ដែលអាចកើតមានឡើងពីការចូលរួមក្នុងភាពជាដៃគូអន្តរវិស័យ ។ ជាការពិត ដៃគូនីមួយៗត្រូវការយល់ដឹងអំពីហានិភ័យ និង រង្វាន់ដែលអាចមានចំពោះអង្គភាពដែលជាដៃគូឱ្យបានច្បាស់លាស់ ដូចជាស្គាល់ហានិភ័យ និង រង្វាន់របស់អង្គការខ្លួនដែរ ប្រសិនបើគេពិតជាតាំងចិត្តចំពោះកិច្ចសហប្រតិបត្តិការដែលស្មោះត្រង់ និង គោលការណ៍ "ផលប្រយោជន៍ទ្វេទិស" ។ ពេលដែលមានលក្ខណៈរួមដែលភាគីនីមួយៗជឿថា ហានិភ័យសំរាប់អង្គភាពរបស់គេធំជាងអង្គភាពដៃគូផ្សេងៗនោះ ជាការគួរឱ្យចាប់អារម្មណ៍ដើម្បីកត់សំគាល់ថា ប្រភេទហានិភ័យភាគច្រើនអាចកើតមានដូចគ្នាចំពោះគ្រប់ភាគីដៃគូទាំងអស់ ។

ហានិភ័យលំដាប់អង្គភាពចំពោះវិស័យនីមួយៗ អាចនឹងកើតមានឡើងតាមផ្នែកដូចខាងក្រោម :

- **ផលប៉ះពាល់លើកេរ្តិ៍ឈ្មោះ** គ្រប់អង្គភាព និង ស្ថាប័នទាំងអស់ឱ្យតំលៃលើកេរ្តិ៍ឈ្មោះរបស់គេ និង មានកង្វល់ក្រែងខូចកេរ្តិ៍ឈ្មោះដោយសារការចូលរួមជាដៃគូ ឬ ក៏ការបែកបាក់ពីភាពជាដៃគូពេលអនាគត ។
- **បាត់បង់ស្វ័យភាព** ការធ្វើការងារក្នុងកិច្ចសហប្រតិបត្តិការមានន័យថា មានឯករាជ្យភាពតិចតួចជារឿងចៀសមិនរួច ជាពិសេសក្នុងផ្នែកការងារដែលធ្វើរួមគ្នា ។
- **ទំនាស់ផលប្រយោជន៍** ទោះបើក្នុងកិរិតយុទ្ធសាស្ត្រ ឬ កិរិតប្រតិបត្តិការក្តី ការតាំងចិត្តចំពោះភាពជាដៃគូអាចកើតចេញការបែកបាក់ភក្តីភាព ឬ មានអារម្មណ៍ថាត្រូវបានបង្ខំឱ្យទទួលយកការសំរុះសំរួលមួយដែលមិនពេញចិត្ត ។
- **រំលោះធនធាន** ជាធម្មតាភាពជាដៃគូតំរូវឱ្យមានការវិនិយោគធំ (ជាពិសេសពេលវេលា) មុននឹងទទួលបានផលប្រយោជន៍ក្នុងកិរិតមួយសមស្របត្រឡប់មកវិញ ។
- **បញ្ហាប្រឈមនៃការអនុវត្ត** ពេលដែលបង្កើតភាពជាដៃគូបាន ហើយធនធានត្រូវបានផ្តល់ឱ្យនោះនឹងមានការតាំងចិត្តស្រួចស្រាវមួយចំនួន និង បញ្ហាប្រឈមផ្សេងៗចំពោះអង្គភាពជាដៃគូនៅពេលដែលភាពជាដៃគូឈានដល់ការអនុវត្តគំរោង ។

ការប៉ាន់ប្រមាណហានិភ័យ គឺជារឿងសំខាន់ តែពេលខ្លះអាចភ្លេចដោយងាយ ដោយសារតែភាពសប្បាយចិត្តជាមួយនឹងផលប្រយោជន៍ដែលបានពីកិច្ចសហប្រតិបត្តិការជាមួយដៃគូ ។ ដៃគូគួរតែលើកទឹកចិត្តគ្នាទៅវិញទៅមកឱ្យធ្វើការប៉ាន់ប្រមាណហានិភ័យតាំងពីគ្រាដំបូងៗនៃការធ្វើសហប្រតិបត្តិការរបស់គេ ហើយបើអាចទៅរួច គួរតែរកឱកាសដើម្បីលើកយកនូវការបារម្ភមកដោះស្រាយរួមគ្នាជាក្រុម ជាចំហ និង ក្នុងបរិកាសមិនវិនិច្ឆ័យ ។

តែជាការពិត ដៃគូទាំងអស់មើលឃើញថា រង្វាន់ដែលទទួលបាននោះធំជាងហានិភ័យទៅទៀត ហើយនៅទីនេះដែរមានប្រភេទនៃផលប្រយោជន៍ជាច្រើនដែលភាគីជាដៃគូជាទូទៅអាចទទួលបាន ។ ប្រភេទនៃផលប្រយោជន៍ទាំងនោះរួមមាន :

- អភិវឌ្ឍវិជ្ជាជីវៈរបស់បុគ្គលិកសំខាន់ៗ
- មានលទ្ធភាពទទួលព័ត៌មាន និង បណ្តាញការងារផ្សេងៗប្រសើរជាងមុន
- លទ្ធភាពពង្រីកការងារច្រើនជាងមុន

បន្ថែមលើប្រយោជន៍ដែលមានលក្ខណៈរួមគ្នាខាងលើនេះ នៅមានរង្វាន់ច្រើនផ្សេងទៀត ដែលមានលក្ខណៈជាក់លាក់ទៅតាមដៃគូនីមួយៗ ។ ជាការប្រពៃរង្វាន់ទាំងនេះ គួរត្រូវបានទទួលដឹង និង ចែករំលែកឱ្យគ្នាទៅវិញទៅមកតាំងពីគ្រាដំបូងៗនៃភាពជាដៃគូ ដើម្បីឱ្យមានការទទួលយកនូវអាទិភាពរបស់គ្នាទៅវិញទៅមកដោយរីករាយ ហើយត្រូវធានាថាដៃគូទាំងអស់យល់ដឹងច្បាស់អំពីការរំពឹងទុករបស់ដៃគូនីមួយៗអំពីភាពជាដៃគូ ។

## ការរៀបចំធនធាន

មុននឹងបង្កើតភាពជាដៃគូជាផ្លូវការ រឿងសំខាន់សំរាប់ដៃគូត្រូវពិចារណា គឺតើធនធានអ្វីខ្លះដែលត្រូវការចំណាយលើកម្មវិធី ឬ គំរោងដែលបានព្រមព្រៀងគ្នា ។ ជាធម្មតា គេគណនាធនធានដោយយោងទៅនឹងលក្ខខណ្ឌផ្តល់មូលនិធិ ប៉ុន្តែផលប្រយោជន៍ជាក់ស្តែងមួយទៀត ក្នុងចំណោមផលប្រយោជន៍ដែលបានពីការធ្វើការបែបអន្តរវិស័យនោះ គឺលទ្ធភាពច្រើនជាងមុនសំរាប់ទទួលធនធានមិនមែនសាច់ប្រាក់ដែលដៃគូនីមួយៗនាំមកចូលរួមក្នុងភាពជាដៃគូ ។

ការប្រជុំដៃគូមួយដង (ឬច្រើនដង) ដែលផ្តោតលើការកំណត់រកធនធាន ដែលដៃគូនីមួយៗអាចនឹងចូលរួមចំណែកអាចមានប្រយោជន៍ច្រើនណាស់ ។ រៀបចំតាមទម្រង់សិក្ខាសាលា បើមានលទ្ធភាពអញ្ជើញអ្នកសម្របសម្រួលពីខាងក្រៅដែលមានបទពិសោធន៍ជាមួយនឹងដំណើរការនេះមករៀបចំ ។ ការប្រជុំអាចផ្តល់ឱកាសឱ្យដៃគូនីមួយៗអាចរកឃើញសក្តានុពលរបស់ខ្លួនសំរាប់ចូលរួមចំណែកជាធនធាន និង ក្នុងស្មារតីប្រកួតប្រជែងប្រកបដោយភាពទន់ភ្លន់ អាចនាំឱ្យគេទទួលបានការតាំងចិត្តយ៉ាងមោះមុត ដែលជួយឱ្យភាពជាដៃគូអាចចាប់ដំណើរការបានរហ័ស និង មានប្រសិទ្ធផលថែមមួយកំរិតទៀត (សូមមើលប្រអប់ ២ ទំព័រ១៤) ។

មានមធ្យោបាយសំរាប់អនុវត្តន៏ការងារនេះប្រកបដោយថាមពលខ្ពស់ ។ មធ្យោបាយសមញ្ញបំផុតមួយ គឺសូមឱ្យទាំងអស់គ្នាដែលនៅក្នុងបន្ទប់សរសេរធនធានដែលពួកគេអាចចូលរួមលើក្រដាសកាត បន្ទាប់មកបិទលើផ្ទាំងក្រដាសធំបិទជាប់នឹងជញ្ជាំងដែលគ្រប់គ្នាអាចមើលឃើញកាតទាំងនោះកើនច្រើនឡើងៗ ។ ក្រដាសកាតអាចជាក្រដាសពណ៌ ដើម្បីកំណត់ចំណាំថាតើបានផ្តល់មកពីដៃគូណាមួយ ។ កាតទាំងនេះអាចដាក់ជាក្រុមៗតាមប្រភេទធនធាន ហើយក្រុមទាំងមូលធ្វើការពិនិត្យ និង សរសេរកាតដាក់បន្ថែមប្រសិនបើមានគំនិតថ្មីផ្សេងពីនោះ ។

ក្រៅពីការទទួលបានការចូលរួមចំណែកជាធនធនដែលការប្រជុំនេះសំរេចបាន ដំណើរការនេះមានតំលៃមិនអាចកាត់ថ្លៃក្នុងការកសាងការគោរព ការយល់គ្នា និង ការងារក្រុមរវាងដៃគូទាំងអស់ ។ ទាំងអស់នេះជាបុរេលក្ខខណ្ឌដ៏សំខាន់សំរាប់ជោគជ័យក្នុងកិច្ចសហប្រតិបត្តិការ ។

# ប្រអប់ ២ ការបង្កើតផែនទីធនធាន

**គន្លឹះ : ផរ = រដ្ឋាភិបាល  ផធ = ផ្នែកឯកជន  ផស = ផ្នែកសង្គមស៊ីវិល**

## តើដៃគូនីមួយៗ មានអ្វីខ្លះចូលរួមចំណែក ក្នុងភាពជាដៃគូ ?

### ព័ត៌មាន (ការទទួល)
ស្ថិតិ-ក្របខ័ណ្ឌច្បាប់ (ផរ)
វិភាគទីផ្សារ-ព្យាករណ៍ទុកមុន (ផធ)
ចំណេះដឹងក្នុងមូលដ្ឋាន-លក្ខខណ្ឌសង្គម

### ទីកន្លែងសំរាប់
ភាពជាដៃគូ-ការិយាល័យ (រូម)
ការប្រជុំ-សិក្ខាសាលា (រូម)
ព្រឹត្តិការណ៍សំខាន់ៗ (ផរ. ផធ)
ឃ្លាំង ( ផធ. ផរ)
សកម្មភាពគំរោង (រូម)
ព័ត៌មានសាធារណៈ (រូម)

### ផលិតផល
(អាស្រ័យលើចំណុចគោលរបស់គំរោង និង ធុរកិច្ចដែលមាន)
ឱសថ (ផធ)
ឧបភោគបរិភោគ (ផធ)
ព័ត៌មានវិទ្យា (ផធ)
ផ្គត់ផ្គង់ថាមពល (ផធ. ផរ)

### ផ្សេងៗ
ដឹកជញ្ជូន (ផធ. ផរ)
ឧបករណ៍ (ផធ. ផរ)
គ្រឿងសង្ហារឹម (ផធ. ផរ)

### ព័ត៌មាន (ការផ្សព្វផ្សាយ)
ប្រព័ន្ធប្រាស្រ័យទាក់ទងអេឡិចត្រូនិក (រូម)
តាមផ្ទាល់មាត់ (រូម)
ឯកសារបោះពុម្ព (រូម)
បណ្តាញការងារ (រូម)

### ជំនាញ
ជំនាញបច្ចេកទេស (រូម)
អភិវឌ្ឍគំរោង (រូម)
កសាងសមត្ថភាព និង បណ្តុះបណ្តាល (រូម)
ការគ្រប់គ្រង (រូម)
ទីផ្សារ (ផធ)
សំរបសំរួល (ផស)
រៀបចំការប្រជុំ (ផរ)

### ទំនាក់ទំនងជាមួយ
អ្នកផ្តល់ហិរញ្ញប្បទាន (ផស. ផរ)
អ្នករៀបចំគោលនយោបាយ (ផរ. ផធ)
អ្នកផ្គត់ផ្គង់-អង្គការពលកម្ម (ផធ)
ស្ថាប័នសាសនា (ផស)
សាធារណៈទូទៅ (ផរ. ផស)
ក្រុមសហគមន៍ (ផស)
ឃោសនាផ្សព្វផ្សាយ (រូម)
អង្គការ (ផស. ផធ)

### ធនធានមនុស្ស
បុគ្គលិកឯកទេស (រូម)
បុគ្គលិកបណ្តែត (ផរ.ផធ)
អ្នកស្ម័គ្រចិត្ត (ផស. ផធ)
និសិត្ស-អ្នកហាត់ការ (ផរ)
គាំទ្ររដ្ឋបាល (រូម)

**ចំណាំ**

គ្រប់ផ្នែកទាំងអស់មានធនធានមនុស្ស, បច្ចេកទេស និង ធនធានចំណេះដឹង យ៉ាងហោចណាស់ក៏គេមានផ្នែកណាមួយដែរ ។ គេមានមិនដូចគ្នាទេ ហើយក៏វិតក៏មិនស្មើគ្នាដែរ តែនៅពេលដែលគេដាក់បញ្ចូលគ្នា គេអាចនឹងរកបានទូវធនធានយ៉ាងច្រើនដែលគេត្រូវការ ដើម្បីរៀបចំផែនការសកម្មភាព ។ ស្ថាប័នផ្តល់ហិរញ្ញប្បទានចង់ឃើញធនធាន ដែលបានយកមកចូលរួមចំណែកពីដៃគូនីមួយៗ ហើយមានធនធានក្រៅពីថវិកាជាច្រើនដែលធ្វើឱ្យធនធានថវិកាកាន់តែមានតម្លៃ ។ ធនធានលុយកាក់ គួរតែមើលវានៅដំណាក់កាលចុងក្រោយ វាមិនមែនជាតំរូវការទី ១ ទេ ។

# ៣ កិច្ចព្រមព្រៀងសំរាប់បង្កើតភាពជាដៃគូ

## កសាងការប្តេជ្ញារបស់ដៃគូ

ភាពជាដៃគូច្រើនជាងការសន្ទនាគ្នាបន្តិច រហូតដល់ពេលអ្នកចូលរួមធ្វើការតាំងចិត្តសហប្រតិបត្តិការ ។ ការតាំងចិត្តនេះត្រូវបានកត់ត្រាទុកក្នុងកិច្ចព្រមព្រៀងភាពជាដៃគូ ឬ ក្នុងអនុស្សារណៈយោគយល់គ្នា ។ មានការខុសគ្នារវាងកិច្ចព្រមព្រៀង និង កិច្ចសន្យា គឺថាកិច្ចព្រមព្រៀងជាទូទៅ :

- មិនចងដោយផ្លូវច្បាប់ទេ
- បង្កើត និង ព្រមព្រៀងគ្នាដោយភាគីទាំងសងខាងក្នុងឋានៈស្មើភាពគ្នា
- ត្រៀមជាស្រេចក្នុងការចរចាម្តងទៀត
- តែមួយដងចប់ ( ទោះបីជាពេលខ្លះការព្រមព្រៀងគ្នារយៈពេលខ្លីជាស៊េរី សមស្របជាងកិច្ចព្រមព្រៀងមួយដងចប់)
- ចូលរួមដោយការស្ម័គ្រចិត្ត

ដៃគូទាំងឡាយបង្កើតកិច្ចព្រមព្រៀងដើម្បីសហប្រតិបត្តិការដ៏មានប្រសិទ្ធភាព ហើយនេះអាចជារឿងដែលគេត្រូវការចាប់ផ្តើមធ្វើការបានល្អជាមួយគ្នា ។ នៅដំណាក់កាលបន្ទាប់ ប្រហែលជាចាំបាច់ត្រូវបង្កើតកិច្ចសន្យាចងសម្ព័ន្ធជាមួយគ្នាតាមផ្លូវច្បាប់ ដើម្បីបំពេញការងារក្នុងទ្រង់ទ្រាយធំ ឬ ក្នុងគំរោងស្មុគស្មាញដែលដំណើរការដោយការប្រើប្រាស់មូលនិធិក្នុងទ្រង់ទ្រាយធំ ឬ ចុះបញ្ជីជាទំរង់ថ្មីនៃស្ថាប័ន ។ ប៉ុន្តែការព្រមព្រៀងបង្កើតភាពជាដៃគូតាមធម្មតាជាជំហានដំបូង ហើយក្នុងកាលៈទេសៈជាច្រើន ការបង្កើតកិច្ចព្រមព្រៀងនេះអាចសមល្មមដើម្បីបញ្ជាក់ និង ចងបញ្ចូលគ្នានូវភាពជាដៃគូពីរយៈពេលមធ្យមទៅយូរអង្វែង ។

## ការចរចាដោយផ្អែកលើផលប្រយោជន៍

ដើម្បីទទួលបានកិច្ចព្រមព្រៀង តំរូវឱ្យមានការចរចា ប៉ុន្តែនៅក្នុងកិច្ចព្រមព្រៀងជាដៃគូនេះ មិនមែនជាការចរចាដូចជារបៀបពាណិជ្ជកម្មដ៏តឹងតែងនោះទេ ។ អ្វីដែលជាតំរូវការនោះ គឺជាឱកាសសំរាប់ប្រយោជន៍ជាមូលដ្ឋានរបស់ដៃគូទាំងអស់ដើម្បីលើកយកមកពិភាក្សាក្នុងវិធីមួយមានគោលដៅជាក់លាក់ ក្នុងគោលបំណងកសាងការឯកភាព និង បំពេញគ្នាចៀសឆ្ងាយពីសេចក្តីប្រាថ្នាដែលខុសគ្នា ។

ដៃគូដែលអនុវត្តតាមទម្រង់នៃការចរចាបែបនេះ ត្រូវការពិចារណាលើការអត់ធ្មត់ ភាពប៉ិនប្រសព្វ និង មានការបត់បែនកំរិតខ្ពស់ តែបើសិនជាភាគីណាមួយសំដែងនូវឆន្ទៈធ្វើយ៉ាងដូច្នេះហើយនោះ ភាគីផ្សេងនឹងធ្វើតាមការដឹកនាំរបស់គេ ។

**ចំណាំ**

ការចរចាដោយផ្អែកលើផលប្រយោជន៏ បំរើយ៉ាងល្អនៅពេលដែលអ្នកចូលរួម :

- ស្តាប់ដោយយកចិត្តទុកដាក់
- សួរសំណួរបើក ( ប្រសើរជាងសំណួរបិទ)
- សង្ខេបនូវអ្វីដែលបាននិយាយ ដើម្បីធានាថាគេមានការយល់ច្បាស់នូវអ្វីដែលបាននិយាយ
- ពេលណាចាំបាច់ គួរយល់ព្រមលើអ្វីដែលមិនទាន់យល់ព្រម ដើម្បីជំរុញការពិភាក្សាទៅមុខទៀត

# ប្រអប់ ៣ រចនាសម្ព័ន្ធជាផ្លូវការ និង មិនផ្លូវការ

| ប្រភេទរចនាសម្ព័ន្ធ | គុណសម្បត្តិ | គុណវិបត្តិ |
|---|---|---|
| **មិនផ្លូវការ** | | |
| ក្រុមការងារ<br>មនុស្សមួយក្រុមតូចដែលព្រមព្រៀងគ្នាស្វែងរកការផ្តួចផ្តើមភាពជាដៃគូ ដែលតំណាងឱ្យមនុស្ស ១ ក្រុមធំ | សេរីភាពច្រើនជាងមុនក្នុងកាស្វែងរកគំនិតបំណង និង ដើម្បីកសាងទំនាក់ទំនងថ្មី | មិនបានខំប្រឹងប្រែងអស់ពីកាយចិត្តដោយភ្នាក់ងារខាងក្រៅ ឬ តួអង្គផ្សេងទៀត |
| ក្រុមបង្គោល<br>មនុស្សមួយក្រុមតូចដែលព្រមព្រៀងគ្នា ដើម្បីឱ្យទិដ្ឋភាពជាក់លាក់នៃការអភិវឌ្ឍភាពជាដៃគូទៅមុខមួយជំហានទៀត | ថ្លៃថោកជាងតំរូវការធនធានសំខាន់ៗ គឺពេលវេលាជាជាងរូបិយប័ណ្ណ | ងាយនឹងធ្វេសប្រហែស ពេលដែលអ្នកចូលរួមបង្វែរចំណុចអាទិភាពរបស់គេ |
| ក្រុមកិច្ចការ<br>តែងតាំងភារកិច្ចក្រុម ដើម្បីសំរេចការងារជាក់លាក់មួយ (ឧ. ផ្តល់សំភារៈ គ្រប់គ្រងដំណើរការចុះឈ្មោះ) | មិនមែនការិយាធិបតេយ្យ | មិនមានរចនាសម្ព័ន្ធគ្រប់គ្រាន់សំរាប់ការសំរបសំរួល និង គ្រប់គ្រងធនធាន |
| **ផ្លូវការខ្លះ** | | |
| បណ្តាញការងារ<br>រៀបចំការប្រាស្រ័យទាក់ទងភ្ជាប់អ្នកដែលមានសកម្មភាពការងារស្រដៀងគ្នា | អភិវឌ្ឍន៍ទម្រង់ធំជាងមុន | ត្រូវការការសំរបសំរួលប្រសើរជាង |
| វេទិកា<br>កន្លែងប្រជុំសំរាប់ការពិភាក្សាជាចំហ | ផ្តល់ការគាំទ្ររួមសំរាប់ការងារដែលមិនប្រទាក់ក្រឡាគ្នាល្អ | តំរូវឱ្យមានការព្រមព្រៀងលើគោលនយោបាយ និង គុណតំលៃនៃប្រតិបត្តិការ |
| សង្គម<br>អង្គភាពសមាជិកមួយមានការផ្តោតខ្លាំងលើសកម្មភាពការងារ | កសាងការតាំងចិត្តពីមជ្ឈដ្ឋានទូលំទូលាយ | ដំណើរការធ្វើការសំរេចចិត្តកាន់តែស្មុគ្រស្មាញ |
| **ផ្លូវការ** | | |
| សមាគម<br>បែបផ្លូវការបន្តិច ស្ថាប័នថ្មីបានចុះបញ្ជីក្នុងសង្គម | បង្កើនសិទ្ធិអំណាច និង សមត្ថភាព ដើម្បីពង្រីកឥទ្ធិពល | យោងតាមការកំរិតដោយច្បាប់ក្នុងការធ្វើសកម្មភាព |
| មូលដ្ឋានគ្រឹះនៃការកកើត<br>សមាគមដែលគៀងគរ និង បែងចែកធនធាន | សកម្មភាពកាន់តែជាក់លាក់ ហើយទំនងជាមាននិរន្តរភាពច្រើនជាងមុន | និន្នាការលំអៀងទៅរកការិយាធិតេយ្យកាន់តែខ្លាំង និង មិនមានលក្ខណៈជាបុគ្គល |
| ភ្នាក់ងារ<br>អង្គភាពស្វយ័តដែលត្រូវបានបង្កើតឡើង ដើម្បីធ្វើសកម្មភាពជំនួសក្រុមផ្សេងទៀត | លើកកំពស់សមត្ថភាព ដើម្បីគៀងគរ និង ចាត់ចែងធនធានក្នុងទ្រង់ទ្រាយធំ | បង្កើនតំលៃការងារផ្នែករដ្ឋបាលកាន់តែខ្ពស់ (ដែលជំទាស់នឹងគំរោង) |

## អភិបាលកិច្ច និង គណនេយ្យភាព

ទោះបើក្នុងដំណាក់កាលដំបូង ភាពជាដៃគូត្រូវការរចនាសម្ព័ន្ធអភិបាលកិច្ច ដើម្បីធានាថាការសំរេចចិត្ត ការគ្រប់គ្រង និង ការរៀបចំការអភិវឌ្ឍ មានភាពសមស្រប និង ប្រតិបត្តិការប្រកបដោយប្រសិទ្ធភាព ។

ឧបករណ៍ទី ២
កំរងសំណួរប៉ាន់ប្រមាណ ដៅទុកនូវសំណួរសំខាន់ៗ ដែលដៃគូ គួរសួរដើម្បីរកឱ្យឃើញពីបំណង ឥរិយាបថ និង ការតាំងចិត្ត របស់ខ្លួន និង របស់ដៃគូ ។

ជាធម្មតា ដៃគូបានបង្ហាញការទទួលខុសត្រូវរបស់គេចំពោះអ្នកពាក់ព័ន្ធមួយចំនួន រួមមាន :

- អ្នកទទួលផលពីភាពជាដៃគូរបស់គំរោង
- អ្នកខាងក្រៅ (មិនមែនជាដៃគូ) ភ្នាក់ងារផ្តល់ហិរញ្ញប្បទាន (អ្នកដែលតំរូវឱ្យធ្វើរបាយការណ៍)
- អង្គភាពដៃគូនីមួយៗ (ដែលមានប្រព័ន្ធគណនេយ្យភាព និង មានអភិបាលកិច្ចផ្ទាល់ខ្លួន)
- ម្នាក់ៗជាសហការីក្នុងភាពជាដៃគូ

វាហាក់ដូចជាបង្ហាញថា គណនេយ្យភាពជាកត្តានាំផ្លូវដល់ភាពជាដៃគូជាងការទទួលស្គាល់ជារួម ហើយដោយហេតុផលនេះ និតិវិធីអភិបាលកិច្ច និង គណនេយ្យភាព ត្រូវមានការព្រមព្រៀងគ្នា និង ដាក់វាជាចំណុចស្នូលក្នុងកិច្ចព្រមព្រៀងជាដៃគូ ។

ក្នុងការអនុវត្តខ្លះ ដៃគូនឹងមានការជ្រើសរើសនូវអ្វីដែលគេធ្វើ និង ពីរបៀបដែលគេអនុវត្ត ។ ពួកគេអាចនឹងពិចារណានូវជម្រើសនានា ចាប់ពីការរៀបចំក្រៅផ្លូវការ (ឧ. ការជ្រើសរើសដៃគូក្នុងពេលត្រូវការ) រហូតដល់ការរៀបចំបែបផ្លូវការ (ឧ. អង្គភាពថ្មីដែលបានចុះបញ្ជី ដែលមាននិតិវិធីអភិបាលកិច្ច និង គណនេយ្យភាពឯករាជ្យ) មុននឹងធ្វើការជ្រើសរើសយកអ្វីមួយដែលសមស្របបំផុតសំរាប់តម្រូវការរបស់គេ ។

ឧបករណ៍ទី ៣
គំរូកិច្ចព្រមព្រៀងភាពជាដៃគូផ្តល់នូវទម្រង់កិច្ចព្រមព្រៀងជាដៃគូដំបូងបែបសាមញ្ញ ។

ទោះបីជាភាពជាដៃគូមិនផ្លូវការក្តី កិច្ចព្រមព្រៀងជាដៃគូតែងតែត្រូវការជាចាំបាច់ ដើម្បីចៀសវាងការយល់ច្រឡំ និង ទំនាស់គ្នានៅពេលក្រោយ ។ ដៃគូភាគច្រើនចាប់ផ្តើមតាមបែបមិនផ្លូវការ តែគេនឹងឈានទៅធ្វើតាមបែបផ្លូវការក្នុងពេលវេលាក្រោយមកទៀត ក្នុងគ្រាដែលកម្មវិធីការងាររបស់គេកាន់តែមានភាពស្មុគស្មាញ និង ប្រើប្រាស់ធនធានច្រើន (សូមមើលប្រអប់ ៣ ទំព័រ ១៦ និង ប្រអប់ ៤ ក្នុងទំព័រ ២២) ។

# កំណត់ត្រា

# ៤ គ្រប់គ្រងដំណើរការកសាងភាពជាដៃគូ

ខណៈដែលភាពជាដៃគូបានបង្កើតឡើង និង បានចុះហត្ថលេខាលើកិច្ចព្រមព្រៀងរួចរាល់ហើយ នឹងមានការប្រឈមថ្មីទៀតដែលត្រូវដោះស្រាយ ។

## តួនាទីក្នុងភាពជាដៃគូ

មនុស្សជាច្រើននឹងចូលរួមក្នុងភាពជាដៃគូតាមដំណាក់កាលផ្សេងៗគ្នា និង ប្រកាន់យកនូវតួនាទីខុសៗគ្នាតាមតំរូវការ ។ ជាការសំខាន់ចំពោះការទទួលស្គាល់នូវភាពទីទៃពីគ្នា និង ដឹងថា តើតួនាទីអ្វីខ្លះដែលត្រូវការ ក្នុងដំណាក់កាលណា និង ក្នុងគោលបំណងអ្វី ។ វាក៏ជាការសំខាន់ណាស់ដែរ ក្នុងការធានាថាគេបានជ្រើសរើសមនុស្សសំខាន់សំរាប់តួនាទីជាក់លាក់ណាមួយ ។ តួនាទីអាចនឹងមានការផ្លាស់ប្តូរញឹកញាប់ក្នុងជីវិតនៃភាពជាដៃគូ ហើយដៃគូអាចនឹងរីកចំរើនទៅតាមតួនាទីថ្មីៗ នៅពេលដែលគេមានបទពិសោធន៏កាន់តែច្រើននៅក្នុងការងារជាដៃគូ ។

| តួនាទី | កំណត់សំគាល់ |
|---|---|
| ដៃគូ | ម្នាក់ៗ (ឬ ច្រើននាក់) ដែលជំរុញឱ្យកើតមានភាពជាដៃគូ ដោយប្រើកេរ្តិ៍ឈ្មោះផ្ទាល់ខ្លួន ឬវិជ្ជាជីវៈ ឬ តួនាទី ដើម្បីធ្វើឱ្យភាពជាដៃគូកាន់តែប្រសើរឡើង ឬ ចេញជារូបរាង ។ |
| អន្តរការី<br>ឬ អ្នកជាកណ្តាល | ជាបុគ្គលដែលគេជ្រើសរើស (ពីក្នុងអង្គភាពដៃគូ ឬ ពីខាងក្រៅ) ឱ្យធ្វើការងារក្នុងនាមដៃគូ ដើម្បីជួយកសាង និង ពង្រឹងភាពជាដៃគូ ជាពិសេសនៅដំណាក់កាលដំបូងៗ ។ |
| ស្ថាប័នផ្តល់<br>ហិរញ្ញប្បទាន | ប្រសិនបើដៃគូទាំងអស់ចូលរួមវិភាគទានសំរាប់ភាពជាដៃគូ (សូមមើលផ្នែកទី ២) ដៃគូទាំងអស់ គឺជាស្ថាប័នផ្តល់ហិរញ្ញប្បទាន (សំគាល់ : មានករណីជាច្រើនដែលស្ថាប័នខាងក្រៅផ្តល់ហិរញ្ញប្បទានសំរាប់ភាពជាដៃគូ ពេលនោះ ដៃគូត្រូវដឹងឱ្យច្បាស់អំពីទំនាក់ទំនង និង របៀបធ្វើរបាយការណ៏ទៅពួកគេ ដោយមិនធ្វើឱ្យអន្តរាយដល់សុចរិតភាពនៃភាពជាដៃគូ ។ |
| អ្នកគ្រប់គ្រង | បុគ្គលដែលបានទទួលការតែងតាំងដោយមានប្រាក់ឈ្នួលដើម្បីគ្រប់គ្រងភាពជាដៃគូ និង/ឬ គំរោងដៃគូ ជាពិសេសនៅខណៈដែលភាពជាដៃគូបានបង្កើតឡើង និង នៅក្នុងដំណាក់កាលអនុវត្តគំរោង ។ |
| អ្នកសំរបសំរួល | បុគ្គល (ជាទូទៅអ្នកពីខាងក្រៅដៃគូ) ដែលបានទទួលការតែងតាំងដើម្បីគ្រប់គ្រងដំណើរការជាក់លាក់ណាមួយរបស់ភាពជាដៃគូ (ឧ. ការប្រជុំដើម្បីដោះស្រាយចំពោះបញ្ហាណាមួយដែលក្រុមជាដៃគូជួបប្រទះ) ។ |
| អ្នកគាំទ្រ | បុគ្គល (ភាគច្រើនជាសមាជិកនៃភាពជាដៃគូ) ដែលធ្វើសកម្មភាពគាំទ្រដៃគូផ្សេងទៀត អ្នកគាំទ្រសកម្ម ផ្តល់តំលៃចំពោះភាពជាដៃគូផ្អែកលើមូលដ្ឋាននៃកំណត់ត្រាព័តិមានជាក់ស្តែងជាងកិត្តិសព្ទផ្ទាល់ខ្លួនរបស់បុគ្គល ។ |

នៅក្នុងទម្រង់នេះ ភាពជាអ្នកដឹកនាំអាចនឹងប្តូរពីមនុស្សម្នាក់ទៅម្នាក់ទៀត អាស្រ័យទៅតាមតំរូវការសំរាប់ធ្វើឱ្យភាពជាដៃគូមានការវិវឌ្ឍប្រកបដោយផាសុខភាព និង មានការគ្រប់គ្រងល្អ ។

## ដៃគូជាអ្នកដឹកនាំ

ភាពជាដៃគូបានចោទជាបញ្ហាអំពីភាពជាអ្នកដឹកនាំ ។តើអ្នកដឹកនាំមានតួនាទីអ្វីនៅក្នុងគំរូដ៏សំខាន់នៃកិច្ចសហប្រតិបត្តិការ និង សមធម៌រវាងភាគីសំខាន់ៗ ? តើកិច្ចសហប្រតិបត្តិការរវាងដៃគូផ្សេងៗ ត្រូវដើរទន្ទឹមគ្នាជាមួយនឹងភាពជាអ្នកដឹកនាំដ៏ខ្លាំងពូកែដែរឬទេ ? តើភាពជាអ្នកដឹកនាំកើតឡើងយ៉ាងដូចម្តេច និង បង្ហាញក្នុងគំរូនៃភាពជាដៃគូដោយមិនធ្វើឱ្យប៉ះពាល់ដល់គោលការណ៍នៃការចែករំលែកការទទួលខុសត្រូវដោយរបៀបណា ? តើដៃគូនីមួយៗអនុវត្តតួនាទីសំខាន់ៗក្នុងនាមជាអ្នកដឹកនាំដែលតំណាងឱ្យភាពជាដៃគូ និង នៅក្នុងអង្គភាពរបស់ពួកគេផ្ទាល់យ៉ាងដូចម្តេច ?

ជាធម្មតា ក្នុងដំណាក់កាលខុសៗគ្នានៃដំណើរការកសាងភាពជាដៃគូ ដៃគូមួយ ឬ ដៃគូផ្សេងទៀត នឹងធ្វើបុរេសកម្មភាព ធ្វើជាតំណាង និង បង្ហាញភាពជាអ្នកដឹកនាំជាសាធារណៈ ។ ពួកគេទទួលខុសត្រូវ និង មានគណនេយ្យភាពចំពោះដៃគូ និង ចំពោះសកម្មភាពរបស់គេ ។ តើគួរជ្រើសរើសប្រភេទនៃការដឹកនាំបែបណា គឺអាស្រ័យតាមប្រភេទនៃភាពជាដៃគូ ភាពស្មុគ្រស្មាញនៃបញ្ហា ភាពបន្ទាន់នៃសកម្មភាព និង បុគ្គលិកលក្ខណៈរបស់មនុស្សដែលពាក់ព័ន្ធ ។ ភាពជាដៃគូ រួមបញ្ចូលមនុស្សដែលមានសមត្ថភាពជាអ្នកដឹកនាំមកពីប្រភពផ្សេងៗគ្នា ដូច្នេះឧបសគ្គភាគច្រើនកើតឡើងពីភាពមិនចុះសំរុង (មិនចែករំលែក) គ្នានៃដៃគូផ្សេងៗគ្នា ។

តួនាទីដឹកនាំផ្សេងទៀត ដែលត្រូវការនៅក្នុងដំណើរការកសាងភាពជាដៃគូ :

- ធ្វើសកម្មភាពជាអ្នកគ្រប់គ្រងលើបេសកកម្មភាពជាដៃគូ (ទាំងក្នុង និង ក្រៅ) និង ឈរលើគុណតំលៃរបស់ភាពជាដៃគូ ។
- បង្វឹកគ្នាទៅវិញទៅមក (ដោយផ្ទាល់ និង ប្រយោល) ក្នុងអាកប្បកិរិយាសមស្របនៅក្នុងភាពជាដៃគូ និង ជាដៃគូក្នុងការគ្រប់គ្រងគំរោង ។
- ហ៊ានប្រឈមចំពោះគ្នាទៅវិញទៅមកនៅក្នុងការធ្វើអ្វីមួយ និង ចំពោះបញ្ហាលំបាកផ្សេងៗ
- ផ្តល់អំណាចដល់សមាជិកផ្សេងៗទៀត ដើម្បីអាចធ្វើបុរេសកម្មភាព ដើម្បីធ្វើការកែប្រែ និង អាចទទួលបានការអត់ឱនចំពោះកំហុសឆ្គងផ្សេងៗ ។
- បង្កើតឱ្យមានសេចក្តីសង្ឃឹម និង សុទិដ្ឋិនិយម ពេលដំណើរការហាក់ដូចជាជាប់គាំង

ដំណាក់កាលដំបូងនៃដំណើរការកសាងភាពជាដៃគូ ជាការសំខាន់ត្រូវជ្រើសរើសមនុស្សម្នាក់ (មកពីអង្គការដៃគូ ឬពីក្រៅដៃគូ) ឱ្យធ្វើជាអន្តរការី ដើម្បីជួយកសាង និង ពង្រឹងភាពជាដៃគូ ។ អន្តរការីមានសមត្ថភាពភ្ជាប់ចក្ខុវិស័យទៅនឹងការងារអនុវត្តន៍ជាក់ស្តែងប្រចាំថ្ងៃ ។ អន្តរការីប្រតិបត្តិតាមបែបបទដឹកនាំថ្មី ដោយធ្វើជាចលករសំរាប់ជំរុញឱ្យមានការផ្លាស់ប្តូរតាមរយៈការណែនាំបង្ហាញផ្លូវច្រើនជាងការបង្គាប់បញ្ជា ។ ដើម្បីធ្វើឱ្យភាពជាដៃគូមានប្រសិទ្ធភាព និង ជំនះបានចំពោះការប្រឈមផ្សេងៗ ត្រូវចាប់ផ្តើមពីការតាំងចិត្តដ៏រឹងមាំពីបុគ្គលម្នាក់ៗចំពោះការកសាងភាពជាដៃគូ និង ជឿជាក់ទាំងស្រុងថា អភិក្រមនៃការកសាងភាពជាដៃគូ មានសារៈសំខាន់ក្នុងការសម្រេចគោលដៅដែលយើងចង់បាន ។

## ជំនាញសំរាប់កសាងភាពជាដៃគូ

ការកសាងភាពជាដៃគូបានជោគជ័យត្រូវការជំនាញច្រើន (ជំនាញខ្លះកើតមកជាធម្មតា និង ខ្លះទៀតកើតឡើងដោយសារគេបង្កើតវា) ហើយជំនាញទាំងអស់នោះ ត្រូវការសំរាប់ធ្វើការចរចា និង ជាអន្តរការីសម្របសម្រួល និង បង្វឹកដល់អ្នកផ្សេងៗទៀត ។ សមត្ថភាពធ្វើការងារជាក្រុម មានសារៈសំខាន់សំរាប់បុគ្គលម្នាក់ៗដែលចង់បំពេញការងារជាមួយគ្នាប្រកបដោយប្រសិទ្ធភាព និង សំរេចបានលទ្ធផលល្អប្រសើរ ។ ពួកគេអាចធ្វើការចរចាកិច្ចព្រមព្រៀង ឬ ធ្វើជាអន្តរការីរវាងដៃគូផ្សេងៗ ឬ សម្របសម្រួលកិច្ចប្រជុំដ៏លំបាកមួយ ។ ពួកគេត្រូវការធ្វើកំណត់ត្រាដោយសុក្រឹត និង ធ្វើការផ្សព្វផ្សាយព័ត៌មានជាច្រើន ។ ពួកគេប្រហែលជាត្រូវធ្វើការបង្វឹក ឬ កសាងសមត្ថភាពដៃគូផ្សេងៗទៀត អ្នកចូលរួមសំខាន់ៗ ឬ បុគ្គលិកគំរោង ។ ការធ្វើជាតំណាងសំរាប់ភាពជាដៃគូ ដើម្បីធ្វើឱ្យអង្គភាពរបស់ពួកគេចូលរួមកាន់តែស៊ីជំរៅថែមទៀត តម្រូវឱ្យមានជំនាញក្នុងការបង្កើត និង ពង្រឹងស្ថាប័ន ។ ជាចុងក្រោយ ដៃគូនីមួយៗនឹងមានការទទួលខុសត្រូវមួយចំនួនលើការវាយតំលៃ និង ពិនិត្យមើលឡើងវិញនូវការកសាងភាពជាដៃគូ និងផលប៉ះពាល់របស់វា ។

ជាការពិតណាស់ គ្មាននរណាម្នាក់មានជំនាញទាំងអស់នោះទេ ហើយក្នុងកិច្ចការនៃភាពជាដៃគូពួកគេមានគណនេយ្យភាពចំពោះភាពខ្លាំង និង ខ្សោយនៅក្នុងវិជ្ជាជីវៈរបស់ពួកគេ ។ បុគ្គលម្នាក់ៗដែលមកពីវិស័យផ្សេងៗគ្នានឹងនាំមកជាមួយនូវជំនាញ និង វិជ្ជាជីវៈខុសៗគ្នាមកចូលរួមក្នុងភាពជាដៃគូ ។ ដំណាក់កាលដំបូងកិច្ចការនឹងអាចត្រូវបានបែងចែកទៅដល់បុគ្គលណាដែលបានបង្ហាញអំពីភាពប៉ិនប្រសព្វរបស់ខ្លួនចំពោះសកម្មភាពជាក់លាក់ណាមួយ ។

ធ្វើការងារជាដៃគូបានផ្តល់ឱកាសឱ្យម្នាក់ៗបានអភិវឌ្ឍជំនាញ និង ពង្រឹងសមត្ថភាពរបស់គេផងដែរ ។ តាមការពិតនេះគ្រាន់តែជាផ្នែកមួយនៅក្នុងការកសាងភាពជាដៃគូ ដែលបង្កើតឱ្យមានការចាប់អារម្មណ៍ចំពោះអ្នកទាំងឡាយណាដែលត្រៀមរួចជាស្រេចដើម្បីធ្វើការផ្លាស់ប្តូរវិជ្ជាជីវៈ ។

ឧបករណ៍ទី ៤ :
កំរងសំណួរអំពីតួនាទី និង ជំនាញសំរាប់កសាងភាពជាដៃគូ :
ជួយឱ្យម្នាក់ៗអាចចូលរួមក្នុងការងារជាដៃគូ ដើម្បីប៉ាន់ប្រមាណសមត្ថភាពរបស់ខ្លួន និង ពីរបៀបដែលគេអភិវឌ្ឍសមត្ថភាពវិជ្ជាជីវៈដើម្បីក្លាយជាដៃគូដ៏ប្រសើរនៅអនាគត ។

ក្នុងដំណើរការអភិវឌ្ឍ និង ពង្រឹងសមត្ថភាព បុគ្គលម្នាក់ៗតែងតែអាចរកឃើញថា ដំណើរការភាពជាដៃគូមិនត្រឹមតែអាចនាំគេឆ្ពោះទៅរកភាពរីកចំរើននៃវិជ្ជាជីវៈប៉ុណ្ណោះទេ ប៉ុន្តែវាក៏ជាដំណើរផ្សងព្រេងមួយដើម្បីបានស្គាល់ និង ធ្វើការអភិវឌ្ឍខ្លួនឯងផងដែរ ។

ទោះជាយ៉ាងណាក៏ដោយ ជំនាញក្នុងការកសាងភាពជាដៃគូ ងាយនឹងចាប់យកបានសំរាប់អ្នកទាំងឡាយណាដែលស្គាល់ខ្លួនឯង និង អាចម្ចាស់ការគ្រប់គ្រងខ្លួនឯងបាន ។ ម្យ៉ាងវិញទៀត ការកសាងភាពជាដៃគូដែលមានប្រសិទ្ធភាព តម្រូវឱ្យមានមនុស្សដែលអាចយល់ និង គ្រប់គ្រងអារម្មណ៍ខ្លួនឯងបាន អ្នកដែលមានជំនឿចិត្តលើខ្លួនឯង និង អ្នកដែលមានការយល់ចិត្តគ្នា មានសុទិដ្ឋិនិយម មានការស្រមើស្រមៃ បើកចិត្តទូលាយ និង មានភាពរម្យទម ។ ភាពជាដៃគូក៏ត្រូវការចាំបាច់នូវដៃគូដែលមានគំនិតផ្តួចផ្តើមល្អ ។

## ប្រអប់ ៤ ជំរើសក្នុងការគ្រប់គ្រង និង អាណត្តិ

| ជំរើសក្នុងការគ្រប់គ្រង | គុណសម្បត្តិ | គុណវិបត្តិ |
|---|---|---|
| គ្រប់គ្រងបែបមជ្ឈការ<br>(ឧ. ការគ្រប់គ្រងភាពជាដៃគូ ឬ គំរោង ដោយអង្គភាពណាមួយតំណាងឱ្យភាពជាដៃគូ) | ● មានប្រសិទ្ធផលខ្ពស់<br>● សំរេចចិត្តច្បាស់លាស់ អំពីដំណើរការ និង ប្រព័ន្ធគ្រប់គ្រងការងារប្រចាំថ្ងៃ<br>● ដឹងច្បាស់អំពីអភិក្រមនៃការគ្រប់គ្រង<br>● មានច្រកចេញចូលតែមួយសំរាប់ធ្វើទំនាក់ទំនងជាមួយភ្នាក់ងារ ឬ បុគ្គលខាងក្រៅ<br>● ចំណាយពេលតិច | ● មានការលំបាកចំពោះដៃគូផ្សេងៗទៀតក្នុងការចូលរួម និង ចែករំលែក<br>● ឥទ្ធិពល និង ការគ្រប់គ្រងឋិតក្នុងដៃភាគីតែម្ខាង<br>● ពុំសូវមានភាពបត់បែនតាមតំរូវការរបស់ដៃគូ<br>● សំរេចចិត្តលឿន ប៉ុន្តែអាចពុំបានត្រឹមត្រូវ |
| គ្រប់គ្រងបែបវិមជ្ឈការ<br>(ឧ. ផ្នែកផ្សេងៗនៃការគ្រប់គ្រងត្រូវបានចែករំលែកក្នុងចំណោមអង្គភាពជាដៃគូ) | ● មានភាពចំរុះគ្នាច្រើននៅក្នុងកិរិតប្រតិបត្តិការ<br>● ចែករំលែកភាពជាម្ចាស់<br>● ចៀសផុតពីការគ្រប់គ្រងបែបប្រើអំណាច<br>● មានសេរីភាពច្រើនក្នុងការប្រតិបត្តិ<br>● ឱកាសច្រើនសំរាប់បុគ្គលនីមួយៗធ្វើជាអ្នកដឹកនាំ | ● មានសក្តានុពលជំលោះផលប្រយោជន៍ខ្ពស់<br>● ដៃគូ និង បុគ្គលម្នាក់ៗមានអារម្មណ៍ឯកោ<br>● ដំណើរការសំរេចចិត្តយឺត<br>● បាត់បង់ភាពប្រទាក់ក្រឡាគ្នា |
| គ្រប់គ្រងដោយមានអាណត្តិ<br>(ឧ. កិច្ចសន្យាការងារជាក់លាក់ចំពោះបុគ្គល ឬ អង្គភាពជាដៃគូណាមួយឱ្យទទួលខុសត្រូវចំពោះដៃគូទាំងអស់) | ● អភិក្រមមានភាពបត់បែនខ្ពស់ អាចធ្វើការពិនិត្យ និង ផ្លាស់ប្តូរតាមតំរូវការ<br>● ផ្តល់តួនាទីទៅអ្នកដែលមានពេលច្រើន (ឬ យកចិត្តទុកដាក់ខ្លាំងចំពោះការងារ)<br>● ចែករំលែកការងារក្នុងដៃគូ និង ជំរុញឱ្យមានការសហការទទួលខុសត្រូវ | ● តម្រូវឱ្យមានការកំណត់ និង បែងចែកការងារបានជាក់លាក់<br>● ពឹងផ្អែកខ្លាំងពេកទៅលើសកម្មភាពរបស់បុគ្គល<br>● ជួបហានិភ័យ ដោយសារបុគ្គល ឬ អង្គភាពជាដៃគូធ្វើការងារសំរាប់តែអង្គភាពខ្លួនឯងដោយមិនប្រឹក្សាជាមួយក្រុមដៃគូ |

## ប្រតិបត្តិល្អក្នុងការកសាងភាពជាដៃគូ

### ប្រើភាសាធ្វើជាឧបករណ៍សំរាប់កសាងភាពជាដៃគូ

របៀបដែលដៃគូប្រើប្រាស់ភាសាអាចបង្កើត ឬធ្វើឱ្យបែកបាក់ភាពជាដៃគូបាន ។ វិស័យនីមួយៗមានភាសាដោយឡែករបស់ខ្លួនដែលអាចធ្វើឱ្យមនុស្សមួយចំនួន (ដែលមិនដឹង) អាចយល់ខុសទាំងស្រុងចំពោះអត្ថន័យរបស់វា ។ ដៃគូត្រូវតែចាប់អារម្មណ៍ចំពោះការប្រើប្រាស់ភាសារបស់ខ្លួន (ប្រើប្រាស់តែភាសាណាដែលសមរម្យ ខ្លី និង ច្បាស់លាស់) ។ ជ្រើសរើសពាក្យល្អៗ ២ ឬ ៣ ម៉ាត់ សំរាប់ធ្វើទំនាក់ទំនង ប្រសើរជាងការប្រើពាក្យច្រើនដែលមិនច្បាស់ និង ច្របូកច្របល់ ។

ជ្រើសរើសពាក្យបានល្អ ដើម្បីប្រើជាឧបករណ៍សំរាប់ធ្វើឱ្យមានការយល់ស្របគ្នា ប្រសើរជាងការធ្វេសប្រហែសក្នុងការប្រើភាសាដែលនាំឱ្យកើតមានការបែកបាក់ ។ មានឧទាហរណ៍មួយចំនួនអំពីភាពខុសគ្នានៃការប្រើភាសានាពេលបច្ចុប្បន្ន :

| **អត្ថន័យដែលពិបាកសំរាប់ដៃគូ** | **ពាក្យដែលកសាងភាពជាដៃគូ** |
|---:|---|
| ទុកចិត្ត | តម្លាភាព |
| កំរៃ | គុណប្រយោជន៍ |
| គោលបំណងរួម | គោលបំណងបំពេញបន្ថែមឱ្យគ្នាទៅវិញទៅមក |
| កិច្ចសន្យា | កិច្ចព្រមព្រៀង |
| ផែនការធុរកិច្ច | ផែនការសកម្មភាព |
| ផ្តល់ហិរញ្ញប្បទាន | ផ្តល់ធនធាន |
| អាទិភាពតាមវិស័យ | គុណតំលៃតាមវិស័យ |
| គណៈកម្មការ | ក្រុមគោលដៅ ក្រុមការងារ |
| វាយតម្លៃ | ពិនិត្យឡើងវិញ |
| វិភាគទីផ្សារ | វិភាគវិសាលភាព |
| ការប្រឹក្សា | ការចូលរួម |
| យុទ្ធសាស្ត្រដកចេញ | យុទ្ធសាស្ត្រសំរាប់អនាគត |

ភាពខុសគ្នាកើតឡើងពីការយល់ដឹងរបស់យើង និង របៀបដែលយើងភ្ជាប់ទំនាក់ទំនងរបស់យើងជាមួយនឹងពិភពលោកខាងក្រៅ ។សមត្ថភាពក្នុងការចែកឱ្យដាច់ពីគ្នា គឺមានសារៈសំខាន់បំផុតសំរាប់ការកសាងភាពជាដៃគូប្រកបដោយប្រសិទ្ធភាព ។ វាផ្តល់ឱ្យមនុស្សនូវសេរីភាពក្នុងការគិត និង ធ្វើសកម្មភាពកាន់តែប្រសើរ និង នាំឱ្យមានជោគជ័យដ៏ត្រចះត្រចង់ចំពោះខ្លួនឯងផ្ទាល់ និង ចំពោះវិជ្ជាជីវៈ ។ ខាងក្រោមនេះ ជាឧទាហរណ៍មួយចំនួនសំរាប់អ្នកដែលធ្វើការក្នុងភាពជាដៃគូ :

### ធ្វើការជាមួយការពិត

សមត្ថភាពក្នុងការចែកឱ្យដាច់ពីគ្នារវាងការពិត និង អ្វីដែលគ្រាន់តែជាការសន្មត (បកស្រាយពីការពិត) ទាំងអស់នេះមានសារៈសំខាន់ណាស់ក្នុងស្ថានភាពបច្ចុប្បន្ននេះ ។ វាអាចធ្វើឱ្យខូចប្រយោជន៍ដល់ភាពជាដៃគូ ប្រសិនបើមនុស្សធ្វើសកម្មភាពផ្អែកតាមការកាត់យល់អំពីព្រឹត្តិការណ៍ណាមួយ ជាងផ្អែកតាមភស្តុតាងជាក់ស្តែងនៃព្រឹត្តិការណ៍នោះ ។

### បោះជំហានទៅមុខ មិនមែនបោះបង់ចោល

ការបោះបង់ចោលអាចកើតមានឡើងក្នុងដំណាក់កាលណាមួយនៃដំណើរការកសាងភាពជាដៃគូ ។ ជាការពិតការបោះបង់ចោល គឺជាផលវិបាកនៃដំណើរការដែលជួបនឹងការប្រឈម ។ ម្យ៉ាងទៀត ការបោះបង់ចោលអាចជាការបាក់ទឹកចិត្ត ហើយជាទូទៅ ត្រូវបានគេមើលឃើញថា ជាឧបសគ្គរាំងដែលពុំអាចជំនះបាន ។ ការបោះបង់ចោល មិនមែនសុទ្ធតែជារឿងអាក្រក់នោះទេ វាអាចគ្រាន់តែជាការរំខានមួយចំពោះដំណើរការដែលធ្វើឱ្យយើងពុំអាចសំរេចតាមអ្វីដែលចង់បាន ។ ការប្រឈមសំរាប់ភាពជាដៃគូ គឺត្រូវចាត់ទុកការការបោះបង់ចោលថាជាឱកាសដើម្បីបោះជំហានទៅមុខ ។

## សំណើ និង ការប្តឹងតវ៉ា

សំណើ គឺជាចរិតលក្ខណៈនៃគ្រប់ភាពជាដៃគូទាំងអស់ ។ ជាទូទៅ មនុស្សពុំបានលើកជាសំណើឱ្យបានគ្រប់គ្រាន់ទេ ប៉ុន្តែចូលចិត្តប្តឹងតវ៉ា ។ ពាក្យទាំងពីរនេះមានភាពខុសគ្នាខ្លាំងណាស់ ។ ការប្តឹងតវ៉ាធ្វើឱ្យមនុស្សមានការអាក់អន់ស្រពន់ចិត្ត ។ ដូច្នេះពួកគេពុំទទួលបាននូវការផ្តល់អំណាចទេ ហើយជាញឹកញាប់ធ្វើឱ្យពួកគេមានកំហឹងស្អប់គ្នា ច្រើនជាងខិតខំព្យាយាមដោះស្រាយបញ្ហា ។ ផ្ទុយមកវិញ សំណើបង្កើតឱ្យមានស្ថានការខុសពីមុនទាំងស្រុង ។ សំណើជំរុញឱ្យមានការឆ្លើយតប និង ធ្វើសកម្មភាព ។

## បង្កើតការសន្ទនាប្រកបដោយគុណភាពក្នុងការកសាងភាពជាដៃគូ

ភាពជាដៃគូ (ក្នុងកំរិតមួយ) គឺជាបណ្តាញនៃការសន្ទនា ។ គុណភាពនៃការសន្ទនារវាងដៃគូផ្សេងៗនឹងកំណត់ប្រសិទ្ធភាពជានៃភាពជាដៃគូ ។ នៅក្នុងការសន្ទនា ដៃគូបង្កើតអនាគត ។ ពួកគេរួមគ្នាបង្កើតនូវចក្ខុវិស័យមួយដែលពួកគេធ្វើដំណើរទៅ ។ គេពិភាក្សាអំពីជំហររបស់គេពីគណនេយ្យភាពចំពោះគ្នាទៅវិញទៅមក និង បង្កើតឱ្យមានការយល់ដឹងពីរបៀបដែលពួកគេអាចពឹងពាក់គ្នាទៅវិញទៅមក ។ ការសន្ទនា គឺជាឧបករណ៍មួយដ៏មានប្រសិទ្ធភាពសំរាប់បង្កើតឱ្យមានតម្លាភាព និង ទំនុកចិត្តក្នុងចំណោមដៃគូ ។ តាមរយៈការសន្ទនាបញ្ហានឹងត្រូវបានបម្លែងទៅជាឱកាស ហើយសកម្មភាពជាក់ស្តែងនឹងត្រូវបានបង្កើតឡើង ។

ឧបករណ៍ទី ៥ : គោលការណ៍ណែនាំសំរាប់ដៃគូសន្ទនាពិភាក្សាឱ្យបានល្អិតល្អន់អំពីសារប្រយោជន៍នៃការសន្ទនាប្រកបដោយភាពច្នៃប្រឌិត ដែលអាចជាមូលដ្ឋានគ្រឹះដ៏ល្អសំរាប់ការកសាងភាពជាដៃគូ

## គ្រប់គ្រងការប្រជុំបានល្អ

ភាពជាដៃគូ (ជាពិសេសក្នុងដំណាក់កាលដំបូង) ពឹងផ្អែកលើការជួបជុំគ្នារបស់មនុស្សក្នុងលក្ខណៈមួយទល់នឹងមួយ ឬក៏ជួបជាក្រុម ។ ការប្រជុំអាចក្លាយទៅជារឿងដដែលៗ មិនទទួលបានលទ្ធផល និង ងាយធុញទ្រាន់ប្រសិនបើគេមិនយកចិត្តទុកដាក់ និង គ្រប់គ្រងមិនបានល្អ ។ វាត្រូវការជំនាញជាក់លាក់មួយដើម្បីបង្កើតឱ្យមានបរិយាកាសល្អសំរាប់ការប្រជុំ និង ដើម្បីធានាថារាល់ការប្រជុំនឹង :

- សំរេចតាមគោលដៅ
- ធ្វើឱ្យដៃគូនីមួយៗសកម្មចូលរួមតាំងពីដើមរហូតដល់ចប់
- ធ្វើការបូកសរុបគ្រប់ចំណុចទាំងអស់នៃរបៀបវារៈ
- បែងចែកការងារសំរាប់តាមដាន និង ពេលវេលាសំរាប់បញ្ចប់ការងារ
- ព្រមព្រៀងគ្នាលើដំណើរការសំរេចចិត្ត ដែលនឹងអនុវត្តនៅក្នុងពេលប្រជុំនីមួយៗ
- រំលឹកនូវបញ្ហាដែលត្រូវពិភាក្សានៅក្នុងកិច្ចប្រជុំលើកក្រោយ
- ធ្វើការបូកសរុបនូវសេចក្តីសំរេចចិត្តទាំងអស់
- បញ្ចប់តាមម៉ោងដែលបានកំណត់

អភិក្រមល្អសំរាប់ការប្រជុំ (ទោះជាផ្លូវការ ឬ មិនផ្លូវការក្តី) នឹងនាំឱ្យយើងមានអារម្មណ៍ល្អ ផ្តល់តំលៃចំពោះការចូលរួម និង គោរពចំពោះភាពមមាញឹករបស់បុគ្គលម្នាក់ៗ ។

ការប្រជុំក៏អាចប្រើប្រាស់ធ្វើជាឧបករណ៍សំរាប់កសាងភាពជាដៃគូបានដែរ (តាមរយៈការបែងចែកការទទួលខុសត្រូវសំរាប់គ្រប់គ្រងកិច្ចប្រជុំដូចជាប្រធានអង្គប្រជុំ អ្នកសម្របសម្រួល និង អ្នកកត់ត្រា ជាដើម) ។

មធ្យោបាយផ្សេងទៀត ដើម្បីធ្វើឱ្យការប្រជុំមានន័យ និង រស់រវើក មានដូចខាងក្រោម :

- ផ្តល់ឱកាសឱ្យសមាជិកមានអន្តរអំពើជាមួយគ្នា
- ធ្វើការបំផុសគំនិត និង បញ្ហាថ្មីៗដែលកំពុងកើតមាននៅកន្លែងណាមួយ
- អញ្ជើញវាគ្មិនសំខាន់ៗមកចូលរួម
- ចែករំលែកបទពិសោធន៍ល្អៗ ។ ធ្វើទស្សនកិច្ចគំរោង ឬ បើកអង្គប្រជុំនៅអង្គភាពរបស់ដៃគូថ្មីណាមួយ ដើម្បីបានដឹងពីការងាររបស់គេតាំងពីចាប់ផ្តើមដំបូង ។
- ប្រើប្រាស់ការប្រជុំដើម្បីពង្រឹងការរៀនសូត្រ ដោយធ្វើការបញ្ចប់កិច្ចប្រជុំជាមួយនឹងការរំលឹកឡើងវិញនូវអ្វីដែលដំណើរការបានល្អ និង អ្វីដែលត្រូវធ្វើការកែលំអទាក់ទងនឹងអន្តរអំពើរបស់អ្នកចូលរួមទាំងអស់ ។

ប្រសិនបើវត្តមានចូលរួមប្រជុំរបស់ដៃគូមានការថយចុះ វាគឺជាសញ្ញាមួយបង្ហាញថាការប្រជុំមិនមានសារៈសំខាន់សំរាប់ដៃគូទៀតទេ (ត្រូវធ្វើការពិនិត្យវាស់វែងឱ្យបានហ្មត់ចត់) ។

### រក្សាទុកកំណត់ត្រា

ការរក្សាទុកកំណត់ត្រាការប្រជុំ និង កំណត់ត្រាភាពជឿនលឿននៃភាពជាដៃគូវាគឺជាភាពប៉ិនប្រសព្វមួយ ។ វាមិនមែនជាការល្អទេ ដែលឱ្យអ្នកដែលមានបទពិសោធន៍ក្មេងខ្ចីទទួលតួនាទីជាអ្នករក្សាទុកកំណត់ត្រា ។ ការប្រឈមធំបំផុតនោះគឺត្រូវពិចារណា តើគួរកត់ត្រាគ្រប់អ្វីៗទាំងអស់ ឬកត់ត្រាតែចំណុចសំខាន់ៗ ។ ដៃគូនីមួយៗត្រូវធ្វើការសំរេចចិត្តពីអ្វីដែលជាតម្រូវការ ។ ចំនុចមួយចំនួនដែលគួរពិចារណារួមមាន :

- សំរេចចិត្តឱ្យហើយជាមុន តើនរណាត្រូវការព័ត៌មានអ្វី ក្នុងទម្រង់បែបណា បន្ទាប់មកធ្វើការបន្សុំព័ត៌មានឱ្យសមស្របទៅតាមគោលបំណងទាំងអស់នោះ ។
- កាត់បន្ថយកំណត់ត្រាពីការប្រជុំ ដោយផ្តោតទៅលើតែ (ក) ការសំរេចចិត្ត (ខ) ផ្នែកដែលត្រូវធ្វើការពិភាក្សាបន្ត និង (គ) ចំណុចដែលបានព្រមព្រៀងគ្នា ។
- រក្សាកំណត់ត្រាប្រវត្តិនៃភាពជាដៃគូ (ទាំងសំណេរបរិយាយ និង រូបថត) ដើម្បីឱ្យដៃគូថ្មីៗអាចយល់ពីអ្វីដែលបានសំរេចហើយ និង ដោយរបៀបណា ។
- សំណេរកំណត់ត្រាផ្សេងៗ ត្រូវតែឱ្យដៃគូទាំងអស់អាចរកបាន ដើម្បីធ្វើឱ្យភាពជាដៃគូមានប្រសិទ្ធផល និង តម្លាភាព ។

### បង្កើតវប្បធម៌រៀនសូត្រ

អ្នកចូលរួមក្នុងភាពជាដៃគូភាគច្រើនព្រមព្រៀងគ្នាថា ភាពជាដៃគូដែលឋិតថេរ លុះត្រាណាតែគេបើកចិត្តទូលាយចំពោះការរៀនសូត្រពីកំហុសរបស់គេផ្ទាល់ និង ពីអ្នកដទៃ ។ ភាពជាដៃគូទាំងអស់ អាចត្រូវបានបង្កើតឡើងក្នុងទម្រង់នៃការ "រៀនសូត្រពីសកម្មភាព" ដែលដៃគូនីមួយៗរៀនពីអ្វីដែលគេកំពុងធ្វើ ។ ដើម្បីមើលឃើញសកម្មភាពទាំងអស់នៃភាពជាដៃគូថាមានលក្ខណៈជាការសិក្សាស្រាវជ្រាវ (បន្ថែមលើយន្តការដែលដំណើរការដើម្បីសំរេចការងារ) គឺត្រូវផ្តល់ឱកាសឱ្យដៃគូទាំងអស់ធ្វើការពង្រឹងចំណេះដឹង ជំនាញ និង ការអនុវត្តវិជ្ជាជីវៈរបស់គេឱ្យកាន់តែស៊ីជំរៅ និង ប្រសើរឡើង ។ កិច្ចសហប្រតិបត្តិការពិតប្រាកដធ្វើឱ្យដៃគូនីមួយៗមានមនសិការ : ដៃគូជួយគ្នាទៅវិញទៅមកឱ្យមានការរីកចំរើនទាំងចំពោះខ្លួនគេផ្ទាល់ និង ទាំងជំនាញវិជ្ជាជីវៈក្នុងខណៈដែលគេព្យាយាមធ្វើឱ្យសំរេចនូវគោលបំណងនៃភាពជាដៃគូ ។

បន្ថែមលើសនេះទៀត គ្រប់ដៃគូទាំងអស់នឹងត្រូវធ្វើការបង្រៀនដល់អ្នកផ្សេងៗទៀត ដែលចង់បង្កើតឱ្យមានអភិក្រមសហប្រតិបត្តិការ ដើម្បីធ្វើឱ្យដំណើរការអភិវឌ្ឍរបស់គេមាននិរន្តរភាព ។ ភាពជាដៃគូជាច្រើន (ទោះបីមើលទៅហាក់ដូចជាត្រូវបានបង្កើតឡើងយ៉ាងល្អក្តី) នឹងទទួលបានផលប្រយោជន៍ពីការចូលរួមជាមួយ "បណ្តាញរៀនសូត្រ" ដែលបានចែករំលែកបទពិសោធន៍ទាំងល្អ និង អាក្រក់ ។

### បង្កើតបទវិន័យ

បទវិន័យសាមញ្ញៗដែលព្រមព្រៀងរវាងដៃគូ អាចជាជំនួយដ៏សំខាន់ខណៈដែលភាពជាដៃគូនៅក្មេងខ្ចី ។ ដៃគូផ្សេងៗនឹងតម្រូវឱ្យធ្វើការធានាអះអាងចំពោះខ្លួនគេ និង របៀបរារៈការងាររបស់ពួកគេ ដែលនឹងផ្តល់នូវសេរីភាពចំពោះអ្នកដទៃ ។ ដៃគូខ្លះ ជាពិសេសមកពីផ្នែកឯកជន និង រដ្ឋាភិបាល អាចនឹងចាត់ទុកថាជារឿងចំឡែកចំពោះការមានបទវិន័យសំរាប់ការប្រព្រឹត្តិ ក៏ប៉ុន្តែសំរាប់ដៃគូដែលមកពីផ្នែកសង្គមស៊ីវិលនឹងគិតថា នេះជារឿងធម្មតា និង អាចទទួលយកបាន (សំរាប់ការជួបគ្នាជាលើកដំបូងរបស់វិស័យចំរុះ) ។

បទវិន័យអាចដាក់បញ្ចូលនូវចំនុចមួយចំនួន ដូចខាងក្រោម :

- ការចូលរួមស្តាប់យ៉ាងសស្រាក់សស្រាំ
- មិនរំខានអ្នកដទៃ
- និយាយសង្ខេបៗ ហើយចំគោលដៅ
- ផ្អែកលើការពិត មិនមែនជាពាក្យចចាមអារាម
- មានការគោរពចំពោះអ្នកដែលមិនបានចូលរួម

នៅដំណាក់កាលដំបូង ដៃគូត្រូវការរំលឹកគ្នាទៅវិញទៅមកអំពីបទវិន័យដែលបានព្រមព្រៀងគ្នា (វាត្រូវការពេលវេលាដើម្បីជំរុះចោលនូវទម្លាប់ប្រព្រឹត្តិមួយចំនួន) ប៉ុន្តែមួយរយៈពេលក្រោយមកទៀត ភាពជាដៃគូនឹងទទួលយកនូវវិធីសាស្ត្រថ្មីៗដោយខ្លួនឯង ហើយបទវិន័យនោះនឹងប្រើដើម្បីគ្រាន់តែធ្វើការរំលឹកដោយទន់ភ្លន់តែប៉ុណ្ណោះ ។ ដៃគូថ្មីៗងាយនឹងសម្រប ខ្លួនជាមួយនឹងការផ្លាស់ប្តូរការប្រព្រឹត្តិដែលគេមើលឃើញថាមានដំណើរការល្អ ។

បទវិន័យអាចសរសេរក្នុងកិច្ចព្រមព្រៀងការកសាងភាពជាដៃគូ ។

**ចំណាំ**

ភាពជាដៃគូនឹងមានដំណើរការល្អនៅពេលដែល :

- មានពិធីសារនៃដំណើរការសំរេចចិត្តច្បាស់លាស់ដែលបានព្រមព្រៀងគ្នា និង ចូលជាធរមាន
- ការសំរេចចិត្តចំពោះការងារប្រចាំថ្ងៃ គឺធ្វើឡើងដោយបុគ្គល ឬ ក្រុមតូចដែលតំណាងឱ្យភាពជាដៃគូ ។
- មានតែការសំរេចចិត្តសំខាន់ៗ (ឧ. គោលនយោបាយ ឬ ការចំណាយធំៗ) ប៉ុណ្ណោះ ដែលត្រូវធ្វើនៅក្នុង ដៃគូក្រុមធំ
- មានការចែករំលែកយ៉ាងទៀងទាត់នូវព័ត៌មានខ្លីៗ និង ច្បាស់លាស់រវាងដៃគូនីមួយៗ



# ៩ ការអនុវត្តគំរោងប្រកបដោយជោគជ័យ

## គ្រប់គ្រងអន្តរកាល

ខណៈដែលភាពជាដៃគូបានបង្កើតឡើង និង កិច្ចព្រមព្រៀងភាពជាដៃគូក៏បានបង្កើតរួចរាល់ហើយដែរ ដៃគូនឹងងាកទៅធ្វើការចាប់អារម្មណ៍លើការអភិវឌ្ឍគំរោង កម្មវិធី ឬ សកម្មភាពរួមគ្នារបស់ពួកគេ ។ នេះជាដំណាក់កាលដែលភាពជាដៃគូចាប់ផ្តើមចុះធ្វើការងារ ហើយជាចំណុចអន្តរកាលយ៉ាងសំខាន់ ដែលគេផ្លាស់ប្តូរការយកចិត្តទុកដាក់ពីការបង្កើតភាពជាដៃគូទៅជាការបង្កើត និង អនុវត្តគំរោង ។ ដៃគូខ្លះមានភាពកក់ក្តៅនៅក្នុងដំណាក់កាលនេះ ពីព្រោះគេចូលចិត្តអនុវត្តការងារជាក់ស្តែង ហើយប្រហែលជាធុញទ្រាន់ចំពោះដំណាក់កាលមុននេះបន្តិច ។ ដៃគូខ្លះមានការខ្វល់ខ្វាយដោយសារភាពជាដៃគូនៅមិនទាន់រឹងមាំល្មមនឹងឱ្យគេឈានពីការជជែកទៅធ្វើជាសកម្មភាព ។

គ្រប់គំរោងទាំងអស់ គួរយកចិត្តទុកដាក់គ្រប់ចំនុចលំអិត និង ត្រូវធ្វើផែនការសកម្មភាពឱ្យបានច្បាស់លាស់ដើម្បីផ្តល់ជាគ្រោងការណ៍ និង សូចនាករ ដែលគ្រប់គ្នាអាចព្រមព្រៀង ( សូមមើលប្រអប់ ៥ ទំព័រ ២៨) ។

នៅក្នុងដំណាក់កាលនេះ ជាការសំខាន់ត្រូវពិនិត្យមើលឡើងវិញអំពីរបៀបគ្រប់គ្រងភាពជាដៃគូ និង ធ្វើការកែសំរួលវាប្រសិនបើចាំបាច់ ( មើលប្រអប់ ៤ ទំព័រ ២២) ។

## ផ្តោតលើការងារ

ភាពជាដៃគូដែលមានជោគជ័យបំផុត គឺដៃគូដែលផ្តោតលើការងារខ្ពស់បំផុត ដែលគ្រប់ដៃគូទាំងអស់សកម្មជាមួយនឹងការបំពេញការងារ និង ទទួលបានលទ្ធផលជាក់ស្តែង ។ ក្នុងចំណុចនេះ អ្នកសម្របសម្រួល ឬ ប្រធានគំរោង អាចនឹងត្រូវបានតែងតាំងដើម្បីចាត់ចែងគ្រប់គ្រងគំរោងជំនួសឱ្យដៃគូ ដែលមិនមានពេលវេលាមកធ្វើការងារនេះជាប្រចាំថ្ងៃ ។ បុគ្គលនោះត្រូវយល់អំពីដំណើរការការងារទាំងមូល និង ធានាថាបុគ្គលិកគំរោង និង ដៃគូសំរេចបានយ៉ាងល្អ និង ទាន់ពេលវេលានូវអ្វីដែលគេបានតាំងចិត្ត ។ នេះ គឺជារង្វាស់មួយសំរាប់វាស់ពីភាពរីកចំរើនរបស់ដៃគូចំពោះការជឿទុកចិត្តគ្នាទៅវិញទៅមក ប្រសិនបើគេមិនចាំបាច់ធ្វើការពិនិត្យលើការងារលំអិតប្រចាំថ្ងៃ និង ដោយមានទំនុកចិត្តថាការងារនៅក្នុងកម្មវិធីភាពជាដៃគូដែលបានបង្កើតឡើងកំពុងប្រតិបត្តិដោយរលូន ។

## ការរាយកាណ៍ ការពិនិត្យមើលឡើងវិញ និង ការកែតំរូវ

ឧបករណ៍ទី ៦
ទម្រង់ពិនិត្យមើលឡើងវិញអំពីភាពជាដៃគូ : ផ្តល់នូវវិធីសាស្ត្រជាច្រើនដើម្បីពិនិត្យមើលឡើងវិញនូវអភិក្រមនៃភាពជាដៃគូដោយផ្អែកលើទិសដៅនៃការធ្វើការពិនិត្យឡើងវិញ ។

ខណៈពេលដែលគំរោង ឬ កម្មវិធីការងារកំពុងដំណើរការ ដៃគូអាចសំរេចចិត្តកាត់បន្ថយការជួបគ្នាកុំឱ្យញឹកញាប់ពេក ហើយនៅពេលចាំបាច់ ពួកគេជួបគ្នាគ្រាន់តែដើម្បីធ្វើការពិនិត្យមើលឡើងវិញលើប្រតិបត្តិការតែប៉ុណ្ណោះ ។ របាយកាណ៍ជាប្រចាំ ត្រូវការជាចាំបាច់ដើម្បីធានាថា ដៃគូបានផ្តល់ដំណឹងពីភាពជឿនលឿននៃការងារ និង ការប្រឈមដែលគេជួប ។ របាយការណ៍ជាសំណេរ ឬផ្ទាល់មាត់អាចប្រើធ្វើជាមូលដ្ឋានដើម្បីធ្វើការរំលឹកវាយតំលៃទាំងគំរោង និង ភាពជាដៃគូខ្លួនឯងផងដែរ ( សូមមើលផ្នែកទី ៧) ។ ដៃគូអាចធ្វើការពិនិត្យកិច្ចព្រមព្រៀងរបស់គេឡើងវិញ ( អាចធ្វើ ១ ឆ្នាំម្តង) និង បើចាំបាច់អាចធ្វើការកែសំរួលដើម្បីឱ្យត្រូវតាមអាទិភាព និង បំណងប្រាថ្នាថ្មីៗ ។

# ប្រអប់ ៥ ផែនការសកម្មភាព

ផែនការសកម្មភាព ( ពេលខ្លះគេហៅថាផែនការអភិវឌ្ឍ ឬ ផែនការធុរកិច្ច) គឺជាដំណើរការមួយទទួលស្គាល់ដោយអ្នកមានវិជ្ជាជីវៈភាគច្រើន និង មានអភិក្រមការងារច្រើន ។ ក្នុងភាពជាដៃគូ វាមានសារៈសំខាន់ដែលត្រូវចងចាំថា :

- គ្រប់ដៃគូទាំងអស់ ត្រូវតែចូលរួមក្នុងដំណើរការធ្វើផែនការសកម្មភាព ដើម្បីឱ្យមានការតាំងចិត្ត និង ភាពជាម្ចាស់ ។
- ដៃគូនីមួយៗនឹងនាំមកនូវជំនាញ និង ការរំពឹងទុកចំពោះការងារផ្សេងៗគ្នា ។ ការគ្រប់គ្រងភាពទីទៃពីគ្នានេះអាចចំណាយពេលវេលាច្រើន ក៏ប៉ុន្តែវាមានចំណុចពិសេសរបស់វា គឺវានឹងបន្ថែមនូវគុណតំលៃដែលអាចពិចារណា ។
- ដៃគូនីមួយៗត្រូវធ្វើការពិចារណា អំពីឥទ្ធិពលទៅលើផែនការសកម្មភាពសំរាប់អង្គភាពរបស់គេ និង ទៅលើដំណើរការធ្វើផែនការសកម្មភាព និង អាទិភាពក្នុងអង្គភាពរបស់គេផ្ទាល់ ។

## គំរូការធ្វើគំរោងផែនការសកម្មភាព




**ចំណាំ**

ផែនការសកម្មភាពជាចំណុចសំខាន់សំរាប់ភាពជាដៃគូ : នៅពេលដែលទំនាក់ទំនងភាពជាដៃគូត្រូវបានបង្កើតឡើង ហើយចំណាប់អារម្មណ៍បានប្តូរពីការបង្កើតភាពជាដៃគូ ទៅផ្តោតការយកចិត្តទុកដាក់លើការបង្កើត និង អនុវត្តកម្មវិធីរួមគ្នា ។ វាជារឿងសំខាន់ណាស់ ដែលយើងត្រូវធ្វើវាឱ្យបានល្អ បើមិនដូច្នេះទេវានឹងអន្តរាយដល់ភាពជាដៃគូ ។

# ៦ និរន្តរភាពក្នុងការកសាងភាពជាដៃគូ

## រៀបចំផែនការសំរាប់រយៈពេលយូរ

ការប្រឈមដ៏ធំមួយចំពោះនិរន្តរភាពនៃភាពជាដៃគូ គឺធនធានសំរាប់រយៈពេលយូរ ។ ស្ថានភាពនីមួយៗនឹងមានតម្រូវការធនធានផ្សេងៗគ្នា ហើយការផ្តួចផ្តើមមួយចំនួនច្រើនតែពឹងផ្អែកលើហិរញ្ញប្បទានពីខាងក្រៅ ។ ទោះជាយ៉ាងណាក្តី ប្រសិនបើអាចធ្វើបាន គួរត្រៀមរៀបចំឱ្យមានរួចជាស្រេចនូវធនធាននៅក្នុងមូលដ្ឋាន និង ធនធានដែលអាចប្រើប្រាស់សាជាថ្មីឡើងវិញ ។ មានករណីជាច្រើន ដៃគូអនុវត្តន៍គំរោងក្នុងស្មារតីជាអ្នកត្រួសត្រាយផ្លូវ ហើយនៅពេលដែលការផ្តួចផ្តើមរបស់គេបានបង្ហាញថាមានប្រសិទ្ធភាព គេនឹងរៀបចំធ្វើវាឱ្យទៅជាអចិន្ត្រៃយ៍ជាមួយនឹងស្ថាប័នផ្សេងៗទៀត ឧទាហរណ៍ដូចជា : រដ្ឋាភិបាលមូលដ្ឋាន ឬ ភ្នាក់ងាររដ្ឋាភិបាលជាដើម ។

ដៃគូ (ម្នាក់ៗ និង ច្រើននាក់) ត្រូវមានយុទ្ធសាស្ត្ររំកិលទៅមុខនៅក្នុងគំនិត (គួរតែគិតចាប់តាំងពីគ្រាដំបូងទៅ និងអាចបញ្ចូលទៅក្នុងកិច្ចព្រមព្រៀងដំបូងនៃការកសាងភាពជាដៃគូ) ។ អាចមានសេណារីយ៉ូចំនួនបួនសំរាប់រំកិលទៅមុខ :

| សេណារីយ៉ូរំកិល | យោបល់ |
|---|---|
| **អង្គភាពដៃគូចាកចេញពីភាពជាដៃគូ** | គ្រប់ភាពជាដៃគូនឹងមានបញ្ហានៃការស្នងដំណែង (ដំណើរការផ្ទេរពីស្ថាបនិកទៅអ្នកជំនាន់ក្រោយ) ។ ម្នាក់ៗអាចលាចេញពីភាពជាដៃគូ (ទោះក្នុងហេតុផលអ្វីក៏ដោយ) បានគ្រប់ពេល ។ ដូច្នេះកាធ្វើផែនការសំរាប់ស្នងដំណែង គឺជារឿងសំខាន់ ដើម្បី :<br>• ធានាថា ភាពជាដៃគូនៅតែមានជីវិត ទោះបីមានការចាកចេញរបស់សមាជិក<br>• ជួយឱ្យអ្នកចំណូលថ្មីអាចទទួលយក និង ចុះសម្រុងបានឆាប់រហ័ស<br>• បញ្ចូលអ្នកដែលទើបចូលថ្មី ដែលសកម្មក្នុងការចូលរួមក្នុងបញ្ជី ទោះបីជាបែបបទប្រតិបត្តិរបស់ពួកគេអាចខុសពីបុព្វការីរបស់គេក៏ដោយ ។ |
| **ភាពជាដៃគូ បែកខ្ញែក (១)** | ដៃគូអាចធ្វើការសំរេចចិត្តថា អង្គភាពដៃគូណាសមនឹងធ្វើជាអ្នកគ្រប់គ្រង និង អភិវឌ្ឍន៍កម្មវិធីការងារបានដោយឯករាជ្យ ។ ក្នុងករណីនេះ ដៃគូនឹងយល់ព្រមធ្វើការផ្ទេរការងារ និង ទ្រព្យសកម្មទៅអង្គភាពដៃគូនោះ ។ ប្រហែលជាអាចមានតំណាងមកពីអង្គភាពដៃគូផ្សេងៗធ្វើជាក្រុមប្រឹក្សាភិបាល ឬ ទីប្រឹក្សា ប៉ុន្តែការទទួលខុសត្រូវមិននៅក្រោមភាពជាដៃគូទៀតទេ ។ |
| **ភាពជាដៃគូ បែកខ្ញែក (២)** | ដៃគូសំរេចចិត្តបង្កើតស្ថាប័នអន្តរវិស័យថ្មីមួយ ដើម្បីទទួលខុសត្រូវគ្រប់គ្រង និង អភិវឌ្ឍភាពជាដៃគូ ។ មានជម្រើសមួយចំនួន (ក្នុងប្រអប់ ៦) ហើយដៃគូអាចត្រូវការជំនួយពីខាងក្រៅដើម្បីជ្រើសរើសជម្រើសដែលសក្តិសមបំផុត ។ ដូចខាងលើដែរ តំណាងមកពីអង្គភាពដៃគូផ្សេងៗ អាចធ្វើជាក្រុមប្រឹក្សាភិបាល ឬ ទីប្រឹក្សា (ជាពិសេស នៅក្នុងដំណាក់កាលផ្ទេរ) ។ |
| **ភាពជាដៃគូ ត្រូវបានបញ្ចប់** | ជោគជ័យមួយចំនួន និង ភាពច្នៃប្រឌិតក្នុងការផ្តួចផ្តើមភាពជាដៃគូមួយចំនួន ត្រូវបានរៀបចំឡើងមានលក្ខណៈជា "បណ្តោះអាសន្ន" ដូច្នេះការចាកចេញនៃដៃគូ គឺជាសញ្ញាប្រាប់ពីជោគជ័យជាងបរាជ័យ (ទោះបីមានការពិបាកក្នុងការធ្វើឱ្យអ្នកខាងក្រៅជឿក៏ដោយ) ។ ក្នុងករណីខ្លះភាពជាដៃគូត្រូវបញ្ចប់ដោយចៀសមិនរួច ពីព្រោះវាមិនអាចសំរេចគោលដៅ ទោះក្នុងហេតុផលអ្វីក៏ដោយ ។ ជំហានណែនាំក្នុងសៀវភៅនេះ មិនតម្រូវឱ្យអនុវត្តតាមទាំងអស់ទេ ។ នៅពេលភាពជាដៃគូបញ្ចប់ (ទោះក្នុងហេតុផលអ្វីក៏ដោយ) ចាំបាច់ឱ្យអ្នកចូលរួមទាំងអស់ទទួលស្គាល់ និង អបអរសាទរចំពោះផលសំរេច ។ |

## ធានាការចូលរួមកាន់តែប្រសើរ

ដៃគូខិតខំប្រឹងប្រែងធ្វើការងារ ដើម្បីធានាឱ្យមានការចូលរួមកាន់តែប្រសើរឡើងពីអង្គភាពជាដៃគូ និង ពីអង្គភាពដែលមិនមែនជាដៃគូផងដែរ ។

ជាមួយនឹងអង្គភាពជាដៃគូ វាជារឿងធម្មតាក្នុងការយកឈ្មោះអង្គភាពណាមួយធ្វើជាឈ្មោះរបស់ភាពជាដៃគូសំរាប់ប្រតិបត្តិការការងារ ។ ហេតុអ្វីបានជាទង្វើនេះអាចក្លាយជាបញ្ហា ? ការដែលមិនបានឱ្យអង្គភាពជាដៃគូចូលរួម អាចមានន័យថា (ក្នុងន័យល្អ) ខ្វះភាពស្វាហាប់ និង ខ្វះការចូលរួមពេញលេញពីអង្គភាពហើយ (ក្នុងន័យអាក្រក់) គឺជាការធ្លាក់ចុះនៃទំនាក់ទំនងភាពជាដៃគូ ប្រសិនបើអ្នកចូលរួមសំខាន់ៗមួយ ឬ ពីរចាកចេញ ។ ប្រហែលជាការចូលរួមដ៏សកម្មរបស់អង្គភាពជាដៃគូមានសារៈសំខាន់ជាងការដែលគ្រាន់តែធ្វើឱ្យគេទទួលស្គាល់ ។

ចុះស្ថាប័នដែលមិនមែនជាដៃគូវិញយ៉ាងម៉េចដែរ ?

មានស្ថាប័ន ឬ ភ្នាក់ងារជាច្រើន ដែលភាពជាដៃគូមានសារៈសំខាន់ចំពោះពួកគេ និង ត្រូវការយល់ដឹង និង ចូលរួមជាមួយនឹងដៃគូតាមមធ្យោបាយជាច្រើន រួមមាន ៖

- ស្ថាប័នដែលប្រតិបត្តិការក្នុងកំរិតយុទ្ធសាស្ត្រ និង គោលនយោបាយ
  (ឧ. នាយកដ្ឋាននានារបស់រដ្ឋាភិបាល គណបក្សនយោបាយ ទីភ្នាក់ងារអន្តរជាតិ)
- អង្គភាពដែលនៅកំរិតប្រតិបត្តិ
  (ឧ. ក្រុមហ៊ុនផ្សេងៗ ទីភ្នាក់របស់រដ្ឋាភិបាល និង អង្គការសង្គមស៊ីវិល)
- ស្ថាប័នផ្តល់ហិរញ្ញប្បទាន (អ្នកនៅខាងក្រៅដែលផ្តល់ធនធានដល់ភាពជាដៃគូ)

ដៃគូនឹងត្រូវការធ្វើការប៉ាន់ប្រមាណពីសារៈសំខាន់នៃទំនាក់ទំនងខុសៗគ្នាទាំងអស់នោះ ដោយផ្អែកលើលក្ខខណ្ឌនៃការជួយជំរុញឱ្យភាពជាដៃគូកាន់តែមានផលប៉ះពាល់ខ្លាំង ឬ ក្នុងលក្ខខណ្ឌនៃការធ្វើឱ្យភាពជាដៃគូ មានឥទ្ធិពលនៅក្នុងការប្រតិបត្តិការការងារ ។

## កសាងសមត្ថភាពស្ថាប័ន

តើដៃគូជួយកសាងសមត្ថភាពស្ថាប័នដែលចូលរួមដោយរបៀបណា ? នេះ គឺជាសំណួរមួយដែលជួយឱ្យគេបញ្ជ្រាបមេរៀនភាពជាដៃគូចូលទៅក្នុងស្ថាប័ន ។ ពេលខ្លះវាគ្រាន់តែមានបញ្ហាជាមួយនឹងពេលវេលា ក៏ប៉ុន្តែជាញឹកញាប់ វាគឺជាការតស៊ូជាមួយនឹងភាពសកម្ម ឬ អសកម្មនៃការមិនទទួលយក ។ មានអភិក្រមច្រើនដែលដៃគូអាចប្រើប្រាស់ ដើម្បីកសាងសមត្ថភាពស្ថាប័នឱ្យកាន់តែប្រសើរឡើងនៅក្នុងស្ថាប័ន ឬ អង្គភាពដែលបានចូលរួមដោយផ្ទាល់ ឬ ដោយប្រយោលនៅក្នុងភាពជាដៃគូ ។ អភិក្រមទាំងនេះ រួមមានការដាក់បញ្ចូលនូវបទពិសោធន៍សហប្រតិបត្តិការអន្តរវិស័យទៅក្នុងស្ថាប័នដើម្បីកសាង :

| | |
|---|---|
| **ការផ្លាស់ប្តូរវប្បធម៌ក្នុងអង្គភាព** | • បង្ហាញថាអង្គភាពផ្សេងៗទៀតធ្វើការងារតាមរបៀបខុសពីយើង (ហើយពេលខ្លះ មានប្រសិទ្ធភាពជាងយើង)<br>• ផ្តល់ភស្តុតាងបញ្ជាក់ពីតំលៃនៃអង្គភាពមួយដែលមានវប្បធម៌រៀនសូត្រ<br>• លើកកំពស់អភិក្រមអង្គភាពផ្អែកលើគុណតំលៃ<br>• បញ្ចុះបញ្ចូលអ្នកគ្រប់គ្រងឱ្យជឿថា អភិក្រមនៃការចូលរួមអាចធ្វើឱ្យការងារមានប្រសិទ្ធផល |
| **ការអភិវឌ្ឍធនធានមនុស្ស** | • បង្ហាញថាកិច្ចសហប្រតិបត្តិការអន្តរវិស័យ អាចជួយធ្វើឱ្យប្រសើរឡើងនូវការអនុវត្តតាមវិជ្ជាជីវៈ<br>• ឱ្យនិយោជិតចូលរួមធ្វើសកម្មភាពនៅក្នុងការផ្តួចផ្តើមឱ្យមានភាពជាដៃគូ<br>• បញ្ចុះបញ្ចូលអ្នកគ្រប់គ្រងឱ្យជឿថា អង្គភាពអាចទទួលប្រយោជន៍ពីការចូលរួមរបស់និយោជិតនៅក្នុងកិច្ចសហប្រតិបត្តិការអន្តរវិស័យ |
| **បណ្តាញប្រកបដោយថាមពល** | • បង្ហាញនូវតំលៃចំពោះអង្គភាពដែលបង្កើតទំនាក់ទំនងថ្មីៗ ភាពចំរុះគ្នា និង ការជះឥទ្ធិពលរបស់ពួកគេ<br>• បង្ហាញពីសក្តានុពលសំរាប់ទំនាក់ទំនងថ្មី គំនិត និង ផ្នែកការងារ<br>• យកគន្លឹះសំខាន់ៗមកក្នុងអង្គភាពតាមបែបច្នៃប្រឌិត និង មានប្រយោជន៍ |
| **ការប្រាស្រ័យទាក់ទងកាន់តែប្រសើរ** | • គាំទ្រអង្គភាពតាមរយៈការផ្សព្វផ្សាយជាសាធារណៈនូវជោគជ័យនៃភាពជាដៃគូ<br>• ប្រើប្រាស់ប្រព័ន្ធប្រាស្រ័យទាក់ទងក្នុងអង្គភាព ដើម្បីធ្វើឱ្យមនុស្សបានចូលរួម និង ផ្តល់ព័ត៌មាន<br>• បង្កើតព្រឹត្តិការណ៍ពិសេស ដើម្បីឱ្យអ្នកដទៃទៀតបង្ហាញពីផលប្រយោជន៍នៃភាពជាដៃគូ (ជាពិសេសទៅដល់អង្គភាពដែលនៅមានការសង្ស័យ) |
| **ឱកាសក្នុងការចេញពីប្រអប់** | • ផ្តល់ឱកាសឱ្យអ្នកចូលរួមសំខាន់ៗទទួលបាននូវបទពិសោធន៍ដោយផ្ទាល់ និង មុនគេបង្អស់អំពីការងារនៃភាពជាដៃគូ<br>• បង្កើត និង គ្រប់គ្រងការជួបគ្នារវាងមនុស្សសំខាន់ៗដែលមិនធ្លាប់បានជួប (និង អាចមានកំណត់ត្រានូវការមិនពេញចិត្តចំពោះគ្នា ឬ មន្ទិលសង្ស័យ)<br>• បង្កើតឱ្យមានឱកាស "បានរៀនសូត្រពីបទពិសោធន៍"<br>(ឧ. ផ្លាស់ប្តូរការងារ ធ្វើជាអ្នកហាត់ការ សិក្ខាសាលាអំពីភាពជាដៃគូ) |

ក្នុងស្ថានភាពខ្លះ ការបង្កើតនូវស្ថាប័នថ្មីមួយប្រហែលជាសមស្រប ដើម្បីអនុវត្តន៍តួនាទីទាំងអស់នៃភាពដៃគូក្នុងរយៈពេលមធ្យម និង វែង (ប្រអប់ ៦ ទំព័រ ៣២ ពិពណ៌នាពីប្រភេទទាំង៧នៃ "ស្ថាប័ន" ជាដៃគូដែលបានវិវត្តក្នុងទសវត្សរ៍ចុងក្រោយនេះ : បង្កើតឱ្យមានទំរង់ខុសគ្នាតិច ឬ ច្រើននូវគំរូនៃការចូលរួមអន្តរវិស័យដូចដែលបានបង្ហាញក្នុងប្រអប់ ៣ ទំព័រ ១៦) ។

# ប្រអប់ ៦ ការកសាងស្ថាប័នដៃគូថ្មី

| ប្រភេទ | លក្ខណៈសម្បត្តិ | ចំណុចខ្លាំង |
|---|---|---|
| **បណ្តាញមូលដ្ឋាន** | ដៃគូដែលមកពីវិស័យសំខាន់ៗផ្តល់សមធម៌ក្នុងការចូលរួម និង ទទួលខុសត្រូវក្នុងការសំរេចចិត្ត ក្នុងរចនាសម្ព័ន្ធផ្លូវការមួយ ដែលប្រតិបត្តិដោយឯករាជ្យនៅក្នុងមូលដ្ឋាន | ● អ្នកមូលដ្ឋានមានភាពជាម្ចាស់ខ្ពស់ និង ស្គាល់ខ្លួនឯង<br>● កសាង និង ធ្វើឱ្យស្ថាប័នមូលដ្ឋានសហប្រតិបត្តិការ |
| **បណ្តាញសកល** | ដូចខាងលើដែរ ក៏ប៉ុន្តែប្រតិបត្តិក្នុងកំរិតអន្តរជាតិ | ● ថ្លឹងថ្លែងសេដ្ឋកិច្ច<br>● កសាងយុទ្ធសាស្ត្រផ្សាភ្ជាប់រវាងអ្នកចូលរួម ដែលនាំមកនូវអំណាច ធនធាន និង ឥទ្ធិពល |
| **បែកខ្ញែក** | ដៃគូបានព្រមព្រៀងគ្នាលើទិសដៅរួម តែគេពុំសូវបានជួបមុខគ្នា ។ ជំនួសមកវិញ គេប្រតិបត្តិដោយដៃគូផ្សេង (ឬ ក្រុមតូច) ដែលត្រូវបានតែងតាំងឱ្យបំពេញភារកិច្ច តំណាងឱ្យភាពជាដៃគូប្រកបដោយគណនេយ្យភាព | ● មានភាពបត់បែនខ្ពស់<br>● សេរីភាពក្នុងប្រតិបត្តិការ និង ដៃគូស្គាល់ខ្លួនឯង |
| **បណ្តោះអាសន្ន** | រចនាសម្ព័ន្ធភាពជាដៃគូត្រូវបានរៀបចំឡើង ដើម្បីប្រើតែមួយរយៈ ។ វាបានកំណត់ពេលជាក់លាក់ ហើយត្រូវបានគេឈប់ប្រើខណៈដែលកម្មវិធីការងារ ដែលបានព្រមព្រៀងគ្នាត្រូវបានបញ្ចប់ ។ | ● មានការចូលរួមអស់ពីកំលាំងកាយចិត្ត<br>● ផ្តោតលើលទ្ធផលរយៈពេលខ្លី និង ដែលមើលឃើញជាក់ស្តែង |
| **ប្រឹក្សាយោបល់** | កិច្ចការងាររបស់ស្ថាប័នដៃគូ គឺផ្តល់យោបល់ ឬ គំនិតថ្មីៗ ជាងការបង្កើត និង អនុវត្តគំរោង | ● បំពេញបន្ថែមលើដំណើរការនយោបាយ<br>● សិទ្ធិអំណាចបានមកពីការឯកភាពគ្នា មិនមែនផ្អែកលើអំណាចបុគ្គល |
| **អន្តរការី** | អង្គភាពមួយដែលប្រតិបត្តិជំនួសឱ្យដៃគូ និង អ្នកចូលរួមផ្សេងៗទៀត ។ ជាការសំខាន់ គេជួយគាំទ្រដល់ការផ្តួចផ្តើម បង្កើតភាពជាដៃគូដោយឯករាជ្យ ជាងការធ្វើឱ្យខ្លួនឯង ក្លាយទៅជាដៃគូ | ● គំរូនៃការផ្តល់អំណាចកំរិតខ្ពស់<br>● ជួយកសាងវប្បធម៌សហប្រតិបត្តិការ<br>● បង្កើតរចនាសម្ព័ន្ធគាំទ្របានសមរម្យ និង មានភាពបត់បែន |
| **ការរៀនសូត្រ** | ភាពជាដៃគូបានបង្កើតឡើងជាមួយនឹងគោលដៅចំបង គឺការរៀនសូត្រ និង ចែករំលែកព័ត៌មាន ដែលបានមកពីបទពិសោធន៍នៃភាពជាដៃគូ | ● បត់បែន<br>● កសាងចំណេះដឹង និង សមត្ថភាពជាទិសដៅដ៏ចំបង |

ដូច្នេះ ដៃគូត្រូវធ្វើការបកស្រាយថា តើកិច្ចខិតខំប្រឹងប្រែងរបស់គេមានភាពវិសេសវិសាល សំរាប់ភ្ជាប់ទំនាក់ទំនងស្ថាប័នផ្សេងៗយ៉ាងមានប្រសិទ្ធភាព សំរាប់កសាងសមត្ថភាពស្ថាប័នដែលមានស្រាប់ ឬ បង្កើតរចនាសម្ព័ន្ធស្ថាប័នថ្មី ។ តាមពិត ភាពជាដៃគូអាចធ្វើកិច្ចការទាំងបីនៅក្នុងកំឡុងពេលណាមួយ ។

ទីបញ្ចប់ វាអាចក្លាយជាសំណួរនៅជុំវិញកំណែទម្រង់ស្ថាប័ន ។

យើងងាកមករកភាពជាដៃគូអន្តរវិស័យ ដើម្បីបង្កើតអភិក្រមមួយ ឈានទៅរកការអភិវឌ្ឍប្រកបដោយនិរន្តរភាពដែលមានការច្នៃប្រឌិត និង បំរើឱ្យសង្គម សេដ្ឋកិច្ច និង បរិដ្ឋាន ជាងអភិក្រមដែលបំរើឱ្យវិស័យតែមួយ ។ក៏ប៉ុន្តែ ប្រសិនបើភាពជាដៃគូបរាជ័យចំពោះការប្រឈម និង រារាំងចំពោះការផ្លាស់ប្តូរក្នុងស្ថាប័ន ឬ អាកប្បកិរិយារបស់វិស័យណាមួយនោះ ផលប៉ះពាល់របស់វាប្រហែលជាគ្រាន់តែបានសើរៗ និង ពុំបានឋិតថេរឡើយ ។

ក្នុងដំណាក់កាលខ្លះ វាបង្ហាញច្បាស់ថាភាពជាដៃគូដើរតួនាទីដ៏សំខាន់ក្នុងប្រតិបត្តិការដោយផ្ទាល់ឬប្រយោល ក្នុងការសើររើឡើងវិញ និង កែសំរួលគុណតំលៃរួម តួនាទី និង សកម្មភាពចំបងៗនៃវិស័យខុសៗគ្នា (រដ្ឋាភិបាល ផ្នែកឯកជន និង សង្គមស៊ីវិល) ។

កំណែទម្រង់ស្ថាប័ន អាចជាលទ្ធផលយ៉ាងសំខាន់ក្នុងភាពជាដៃគូជាងអ្វីៗផ្សេងទៀត ។ ម្យ៉ាងវិញទៀត ប្រសិនបើភាពជាដៃគូអាចធ្វើឱ្យនាយកដ្ឋានរបស់រដ្ឋាភិបាលមានដំណើរការកាន់តែមានភាពច្នៃប្រឌិត និង មានប្រសិទ្ធភាព ឬក៏ធ្វើឱ្យក្រុមសាជីវកម្មចែករំលែកកាន់តែខ្លាំងក្លា និង ជាប្រព័ន្ធ ឆ្ពោះទៅរកការអភិវឌ្ឍប្រកបដោយនិរន្តរភាពក្នុងគ្រប់វិស័យដែលគេប្រតិបត្តិ ឬ ក៏ធ្វើឱ្យអង្គការក្រៅរដ្ឋាភិបាលកាន់តែរីកចំរើនឡើង និង មានផលប៉ះពាល់កាន់តែធំនោះ "លទ្ធផលរយៈពេលវែង" នៃភាពជាដៃគូនឹងមានសារៈសំខាន់ដ៏វិសេសវិសាលជាង "លទ្ធផលរយៈពេលខ្លី" ។

# កំណត់ត្រា

# ៧ ការកសាងភាពជាដៃគូដ៏ជោគជ័យ

## កំណត់ពីភាពជោគជ័យ

តើភាពជាដៃគូដែលប្រកបដោយជោគជ័យមានសណ្ឋានបែបណា ? តើអ្នកណាជាអ្នកកំណត់ភាពជោគជ័យ ? តើវាស់វែងដោយរបៀបណា ? ការកសាងភាពជាដៃគូ និង គំរោងជាដៃគូមានភាពស្មុគ្រស្មាញ និង មានការលំបាកណាស់ក្នុងការវាយតំលៃ ។ លទ្ធផលរយៈពេលខ្លី លទ្ធផលរយៈពេលវែង និង ផលប៉ះពាល់ជាទូទៅមានភាពខុសគ្នា ពេលខ្លះមានលក្ខណៈតូចខ្លាំង ហើយជាញឹកញាប់មិនអាចនឹងរំពឹងទុកជាមុនបាន ។ ក្នុងសៀវភៅនេះ យើងលើកយកបញ្ហាជាក់លាក់ទាក់ទងនឹងការធ្វើការប៉ាន់ប្រមាណភាពជាដៃគូ ។ យើងសន្មតទុកជាមុនថា គំរោងជាច្រើននឹងត្រូវបានធ្វើការវាយតំលៃតាមវិធីដូចៗគ្នាទៅនឹងការវាយតំលៃនៃគ្រប់គំរោងអភិវឌ្ឍន៍ទាំងអស់ (ជាទូទៅ ធ្វើតាមលក្ខណៈវិនិច្ឆ័យដែលស្ថាប័នផ្តល់ហិរញ្ញប្បទានបានកំណត់តាំងពីគ្រាដំបូង) ។ ការបារម្ភដ៏ចំបងរបស់យើង គឺជុំវិញទស្សនៈរបស់អង្គភាពជាដៃគូចំពោះប្រសិទ្ធភាពនៃភាពជាដៃគូ ។

ដៃគូត្រូវធ្វើការវាស់វែង ឬ ប៉ាន់ប្រមាណលើបីចំនុចដូចខាងក្រោម :

- ផលប៉ះពាល់នៃគំរោងភាពជាដៃគូរបស់គេទៅលើសង្គម
- តំលៃនៃភាពជាដៃគូ ចំពោះអង្គភាពជាដៃគូនីមួយៗ
- ការចំណាយជាក់ស្តែង និង ផលប្រយោជន៍នៃអភិក្រមភាពជាដៃគូ

ដោយពិនិត្យទៅលើចំនុចទាំងបីនេះ យើងនឹងអាចធ្វើការវាយតំលៃបានថា :

- ភាពជាដៃគូមានប្រសិទ្ធភាពក្នុងការធ្វើឱ្យសំរេចទិសដៅរបស់វា
- ដៃគូបានទទួលផលប្រយោជន៍ពិតប្រាកដពីការចូលរួមរបស់ពួកគេ
- អភិក្រមនៃភាពជាដៃគូ គឺជាជំរើសដ៏ប្រសើរ និង ស័ក្តិសមបំផុត

ការប្រមូលព័ត៌មានដើម្បីធ្វើការវិនិច្ឆ័យអំពីប្រសិទ្ធភាពនៃភាពជាដៃគូគឺជាដំណើរការដ៏លំបាកមួយ ។ ភាពជាដៃគូជាច្រើនដែលឈានមកដល់ដំណាក់កាលធ្វើការវាយតម្លៃ ហាក់ដូចជាចង់ធ្វើការបែងចែកដាច់ពីគ្នារវាងការវាស់វែងផលប៉ះពាល់គំរោងនៃភាពជាដៃគូ និង ការប៉ាន់ប្រមាណអំពីតំលៃនៃភាពជាដៃគូចំពោះអង្គភាពដែលជាដៃគូ ។

វាជាការសមហេតុផលដែលយើងអាចរំពឹងថា គំរោង និង សកម្មភាពផ្សេងៗអាចធ្វើការវាយតំលៃដោយប្រើវិធីសាស្ត្រសាមញ្ញ និង ដោយផ្អែកលើលទ្ធផលរយៈពេលខ្លី និង ស្ថិតិ ។ ប៉ុន្តែការប៉ាន់ប្រមាណពីតំលៃនៃភាពជាដៃគូខ្លួនឯង តម្រូវឱ្យប្រើអភិក្រមផ្សេង ។ ដើម្បីធ្វើការប៉ាន់ប្រមាណកិច្ចសហប្រតិបត្តិការ និង ការចូលរួម តម្រូវឱ្យមានកិច្ចសហប្រតិបត្តិការ និង ការចូលរួមនៅក្នុងដំណើរការសិក្សាស្រាវជ្រាវ (ប្រសិនបើសុចរិតភាពនៃភាពជាដៃគូខ្លួនឯងបានទទួលការគោរព និង ថែរក្សា) ។

ដូច្នេះ តើភាពជាដៃគូដែលប្រកបដោយភាពជោគជ័យមានសណ្ឋានបែបណា ? ភាពជាដៃគូដែលប្រកបដោយជោគជ័យមានលក្ខណៈមួយចំនួនច្រើន ឬ ទាំងអស់ នៃលក្ខណៈខាងក្រោម :

- ភាពជាដៃគូធ្វើអ្វីៗតាមផែនការដែលបានកំណត់ទុកជាមុន (កម្មវិធី ឬ គំរោងបានសំរេចតាមគោលបំណងដែលបានព្រមព្រៀងគ្នាពីដំបូង)
- ភាពជាដៃគូមានផលប៉ះពាល់ចំពោះអ្នកដទៃទៀតដែលមិនមែនជាក្រុមគោលដៅ (មានការទទួលស្គាល់ពីសមិទ្ធផលពីក្រុមគោលដៅរបស់គំរោង និង ពីសហគមន៍ ។
- ភាពជាដៃគូមាននិរន្តរភាព និង ការគ្រប់គ្រងដោយខ្លួនឯង (ទោះបីតាមរយៈការបន្តភ្ជាប់ទំនាក់ទំនងអង្គភាពជាដៃគូ ឬ តាមរយៈខ្លួនឯងផ្ទាល់) យន្តការសំរាប់និរន្តរភាពដែលដាក់ជំនួសភាពជាដៃគូនឹងជំរុញឱ្យដៃគូឈានទៅមុខទៀត ។
- ភាពជាដៃគូមាន "តំលៃបន្ថែម" ដែលដៃគូនីមួយៗបានទទួលនូវផលប្រយោជន៍ (អង្គភាពជាដៃគូបង្កើតរបៀបធ្វើការងារថ្មីៗជាមួយវិស័យផ្សេងៗទៀត ហើយមានប្រព័ន្ធផ្ទាល់ខ្លួន និង បែបបទក្នុងការប្រតិបត្តិ ក៏កាន់តែប្រសើរ) ។

# ប្រអប់ ៧ ការនិយាយរឿង

មានគ្រាមួយ...

ភាពជាដៃគូ ចាប់ផ្តើមដូចជារឿងដែលស្ថិតក្នុងគំនិតរបស់យើង ហើយបញ្ចប់ដូចរឿងផ្សេងៗទៀតក្នុងពិភពលោកដែរ ។ ក្នុងដំណើរដែលចាប់ផ្តើមពីការគិតរហូតក្លាយជាការពិត យើងចាប់ផ្តើមដោយការស្រមើស្រមៃ ។ ខណៈដែលយើងស្រមើស្រមៃបង្កើតនូវគំនិតមួយ យើងក៏អាចធ្វើការចែករំលែករឿងនោះតាមរបៀបដែលរស់រវើក ធ្វើឱ្យគេមានចំណាប់អារម្មណ៏ និង រំភើបរីករាយ ។

ការចែករំលែកបទពិសោធន៍របស់យើងដោយមិនពឹងផ្អែកលើការស្រមើស្រមៃ អាចធ្វើឱ្យការកសាងភាពជាដៃគូប្រៀបដូចជាការលាបពណ៌ដោយលំហាត់មួយចំនួន ។ ដំណើរការត្រូវបានកាត់បន្ថយទៅជាស៊េរីនៃការសាកល្បងនូវយុទ្ធសាស្ត្រផ្សេងៗ ការរៀបរាប់ពីស្ថិតិ និង វិភាគការពិត ។ ខណៈដែលរឿងបាននិទាន វានឹងទាក់ទាញចំណាប់អារម្មណ៏តិចតួចពីអ្នកស្តាប់ ។ ដើម្បីធ្វើឱ្យប្រសើរជាងនេះ យើងត្រូវដឹងពីអ្វីដែលធ្វើឱ្យមានន័យជ្រៅក្នុងដំណាក់កាលនោះ និង ព្យាយាមនាំទស្សនៈនៃជីវិតដែលយើងធ្លាប់រស់ក្នុងហានិភ័យពិតៗ ។

ដើម្បីនិយាយរឿងនៃភាពជាដៃគូ គឺត្រូវរាប់ឡើងវិញនូវដំណើរផ្សងព្រេង ជាដំណើរស្វែងរកអ្វីមួយដែលខុសប្លែកពីគេ និង ជាសកល ។ ប្លែកពីគេ ពីព្រោះគ្មានអ្នកធ្វើបែបនេះពីមុនមក ។ ជាសកល ពីព្រោះភាពជាដៃគូនីមួយៗធ្វើដំណើរទៅក្នុងសាគរដែលគេមិនស្គាល់ពីមុន ហើយស្វែងរកទិសដៅដែលគ្មានសុវត្ថិភាព ឬដែលគ្មានភាពជាក់លាក់ ។ ជាការពិត វាមានរង្វាន់សំរាប់អ្នកឈ្នះ តែវាក៏មានគ្រោះថ្នាក់យ៉ាងរហ័ស ដែលភាពជាដៃគូនឹងត្រូវជួបប្រទះក្នុងដំណើរផ្លូវឆ្ពោះទៅរកទីបញ្ចប់ ។

ចំពោះការប្រាស្រ័យទាក់ទងក្នុងដំណើររឿងនេះ ជាចាំបាច់មិនត្រូវរំលងឧបសគ្គដែលគេបានជួបប្រទះទេ មើលបញ្ហាដែលកើតឡើងពីដំបូងដូចជាដុំថ្មដែលកំពុងចោល (ចំពោះអ្នកទាំងឡាយណាដែលមិនមានកិច្ចសហប្រតិបត្តិការ) ឬ ក៏ជាកំហុសឆ្គងដ៏ធ្ងន់ធ្ងរនៃការវិនិច្ឆ័យ ដែលត្រូវធ្វើការប្រឈម និង ដោះស្រាយ ។ រឿងដែលល្អ គឺរឿងដែលរក្សាបាននូវភាពតានតឹងរវាងល្អ និង អាក្រក់ រវាងលទ្ធភាពដែលអាចទទួលបានជោគជ័យ និង លទ្ធភាពដែលអាចបរាជ័យ ។ ធានាឱ្យបានថាកំហុសឆ្គងក៏ដូចជាភាពជោគជ័យ គឺត្រូវអនុញ្ញាតឱ្យកើតមានឡើងតាមលក្ខណៈពេញលេញ ។ យើងដែលជាអ្នកស្តាប់ចង់ឮពីអ្វីដែលជិតបាត់បង់ ឬ ការខំប្រឹងប្រែងដល់ដំណាក់កាលចុងក្រោយ ដើម្បីធានាសុវត្ថិភាពកិច្ចព្រមព្រៀង ។

ប្រសិនបើមានការផ្តល់ដំបូន្មានតែមួយ ដំបូន្មាននោះ គឺត្រូវតែមានសេចក្តីក្លាហាន ។ ជាការងាយស្រួលក្នុងការដាក់ខ្លួនដើម្បីកាត់បន្ថយនូវអ្វីដែលបានសំរេច ។ ទោះជាយ៉ាងណាក្តី ភាពជាដៃគូអន្តរវិស័យវាមិនមែនជារឿងធម្មតានោះទេ ។ ភាពជាដៃគូពិតប្រាកដប្រៀបដូចជាដំបងក្នុងដៃអ្នកខ្លាំងពូកែ ។ សូមពិចារណាអំពីភាតរភាពរបស់ចិញ្ចៀន ។ ការសំរេចជ្រើសរើសប្រតិបត្តិការភាពជាដៃគូ ដើម្បីយកឈ្នះលើឧបសគ្គ និង ដើម្បីធ្វើអ្វីៗឱ្យសំរេចតាមគោលបំណងទាំងអស់នេះគឺជារឿងដែលមិនធម្មតា និង មិនអាចរំពឹងទុកជាមុនបាន ។

នេះមិនមែនមានន័យថាត្រូវប្រើភាសាល្អដូចផ្កា ឬ ក៏ប្រើប្រយោគកថាខ័ណ្ឌសីលសាស្ត្រដែរ ។ ប៉ុន្តែវាមានន័យថាកាត់បន្ថយភាពជោគជ័យឱ្យត្រូវតាមការពិត ។ យើងអាចស្ងប់ស្ងែងជាមួយនឹងអ្វីដែលយើងបានសំរេច ។ ម្យ៉ាងទៀតវាជួយឱ្យយើងមើលឃើញភាពជាដៃគូថាជាគោលគំនិតនៃការខំប្រឹងប្រែងពិតៗ ។

នៅទីបំផុត (ការនៅតែរក្សាបាននូវការខិតខំប្រឹងប្រែង ការតតាំងជាមួយព្យុះកំណាច និង ឆ្ពោះទៅកាន់ជ័យជំនះ) គ្មានអ្នកណាម្នាក់នៅតែដដែលនោះទេ ។ បទពិសោធន៏មានជាហូរហែ ។ ការប្រឈមមុខជាមួយនឹងការសង្ស័យ និង ការពុះពារជំនះការលំបាក បាននាំមកនូវការរៀនសូត្រថ្មី កំលាំងថ្មី និង ការយល់ដឹងថ្មីៗ ។ អនុវត្តកសាងភាពជាដៃគូតាមបែបច្នៃប្រឌិត យើងបានផ្លាស់ប្តូរអត្តភាពរបស់យើង និង ខ្លួនរបស់យើង និយាយម្យ៉ាងទៀត ផ្លាស់ប្តូរពិភពលោករបស់យើង ។

នេះ គឺជារឿងដ៏មានតម្លៃ ។

- ភាពជាដៃគូបានបង្កើតឱ្យមានការចូលរួមចំណែកដ៏មានប្រយោជន៍ទៅក្នុងចលនានៃភាពជាដៃគូសកល (ព័ត៌មានអំពីភាពជាដៃគូមានភាពទូលំទូលាយអាចរកបាននៅតាមទីសាធារណៈ ដើម្បីឱ្យក្រុមផ្សេងៗទៀតបំពេញបន្ថែមតាមមធ្យោបាយរបស់គេរៀងៗខ្លួន) ។

ចំនុចដែលសំខាន់នៅទីនេះ គឺថាក្នុងដំណាក់កាលដំបូងៗនៃភាពជាដៃគូ ដៃគូបានព្រមព្រៀងគ្នាលើសូចនាករមួយចំនួន (ទាំងសូចនាករប្រតិបត្តិការជាក់ស្តែង និង សូចនាករអំពីដំណើរការទូលំទូលាយ) សំរាប់ប្រើប្រាស់ធ្វើជាមូលដ្ឋានគ្រឹះវាស់វែងរកប្រសិទ្ធភាពនៃភាពជាដៃគូក្នុងកំឡុងពេលណាមួយ ។ ប្រសិនបើអាច សូចនាករគួរតែគ្របដណ្តប់លើដៃគូជាក់លាក់ និង គោលដៅរួម ។

## ចែករំលែកបទពិសោធន៍ល្អៗ

ឧបករណ៍ទី ៧ : គំរូករណីសិក្សា – ផ្តល់ទំរង់សាមញ្ញសំរាប់ប្រមូលករណីសិក្សា ដើម្បីធ្វើការចែករំលែកបទពិសោធន៍

ប្រសិនបើភាពជាដៃគូបានទទួលជោគជ័យ និង លទ្ធផលល្អ ត្រូវធ្វើការផ្សព្វផ្សាយ (ប៉ុន្តែត្រូវតែមានភាពប្រាកដប្រជា ហើយប្រាកដក្នុងចិត្តថា អ្នកមានរឿងពិតដើម្បីនិទានប្រាប់គេ) ។ នៅពេលដែលអ្នកសំរេចចិត្តប្រកាសប្រាប់ជាសាធារណៈ ត្រូវនិយាយប្រាប់ឱ្យបានល្អ (សូមមើលប្រអប់ ៧ ទំព័រ ៣៦) អ្នកត្រូវជ្រើសរើស "អ្នកដែលពូកែនិយាយរឿង" ពីបណ្តាញភាពជាដៃគូរបស់អ្នក ។

តើនរណានឹងចាប់អារម្មណ៍លើភាពជោគជ័យ ឬមិនជោគជ័យក្នុងភាពជាដៃគូ ?

មានអ្នកស្តាប់សំខាន់ៗជាច្រើន (ទាំងខាងក្នុង និង ខាងក្រៅ) ដែលគេចាប់អារម្មណ៍ :

| | |
|---|---|
| **អ្នកស្តាប់ខាងក្នុង** | • ក្រុមគោលដៅនៃគំរោងភាពជាដៃគូ<br>• ដៃគូ និង បុគ្គលិកដែលចូលរួមក្នុងភាពជាដៃគូ<br>• អ្នកគ្រប់គ្រង<br>• ក្រុមអ្នកគ្រប់គ្រងជាន់ខ្ពស់នៅក្នុងអង្គភាពដៃគូ<br>• នាយកដ្ឋានដែលបានជ្រើសរើសនៅក្នុងអង្គភាពដៃគូ<br>• បុគ្គលិកប្រតិបត្តិដែលមានការប្រឈមស្រដៀងៗគ្នា កន្លែងផ្សេង |
| **អ្នកស្តាប់ខាងក្រៅ** | • ស្ថាប័នហិរញ្ញប្បទានពីខាងក្រៅ<br>• អ្នកបង្កើតគោលនយោបាយ<br>• ភ្នាក់ងារផ្តល់ជំនួយទ្វេភាគី ពហុភាគី និង ប្រចាំតំបន់<br>• អង្គភាពពាក់ព័ន្ធ<br>• ប្រព័ន្ធផ្សព្វផ្សាយ និង ស្ថាប័នសាធារណៈ<br>• ដៃគូផ្សេងៗ រាប់បញ្ចូលទាំងអ្នកដែលចូលរួមជាដៃគូ ឬ អ្នកដែលបង្កើតភាពជាដៃគូសំរាប់ខ្លួនគេ ដោយទទួលការលើកទឹកចិត្តពីគំរោងនេះ |

ឧបករណ៍ទី ៨ : បញ្ជីសម្រង់ការប្រាស្រ័យទាក់ទង : សំណើមួយចំនួនអំពីអ្នកដែលមានចំណាប់អារម្មណ៍ ជម្រើសនានាក្នុងការប្រាស្រ័យទាក់ទង និងសារសំរាប់ដំណើររឿងការកសាងភាពជាដៃគូ

វាជាការសំខាន់ក្នុងការបែងចែកព័ត៌មានតាមមធ្យោបាយត្រឹមត្រូវដល់ក្រុមអ្នកស្តាប់ផ្សេងៗគ្នា ។ ស្ថាប័នផ្តល់ហិរញ្ញប្បទានពីខាងក្រៅរំពឹងថានឹងទទួលបានរបាយការណ៍ជាផ្លូវការ ។ មជ្ឈដ្ឋានសាធារណៈនឹងចង់ដឹងរឿងដែលទាក់ទងនឹងការបានប្រសើរឡើងរបស់បុគ្គល ។ អ្នកបង្កើតគោលនយោបាយត្រូវការស្ថិតិ ។ ដៃគូដែលមានសក្តានុពលផ្សេងទៀត ចង់ដឹងអំពីរបៀបដែលដៃគូបច្ចុប្បន្នទទួលបានផលប្រយោជន៍ពីការចូលរួមរបស់គេ ។ ភាពជាដៃគូមួយដែលទទួលបានជោគជ័យនឹងដឹងថាតើអ្នកណាត្រូវការព័ត៌មានអ្វី ហើយនឹងរកវិធីសាស្ត្រធ្វើការប្រាស្រ័យទាក់ទងជាមួយក្រុមអ្នកចង់ដឹងចង់ឮតាមមធ្យោបាយផ្សេងៗគ្នា ។

## កិច្ចសហប្រតិបត្តិការក្នុងពិភពប្រកួតប្រជែង

ភាពជាដៃគូផ្តល់នូវអភិក្រមជាក់លាក់សំរាប់ធ្វើការអភិវឌ្ឍប្រកបដោយនិរន្តរភាព ដោយបញ្ចូលកិច្ចសហប្រតិបត្តិការដើម្បីធ្វើការប្រកួតប្រជែង ។

គ្មានភាពជាដៃគូណាមួយមានភាពងាយស្រួល សុវត្ថិភាព ស្ថេរភាព រហ័ស ឬ មានតម្លៃថោកនោះទេ ។ ក៏ប៉ុន្តែជាមួយនឹងការគ្រប់គ្រងបានល្អ ការតាំងចិត្តបានល្អ និង ការប្តេជ្ញាចិត្ត ភាពជាដៃគូអន្តរវិស័យដើម្បីការអភិវឌ្ឍប្រកបដោយនិរន្តរភាព អាចនឹងមានដំណើរការល្អ និង អាចសំរេចបានលទ្ធផលល្អប្រសើរជាងការមានអភិក្រមតែមួយវិស័យ ដើម្បីដោះស្រាយបញ្ហាដូចគ្នានេះ ។

ជាចុងក្រោយ មានតម្រាមាសសំខាន់បី ដែលអាចជួយធ្វើឱ្យការកសាងភាពជាដៃគូដំណើរការបានល្អ...

**ចំណាំ**

ផែនការសកម្មភាពជាចំណុចសំខាន់សំរាប់ភាពជាដៃគូ : នៅពេលដែលទំនាក់ទំនងភាពជាដៃគូត្រូវបានបង្កើតឡើង ហើយចំណាប់អារម្មណ៍បានប្តូរពីការបង្កើតភាពជាដៃគូ ទៅផ្តោតការយកចិត្តទុកដាក់លើការបង្កើត និង អនុវត្តកម្មវិធីរួមគ្នា ។ វាជារឿងសំខាន់ណាស់ ដែលយើងត្រូវធ្វើវាឱ្យបានល្អ បើមិនដូច្នេះទេ វានឹងអន្តរាយដល់ភាពជាដៃគូ ។

ជារួម ត្រូវចងចាំថា ភាពរឹងមាំនឹងទទួលបានជោគជ័យ (កវីនិពន្ធជនជាតិនីហ្សេរីយ៉ាម្នាក់ ឈ្មោះ បេន អ៊ុករីបានមានប្រសាសន៍ថា : មនុស្សបានទទួលព្រះពរជាមួយនឹងបំលាស់ប្តូរសំខាន់ៗ) ។ ភាពជាដៃគូអន្តរវិស័យមានសក្តានុពលក្នុងការធ្វើជាយន្តការដ៏ប្រសើរសំរាប់ធ្វើការផ្លាស់ប្តូរសេដ្ឋកិច្ច បរិដ្ឋាន និង សង្គម ។ សូមឱ្យជួបនឹងសំណាងល្អ ក្នុងការនាំភាពជាដៃគូរបស់លោកអ្នកទៅកាន់គោលដៅនេះ ។

# ឧបសម្ព័ន្ធ


១
ទម្រង់ប៉ាន់ប្រមាណដៃគូ

២
កំរងសំណួរការប៉ាន់ប្រមាណ

៣
គំរូកិច្ចព្រមព្រៀងភាពជាដៃគូ

៤
កំរងសំណួរអំពីតួនាទី និង
ជំនាញសំរាប់កសាង ភាពជាដៃគូ

៥
គោលការណ៍ណែនាំសំរាប់ដៃគូសន្ទនា

៦
ទម្រង់ពិនិត្យមើលឡើងវិញអំពីភាពជាដៃគូ

៧
គំរូករណីសិក្សា

៨
បញ្ជីសម្រង់ការប្រាស្រ័យទាក់ទង

# កំណត់ត្រា

# ឧបករណ៍ ១ ទម្រង់ប៉ាន់ប្រមាណដៃគូ

អ្នកក្រើនរំលឹក ជួយឱ្យអ្នកដែលបង្កើតភាពជាដៃគូសួរសំណួរបែបជាប្រព័ន្ធចំពោះដៃគូនីមួយៗ ដើម្បីធានាថា វាស៊ីសង្វាក់គ្នាជាមួយនឹងគោលដៅ និងតម្រូវការរបស់ភាពជាដៃគូ ។ ទម្រង់ឧបករណ៍នេះ អាចប្រើជាការចាប់ផ្តើមធ្វើការរាវរកទំនាក់ទំនង ដោយផ្តល់នូវការពិភាក្សាជាមូលដ្ឋានគ្រឹះជាមួយអ្នកចូលរួមសំខាន់ៗ ទាំងក្នុងកំរិតខ្ពស់ និង កំរិតប្រតិបត្តិការ ។ វាបានបង្កើតឡើង ដើម្បីសួរសំណួរដែលសមរម្យ ( មិនមែនជាការផ្តល់និយមន័យជាក់លាក់ទេ) ។

| **តើអង្គភាពជាដៃគូមាន...** | **ស្ថានភាពបច្ចុប្បន្ន**<br>រំលឹកអំពី :<br>• អ្វីដែលលោកអ្នកដឹង<br>• ធនធានព័ត៌មានដែលអាចទុកចិត្តបាន<br>• ទោះបើមានព័ត៌មានគ្រប់គ្រាន់-ការសំរេចចិត្តផ្អែកលើអ្វីជាគោល | **សកម្មភាពអនាគត**<br>កត់សំគាល់អំពី :<br>• តំរូវការព័ត៌មានសំរាប់អនាគត<br>• អ្វីដែលនៅតែមានកង្វល់<br>• តារាងពេលវេលា និង លក្ខណៈវិនិច្ឆ័យសំរាប់ធ្វើការសំរេចចិត្តអំពីនិរន្តរភាព |
|---|---|---|
| ១. កំណត់ត្រាទិន្នន័យបានល្អ ? | | |
| ២. ឈរលើហេតុផល និងមានការគោរពនៅក្នុងវិស័យខ្លួនឯងដូចម្តេចដែរ ? | | |
| ៣. ឈរលើហេតុផល និង មានការគោរពពីវិស័យផ្សេងៗ និង អ្នកចូលរួមសំខាន់ៗ ? | | |
| ៤. បំណងចែករំលែកនូវទំនាក់ទំនងដ៏ទូលំទូលាយ និង មានប្រសិទ្ធភាព ? | | |
| ៥. ច្រកបែងចែកព័ត៌មាន ធនធាន និង បទពិសោធន៍ ? | | |
| ៦. ជំនាញ និងសមត្ថភាពដែលបំពេញបន្ថែមទៅក្នុងអង្គភាពរបស់អ្នក និង ដៃគូ ? | | |
| ៧. ការគ្រប់គ្រង និង រចនាសម្ព័ន្ធ អភិបាលកិច្ចល្អ ? | | |
| ៨. របាយការណ៍អំពីស្ថេរភាពហិរញ្ញវត្ថុ និង ភាពអាចជឿទុកចិត្តបាន ? | | |
| ៩. ក្រុមបុគ្គលិកមានស្ថេរភាព ? | | |
| ១០. ប្រើអំណាចផ្តាច់ការ ពេលជួបស្ថានភាពមិនប្រក្រតី ? | | |
| **តើបុគ្គលិកអង្គភាពជាដៃគូមាន ...** | | |
| ១១. បទពិសោធន៍ និង ទំនុកចិត្តក្នុងការអភិវឌ្ឍគំរោង ? | | |
| ១២. ជោគជ័យក្នុងការរកធនធាន និង គ្រប់គ្រងថវិកា ? | | |
| ១៣. ការប្រាស្រ័យទាក់ទង និង ធ្វើការងារជាក្រុមបានល្អ ? | | |

# កំណត់ត្រា

# ឧបករណ៍ ២ កំរងសំណួរការប៉ាន់ប្រមាណ

## ១. បំណងប្រាថ្នា ឥរិយាបថ និង ការតាំងចិត្តរបស់អ្នកដឹកនាំម្នាក់ៗ

- តើខ្ញុំចាត់ទុកអភិក្រមនៃភាពជាដៃគូថាជារឿងសំខាន់សំរាប់សំរេចគោលដៅដែរឬទេ ?
- តើខ្ញុំជឿថា ដៃគូរបស់ខ្ញុំ ចង់ឱ្យភាពជាដៃគូមានជោគជ័យដែរឬទេ ?
- តើខ្ញុំបានតាំងចិត្តទទួលយកលទ្ធផលនៃភាពជាដៃគូដែរឬទេ ?
- តើខ្ញុំនឹងហ៊ានប្រឈមចំពោះការសន្មតរបស់ខ្ញុំដែរឬទេ ?
- តើខ្ញុំឱ្យតំលៃទៅលើភាពទីទៃពីគ្នា ក្នុងចំណោមដៃគូរបស់យើងដែរឬទេ ?
- តើខ្ញុំជឿទុកចិត្តលើដៃគូរបស់ខ្ញុំ ក្នុងការដែលគេធ្វើការសំរេចចិត្តជំនួសខ្ញុំដែរឬទេ ?

## ២. អាកប្បកិរិយារបស់អ្នកដឹកនាំម្នាក់ៗ

- តើខ្ញុំបានជួយគាំទ្រអភិក្រមនៃភាពជាដៃគូដែរឬទេ ?
- តើខ្ញុំប្រុងប្រៀបស្តាប់យ៉ាងសកម្មចំពោះដៃគូរបស់ខ្ញុំដែរឬទេ ?
- តើខ្ញុំបានប្រកាន់ខ្ជាប់លើគុណតំលៃរបស់ភាពជាដៃគូដែរឬទេ ? (ឧ. អាកប្បកិរិយាចំពោះ សមធមិ តម្លាភាព និង ផលប្រយោជន៍ទៅវិញទៅមក)
- តើខ្ញុំបានស្វែងរក និង ផ្តល់យោបល់ត្រឡប់ដល់ ឬ ពីដៃគូរបស់ខ្ញុំដែរឬទេ ?
- តើខ្ញុំដើរតាមអ្វី ដែលខ្ញុំបានតាំងចិត្តដែរឬទេ ?
- តើខ្ញុំគោរពឱ្យតម្លៃដៃគូរបស់ខ្ញុំ ទោះបីក្នុងពេលគេអវត្តមានដែរឬទេ ?
- តើខ្ញុំគាំទ្រតម្រូវការអភិវឌ្ឍរបស់ដៃគូខ្ញុំដែរឬទេ ?
- តើខ្ញុំទទួលស្គាល់ផលសំរេច ដែលដៃគូរបស់ខ្ញុំបានធ្វើដែរឬទេ ?

## ៣. ផ្នត់គំនិត គុណតំលៃ និង បទដ្ឋានរបស់ភាពជាដៃគូ

- តើយើងបានចែករំលែកការយល់ដឹងអំពីផលប្រយោជន៍ និង ហានិភ័យនៃភាពជាដៃគូដែរឬទេ ?
- តើយើងបានផ្សាភ្ជាប់លើទស្សនៈវិស័យ និង គុណតំលៃរួមដែរឬទេ ?
- តើយើងមានសេរីភាពក្នុងការចែករំលែកគំនិតរបស់យើង ទោះបីជាក្នុងស្ថានភាពខ្វែងគំនិតគ្នាជាមួយអ្នកដទៃដែរឬទេ ?
- តើយើងមានការបើកចំហចិត្ត ដើម្បីផ្លាស់ប្តូរទស្សនៈរបស់យើងចំពោះអ្នកពាក់ព័ន្ធផ្សេងៗទៀតដែរឬទេ ?
- តើយើងផ្តល់ដល់គ្នាទៅវិញទៅមក នូវផលប្រយោជន៍នៃការសង្ស័យដែរឬទេ ?
- តើយើងបានបង្កើតវប្បធម៌មិតម្លាភាព ក្នុងចំណោមយើង និង ជុំវិញភាពជាដៃគូដែរឬទេ ?
- តើយើងបានបន្តរកមើលឱកាស ដើម្បីរៀនសូត្រ ផ្លាស់ប្តូរ និង កែលំអដែរឬទេ ?

## ៤. រចនាសម្ព័ន្ធ ប្រព័ន្ធ និង យុទ្ធសាស្ត្ររបស់ភាពជាដៃគូ

- តើកិច្ចព្រមព្រៀងជាដៃគូរបស់យើងច្បាស់លាស់ ហើយគ្រប់គ្នាងាយយល់ដែរឬទេ ?
- តើមានផលកំរៃសំរាប់ដៃគូគិត និង ធ្វើសកម្មភាពសំរាប់ជាប្រយោជន៍ចំពោះភាពជាដៃគូដែរឬទេ ?
- តើយើងមានជំនាញ សមត្ថភាព និង បច្ចេកវិជ្ជា ដើម្បីធ្វើឱ្យភាពជាដៃគូបានជោគជ័យដែរឬទេ ?
- តើយើងមានរចនាសម្ព័ន្ធ និង ច្បាប់វិន័យ ក្នុងការធ្វើការជាមួយគ្នាឱ្យមានប្រសិទ្ធភាពដែរឬទេ ?
- តើយើងបានចែករំលែកព័ត៌មានជាមួយអ្នកពាក់ព័ន្ធផ្សេងៗដោយសេរីដែរឬទេ ?
- តើយុទ្ធសាស្ត្រជាអាទិភាពរបស់យើងមានភាពច្បាស់លាស់ចំពោះអ្នកគ្រប់គ្នា ដែលពាក់ព័ន្ធដែរឬទេ ?
- តើយើងបានកំណត់ និង គោរពតាមស្តង់ដារគុណភាពកំរិតខ្ពស់ចំពោះអ្វីៗគ្រប់យ៉ាង ដែលយើងបានធ្វើដែរឬទេ ?
- តើយើងបាននាំយកធនធានដ៏ប្រពៃដើម្បីបំពេញបង្គ្រប់ និង ធ្វើឱ្យភាពជាដៃគូបានជោគជ័យដែរឬទេ ?
- តើយើងបានធ្វើឱ្យភាពជាដៃគូកើតមានឡើងនូវក្នុងស្ថាប័នទាំងមូល ដើម្បីអាចបន្តដំណើរការទៅមុខដោយគ្មានយើងដែរឬទេ ?

*គ្រោងការនេះដកស្រង់ចេញពី "ប្រវត្តិសង្ខេបនៃអ្វីៗទាំងអស់" រៀបរៀងដោយ លោកគិន វីលប័រ បោះពុម្ពដោយរោងពុម្ពសាំហាឡា ។*

# កំណត់ត្រា

# ឧបករណ៍ ៣ គំរូកិច្ចព្រមព្រៀងភាពជាដៃគូ

**១.០ អង្គភាពជាដៃគូ**

១.១ ដៃគូ ក
អាសយដ្ឋានទំនាក់ទំនង
អ្នកទំនាក់ទំនង

១.២ ដៃគូ ខ
អាសយដ្ឋានទំនាក់ទំនង
អ្នកទំនាក់ទំនង

១.៣ ដៃគូ គ
អាសយដ្ឋានទំនាក់ទំនង
អ្នកទំនាក់ទំនង

**២.០ សេចក្តីថ្លែងពីគោលបំណង**

២.១ យើងបានយល់ព្រមចុះហត្ថលេខាខាងក្រោម ដោយទទួលស្គាល់នូវការតាំងចិត្ត/កង្វល់រួម អំពី...

២.២ ដោយធ្វើការរួមគ្នាក្នុងភាពជាដៃគូ យើងមើលឃើញថា គុណតំលៃបន្ថែមរបស់យើងទាំងសងខាង អាចនាំទៅសំរេចការតាំងចិត្តនេះ និង ដោះស្រាយនូវកង្វល់នេះ

២.៣ យើងរំពឹងទុកយ៉ាងច្បាស់លាស់ថា ដៃគូនីមួយៗនឹងចូលរួមចំណែក ក្នុងគំរោងតាមមធ្យោបាយដូចខាងក្រោមនេះ :
ដៃគូ ក...
ដៃគូ ខ...
ដៃគូ គ...
ដៃគូទាំងអស់...

**៣.០ រចនាសម្ព័ន្ធ និង និតីវិធី**

៣.១ តួនាទី និង ការទទួលខុសត្រូវរបស់ដៃគូ...
៣.២ ការសំរបសំរួល និង ការងាររដ្ឋបាល...
៣.៣ ក្រុមការងារ/គណៈកម្មាធិការ/ក្រុមប្រឹក្សាយោបល់...
៣.៤ ដំណើរការក្នុងការសំរេចចិត្ត...
៣.៥ ការរៀបចំឱ្យមានគណនេយ្យភាព...

**៤.០ ធនធាន**

៤.១ យើងនឹងផ្តល់ធនធានខាងក្រោមទៅ :
ក. ភាពជាដៃគូ និង
ខ. គំរោង...

**៥.០ សវនកម្ម / ពិនិត្យឡើងវិញ / កែសំរួល**

៥.១ យើងបានព្រមព្រៀងបង្កើតឱ្យមានព័ត៌មានពាក់ព័ន្ធដល់ភាពជាដៃគូនេះ ដោយអាចរកបានទៅតាមការចាំបាច់

៥.២ យើងបានព្រមព្រៀងពិនិត្យភាពជាដៃគូឡើងវិញ រៀងរាល់... ខែ

៥.១ ធ្វើសវនកម្មឯករាជ្យលើការចាត់ចែងហិរញ្ញវត្ថុសំរាប់ភាពជាដៃគូ (ហើយគំរោងណា ដែលជាលទ្ធផលរបស់ភាពជាដៃគូត្រូវធ្វើសវនកម្មរៀងរាល់ឆ្នាំ)

៥.១ យើងបានព្រមព្រៀងធ្វើការកែសំរួលភាពជាដៃគូ (ដោយរាប់បញ្ចូលទាំងការសរសេរកិច្ចព្រមព្រៀងជាថ្មី) គួរតែធ្វើការពិនិត្យឡើងវិញ ឬ ធ្វើសវនកម្មដែលបង្ហាញថា វាជាការចាំបាច់សំរាប់ភាពជាដៃគូដើម្បីឈានទៅសំរេចគោលបំណង)

**៦.០ លក្ខខណ្ឌនៃកិច្ចព្រមព្រៀង**

៦.១ កិច្ចព្រមព្រៀងនេះ មិនអនុញ្ញាតឱ្យប្រើសំភារៈដែលរក្សាសិទ្ធិ (រាប់បញ្ចូលទាំងផ្លាកសញ្ញា) ឬ ផ្សព្វផ្សាយនូវព័ត៌មានសំងាត់ដល់ភាគីទី ៣ ដោយមិនបានអនុញ្ញាតជាលាយលក្ខអក្សរពីភាគីដែលទាក់ទងឡើយ ។

៦.២ កិច្ចព្រមព្រៀងនេះមិនបានបញ្ចូលអង្គភាពដៃគូ ឬ បុគ្គលិករបស់គេចំពោះរឿងហិរញ្ញវត្ថុ ឬ ការទទួលខុសត្រូវផ្សេងៗ ដោយមិនមានក្នុងឯកសារជាផ្លូវការឡើយ ។

**ហត្ថលេខា**

តំណាងភាគី ក
______________________

តំណាងភាគី ខ
______________________

តំណាងភាគី គ
______________________

កាលបរិច្ឆេទ : ______________________

ទីកន្លែង : ______________________

# កំណត់ត្រា

# ឧបករណ៍ ៤ កំរងសំណួរអំពីតួនាទី និង ជំនាញសំរាប់កសាងភាពជាដៃគូ

កំរងសំណួរនេះបានរៀបចំឡើងសំរាប់រាល់អ្នកដែលចូលរួមក្នុងភាពជាដៃគូ ដើម្បីប៉ាន់ប្រមាណជំនាញភាពជាដៃគូរបស់គេ ក្នុងគោលបំណងបង្កើនទំនុកចិត្តលើជំនាញដែលខ្លាំង និង រកយុទ្ធសាស្ត្រដោះស្រាយជំនាញដែលខ្សោយ ។ វាអាចប្រើសំរាប់ដៃគូជាក្រុម ដើម្បីបង្កើតជាទិដ្ឋភាពនៃជំនាញរួមដែលអាចមានក្នុងភាពជាដៃគូ ហើយកំណត់រកថា តើដៃគូនីមួយៗមានជំនាញពិសេសអ្វីត្រូវនឹងតួនាទី និង ការងារអ្វី ។ វាក៏អាចជាឧបករណ៍ជួយឱ្យដៃគូទទួលស្គាល់នូវតំរូវការជំនាញថ្មី ដែលត្រូវនាំមកពីខាងក្រៅភាពជាដៃគូ ។

## ការប៉ាន់ប្រមាណលើតួនាទី (១=ទាប ៥=ខ្ពស់)

| តើអង្គភាពជាដៃគូមាន... | ការប៉ាន់ប្រមាណលើសមត្ថភាពបច្ចុប្បន្នក្នុងផ្នែកនេះ | | | | | យុទ្ធសាស្ត្រធ្វើឱ្យប្រសើរឡើង (បើចាំបាច់) |
|---|---|---|---|---|---|---|
| ភាពជាដៃគូ/ "ជើងឯក" គំរោង | ☐ ១ | ☐ ២ | ☐ ៣ | ☐ ៤ | ☐ ៥ | |
| បញ្ជ្រាបការយល់ដឹង | ☐ ១ | ☐ ២ | ☐ ៣ | ☐ ៤ | ☐ ៥ | |
| ការសំរបសំរួល/ការងាររដ្ឋបាល | ☐ ១ | ☐ ២ | ☐ ៣ | ☐ ៤ | ☐ ៥ | |
| ការគ្រប់គ្រងទំនាក់ទំនង | ☐ ១ | ☐ ២ | ☐ ៣ | ☐ ៤ | ☐ ៥ | |
| គៀងគរប្រមូលធនធាន | ☐ ១ | ☐ ២ | ☐ ៣ | ☐ ៤ | ☐ ៥ | |
| ធ្វើផែនការគំរោង/កម្មវិធី | ☐ ១ | ☐ ២ | ☐ ៣ | ☐ ៤ | ☐ ៥ | |
| ការគ្រប់គ្រងគំរោង/កម្មវិធី | ☐ ១ | ☐ ២ | ☐ ៣ | ☐ ៤ | ☐ ៥ | |
| ការប្រាស្រ័យទាក់ទង | ☐ ១ | ☐ ២ | ☐ ៣ | ☐ ៤ | ☐ ៥ | |
| ការត្រួតពិនិត្យ | ☐ ១ | ☐ ២ | ☐ ៣ | ☐ ៤ | ☐ ៥ | |
| ផ្សេងៗ (បញ្ជាក់ឱ្យបានច្បាស់) | ☐ ១ | ☐ ២ | ☐ ៣ | ☐ ៤ | ☐ ៥ | |

## ការប៉ាន់ប្រមាណលើជំនាញ (១=ទាប ៥=ខ្ពស់)

| តួនាទីសំខាន់ៗក្នុងភាពជាដៃគូ | ការប៉ាន់ប្រមាណលើសមត្ថភាពបច្ចុប្បន្នក្នុងផ្នែកនេះ | | | | | យុទ្ធសាស្ត្រធ្វើឱ្យប្រសើរឡើង (បើចាំបាច់) |
|---|---|---|---|---|---|---|
| ការចរចា | ☐ ១ | ☐ ២ | ☐ ៣ | ☐ ៤ | ☐ ៥ | |
| ការសម្រុះសម្រួលផ្សះផ្សា | ☐ ១ | ☐ ២ | ☐ ៣ | ☐ ៤ | ☐ ៥ | |
| ការសម្របសម្រួល | ☐ ១ | ☐ ២ | ☐ ៣ | ☐ ៤ | ☐ ៥ | |
| ការសំយោគព័ត៌មាន | ☐ ១ | ☐ ២ | ☐ ៣ | ☐ ៤ | ☐ ៥ | |
| ការបង្វឹក និង ការកសាងសមត្ថភាព | ☐ ១ | ☐ ២ | ☐ ៣ | ☐ ៤ | ☐ ៥ | |
| ការផ្សាភ្ជាប់ស្ថាប័ន | ☐ ១ | ☐ ២ | ☐ ៣ | ☐ ៤ | ☐ ៥ | |
| ការពង្រឹងស្ថាប័ន | ☐ ១ | ☐ ២ | ☐ ៣ | ☐ ៤ | ☐ ៥ | |
| ការពិនិត្យឡើងវិញ និង ការវាយតំលៃ | ☐ ១ | ☐ ២ | ☐ ៣ | ☐ ៤ | ☐ ៥ | |
| ផ្សេងៗ (បញ្ជាក់ឱ្យបានច្បាស់លាស់) | ☐ ១ | ☐ ២ | ☐ ៣ | ☐ ៤ | ☐ ៥ | |

**ចំណាំ**

ជំនាញអាចអភិវឌ្ឍបាន ហើយតួនាទីក៏អាចផ្លាស់ប្តូរក្នុងរយៈពេលភាពជាដៃគូ ។ បើដៃគូម្នាក់ៗកាន់តែអាចអភិវឌ្ឍសមត្ថភាពអាជីពរបស់គេ ហើយទទួលយកការងារថ្មីៗ នោះគេកាន់តែមានអារម្មណ៍ផ្សាភ្ជាប់ ហើយឱ្យតំលៃក្នុងភាពជាដៃគូ ។ ភាពជាដៃគូអាចដំណើរការល្អព្រោះគេផ្តល់ឱកាស ហើយអនុញ្ញាតឱ្យម្នាក់ៗចេញពីប្រអប់នៃរបៀបប្រតិបត្តិការការងារពីមួយថ្ងៃទៅមួយថ្ងៃរបស់គេ ។

# កំណត់ត្រា

# ឧបករណ៍ ៥ គោលការណ៍ណែនាំសំរាប់ដៃគូសន្ទនា

## ការសន្ទនាដែលបង្កើតឱ្យមានលទ្ធភាព

ការសន្ទនាដែលបង្កើតឱ្យមានលទ្ធភាព ជាការសន្ទនាដែលប្រមើលមើលអនាគតពោរពេញទៅដោយលទ្ធភាពដែលអាចទៅរួច ។ វាជាការចែករំលែកគំនិតថ្មៃប្រឌិត និង គំនិតស្រមើលស្រមៃ ។ សំណួររាវរកភាពដែលអាចធ្វើទៅរួចមិនត្រូវមានការខ្វល់ខ្វាយក្នុងដំណាក់កាលនេះទេ ។ ជាងនេះទៅទៀត ការសន្ទនាដែលបង្កើតឱ្យមានលទ្ធភាព គឺមានបំណងនឹងនាំមកនូវអព្ភន្តរញ្ញាណ និង ទស្សនះដែលជាបំណងប្រាថ្នាពីរបៀបដែលអនាគតអាចកើតមានឡើងជាប្រាកដ ។

ការសន្ទនាដែលបង្កើតឱ្យមានលទ្ធភាព ស័ក្តិសមប្រើបំផុតនៅក្នុងដំណាក់កាលដំបូងៗ ពេលដែលដៃគូធ្វើការជាមួយគ្នា ដើម្បីបង្កើតចក្ខុវិស័យ ហើយក៏អាចប្រើក្រោយមកទៀត ក្នុងខណៈដែលភាពជាដៃគូត្រូវធ្វើការកែសំរួលជាថ្មី ។ វាអាចប្រើក្នុងពេលនៃការធ្វើព្យុះគំនិតជុំវិញយុទ្ធសាស្ត្រជាក់លាក់ណាមួយដែលបានកំណត់ជាមួយនឹងសំណួរបើក ដែលលើកទឹកចិត្តក្នុងការធ្វើការឆ្លុះបញ្ចាំង និង ការស្រមើស្រមៃ ហើយមិនគ្រាន់តែទាញយកចំលើយដែលអាចឆ្លើយត្រឹមតែ បាទ និង ទេ នោះដែរ ។

ការសន្ទនាដែលបង្កើតឱ្យមានលទ្ធភាព គួរតែបន្តធ្វើយ៉ាងហោចណាស់ក៏ ១៥ នាទីដែរ ទោះជាវាអាចធ្វើបានរហូតដល់មួយម៉ោងក៏ដោយ ។ ជាឧទាហរណ៍ សំណួរបើក ដែលសក្តិសម គឺ:

*តើដំណោះស្រាយក្នុង... (អាចដាក់គោលគំនិត ឬលទ្ធផលដែលគេប្រាថ្នា) មានន័យដូចម្តេច ?*
*តើដំណោះស្រាយក្នុង... (អាចដាក់គោលគំនិត ឬលទ្ធផលដែលគេប្រាថ្នា) អាចទៅរួចដោយរបៀបណា ?*
*តើលោកអ្នក ឬ យើងអាចបន្តធ្វើការផ្តួចផ្តើមនេះរបៀបណា ?*

## ការសន្ទនាដែលបង្កើតឱ្យមានឱកាស

ការសន្ទនាដែលបង្កើតឱ្យមានឱកាស គឺទាក់ទងនឹងការបង្កើតការប្តេជ្ញាចិត្តរួម និង ជាក់លាក់ក្នុងការដោះស្រាយសកម្មភាព ។ វាជាការសន្ទនាអំពីការចែករំលែកគណនេយ្យភាព ។ តាមរយៈការសន្ទនាបែបនេះ ដៃគូអាចឈានទៅដល់កិច្ចព្រមព្រៀងបង្កើតលទ្ធភាពដែលអាចទៅរួច ដោយបញ្ជាក់ច្បាស់ពីឱកាសអនាគត ហើយអាចមានភាពប្រាកដនិយមក្នុងការអនុវត្តដោយដៃគូ ។

*ការសន្ទនា សំរាប់បង្កើតឱ្យមានឱកាស បានឱ្យមនុស្សឆ្លើយនូវសំណួរដូចខាងក្រោម :*

តើលោកអ្នកអាចប្រកាសបានថា ក្រោយពីបញ្ចប់ការផ្តួចផ្តើមនេះនឹងមានដំណោះស្រាយអ្វីកើតឡើង ?

ខណៈដែលសំណួរនេះ ត្រូវធ្វើការពិភាក្សាយ៉ាងហោចណាស់ក៏១៥នាទីដែរ ដៃគូអាចបន្តទៅបង្កើតសេចក្តីថ្លែងពីការប្តេជ្ញាចិត្តនៃភាពជាដៃគូរួមគ្នា (មិនត្រូវច្រឡំជាមួយនឹងកិច្ចព្រមព្រៀងដៃគូទេ) ។ សេចក្តីថ្លែងគួរតែចាប់ផ្តើមដូចជា :

*យើង/ភាពជាដៃគូរបស់យើង គឺ... ប្តេជ្ញាចំពោះ...*

ស្នើសុំឱ្យដៃគូនីមួយៗសរសេរនូវអ្វីដែលគេគិតថា គួរតែមាននៅក្នុងសេចក្តីថ្លែងនៃការប្តេជ្ញាចិត្ត ។ បន្ទាប់មកឱ្យគេចែកចាយ និង ពិភាក្សាកិច្ចការនេះជាមួយដៃគូផ្សេងៗទៀតពីចំណុចខ្លាំង (មិនមែនចំណុចខ្សោយ) នៃសេចក្តីថ្លែងនីមួយៗ ។ ក្រុមនឹងធ្វើការជ្រើសរើសសេចក្តីថ្លែងដែលគេគិតថាវាល្អបំផុត ហើយក្រុមបន្តកែសំរួលឱ្យកាន់តែប្រសើរ រហូតទាល់តែវាសមល្មមឆ្លុះបញ្ចាំងឱ្យឃើញពីការប្តេជ្ញាចិត្តរបស់ដៃគូទាំងអស់ ហើយគ្រប់គ្នាមានការពេញចិត្ត ។

(នៅមានត...)

## ការសន្ទនា ដែលបង្កើតឱ្យមានសកម្មភាព

ការសន្ទនា ដែលបង្កើតឱ្យមានសកម្មភាព អាចធ្វើគ្រប់ដំណាក់កាលនៃភាពជាដៃគូ នៅពេលណាមានការចូលរួម ឬ តំរូវការសកម្មភាពរបស់ដៃគូនីមួយៗ ។ វាជួយធ្វើឱ្យមានការទទួលខុសត្រូវច្បាស់លាស់ដល់ដៃគូនីមួយៗ ហើយបង្កើនការយល់ដឹងរួមថា តើនរណាមានគណនេយ្យភាពចំពោះអ្វី ។ វាក៏ជួយជំរុញដំណើរការភាពជាដៃគូឱ្យឈានទៅមុខមួយជំហានទៀត ដោយប្រែក្លាយលទ្ធភាព និង ឱកាស ទៅជាសកម្មភាពជាក់លាក់ ។ សំណួរបើកសំខាន់ៗអាចជា : តើអ្នកណាទទួលខុសត្រូវសកម្មភាពណា ហើយនៅពេលណា ?

យើងសូមផ្តល់អនុសាសន៍ឱ្យកត់ត្រាសំណេរ ហើយរក្សាទុករាល់ការប្តេជ្ញារបស់ដៃគូនីមួយៗ ព្រមទាំងថតចំឡងចែកជូនទៅគ្រប់ដៃគូ ។ ធ្វើដូច្នេះ វានឹងជួយឱ្យដៃគូជួយមើលគ្នាទៅវិញទៅមកនៅពេលក្រោយមកទៀត ។

## ការសន្ទនា សំរាប់ការបញ្ចប់

"ការបញ្ចប់" អ្វីមួយមានន័យថា "ធ្វើទាំងអស់" ជាមួយនឹងវា ។ ការបញ្ចប់មិនមែនមានន័យថា ការបញ្ឈប់ដំណើរការជាក់ស្តែងណាមួយទេ តែវាមានសារៈសំខាន់ស្មើគ្នា ដែលថា ដៃគូបានបញ្ចប់លើដំណើរការដែលអនុវត្តជាបន្ត ។ ការនេះជួយជំរុញឱ្យមានការយល់ដឹង និង ការតឹរីមរវាងដៃ-គូ និង ដៃគូ ។ ដូច្នេះ ការសន្ទនាសំរាប់ការបញ្ចប់អាចនឹងធ្វើនៅគ្រប់ដំណាក់កាលនៃដំណើរការភាពជាដៃគូ ។ ជាទូទៅ ដៃគូអាចធ្វើការសួរខ្លួនឯង (និង អ្នកផ្សេងទៀតទៅវិញទៅមក) ដូចសំណួរខាងក្រោម ហើយព្យាយាមធ្វើសកម្មភាពយោងតាមចំលើយដែលបានផ្តល់ឱ្យ :

*តើមានអ្វីដែលនៅសេសសល់ ដើម្បីឱ្យយើងអាចនិយាយបានថា ភាពជាដៃគូរបស់យើងបានជោគជ័យ ឬ ត្រូវបានបញ្ចប់ ?*
*តើសកម្មភាពអ្វីទៀត ដែលយើងត្រូវធ្វើ ដើម្បីសំរេចកិច្ចការនេះ ?*
*តើអ្នកណាទទួលខុសត្រូវសកម្មភាពណា ហើយនៅពេលណា ?*

*តើសេចក្តីសន្យាណា ដែលយើងបានប្តេជ្ញា តែមិនទាន់បានធ្វើ ?*
*តើអ្នកណាទទួលខុសត្រូវសកម្មភាពណា ហើយនៅពេលណា ដើម្បីសំរេចកិច្ចការនេះ ?*

*តើនរណាចង់ ឬ ត្រូវការប្រាប់ជាមុនពីស្ថានភាព ឬ លទ្ធផលនៃភាពជាដៃគូនេះ ?*
*តើយើងត្រូវធ្វើការប្រាស្រ័យទាក់ទងអ្វីខ្លះ ?*

*តើនរណាអាចនឹងទទួលការខឹងសម្បារ រំខានចិត្ត ក្តៅក្រហាយ ឬ ខកចិត្តជាមួយនឹងយើង ឬ ជាមួយនឹងសកម្មភាពរបស់យើង ?*
*តើយើងត្រូវបញ្ចប់បែបណាជាមួយនឹងពួកគេ ?*

*តើនរណាបានចូលរួមចំណែកក្នុងភាពជាដៃគូ និង សកម្មភាពការងារនេះ ?*
*តើយើងត្រូវទទួលស្គាល់គេ និង ការចូលរួមរបស់គេ ដោយរបៀបណា ?*

*តើអ្វីទៀតដែលយើងត្រូវធ្វើបង្ហើយ (ឧ. ទាំងមូល) ជាមួយនឹងការផ្តួចផ្តើមរបស់យើង ?*

# ឧបករណ៍ ៦ ទម្រង់ពិនិត្យឡើងវិញអំពីភាពជាដៃគូ

នេះជាឧបករណ៍ដែលបានរៀបចំឡើងសំរាប់ពិនិត្យឡើងវិញ អំពីភាពជាដៃគូ ដើម្បីធ្វើការប៉ាន់ប្រមាណលើភាពជោគជ័យទៅលើគោលដៅ ឬ ការរំពឹងទុករបស់អង្គភាពជាដៃគូនីមួយៗ ។ វាមានការចាំបាច់ណាស់ក្នុងការ " ឆែកមើលសុខភាព " នៃការងារជាដៃគូ ជាជាងការធ្វើសវនកម្មជាផ្លូវការលើគំរោង ឬ កម្មវិធីរបស់ដៃគូដែលបានធ្វើ ។

| ទិសដៅ | សកម្មភាព ដែលអាចទៅរួច |
|---|---|
| **ផ្តល់ឱកាសឱ្យដៃគូ ធ្វើការឆ្លុះបញ្ចាំងលើគុណតំលៃនៃភាពជាដៃគូពីទស្សនៈនៃអង្គភាពរបស់គេ** | • **១.១ ការសន្ទនា**ជាមួយអ្នកចូលរួមសំខាន់ៗពីអង្គភាពដៃគូនីមួយៗ ឱ្យគេទទួលយក និង តែងតាំងអ្នកធ្វើការពិនិត្យឡើងវិញ ហើយសរសេរបែបព័ណ៌នាសំរាប់ក្រុមជាដៃគូពិភាក្សាបន្ត ។<br>• **សិក្ខាសាលាក្រុមធំ :** ធ្វើដាច់ដោយឡែកក្នុងអង្គភាពដៃគូនីមួយៗ ធ្វើការវិភាគស្ថានភាព (រកចំណុចខ្លាំង ខ្សោយ ឱកាស និង ការគំរាមកំហែងដល់ភាពជាដៃគូ) បន្ទាប់មកយកលទ្ធផលមកផ្គុំជាមួយនឹងអង្គភាពដៃគូផ្សេងទៀត ។<br>• **ជួបគ្នាតែពីរៗនាក់ :** (ពីរៗនាក់មកពីអង្គភាពដៃគូផ្សេងគ្នាជួបគ្នាបែបជាមិត្តភ័ក្រ) ក្នុងគោលបំណងផ្លាស់ប្តូរទស្សនៈ ហើយបន្ទាប់មក ធ្វើការចែកចាយលទ្ធផលជាមួយអង្គភាពដៃគូក្នុងសិក្ខាសាលា ។ |
| **ធ្វើការប៉ាន់ប្រមាណ (ប្រសិនបើមាន) ការផ្លាស់ប្តូរដែលអាចជួយកែលំអប្រសិទ្ធភាពនៃភាពជាដៃគូ** | • **ផ្លាស់ប្តូរការយកចិត្តទុកដាក់ :** អាចរកឃើញតាមរយៈការធ្វើសិក្ខាសាលា "អំពីអនាគត " ឬ ធ្វើលំហាត់ "អំពីសេនារីយ៉ូនៃការធ្វើផែនការ " ដោយអញ្ជើញដៃគូឱ្យមកចូលរួម និង ឱ្យធ្វើការគិតពិចារណាតាមបែបស្រមើស្រមៃ ។<br>• **កំណត់តួនាទី និង ការទទួលខុសត្រូវឡើងវិញ :** អញ្ជើញដៃគូនីមួយៗឱ្យចូលរួមក្នុងការធ្វើការប៉ាន់ប្រមាណលើតួនាទី និង ការទទួលខុសត្រូវឡើងវិញ (សូមមើលឧបករណ៍ ៣) ហើយចាត់តាំងការទទួលខុសត្រូវម្តងទៀតដល់ដៃគូឱ្យដោះស្រាយចំពោះការងារថ្មីៗ តាមរបៀបផ្សេងៗទៀត ។<br>• **បញ្ជ្រាបទៅក្នុងស្ថាបនាស្ថាប័ន :** ឱ្យក្រុមមនុស្សជាច្រើនទៀត នៅក្នុងអង្គភាពដៃគូនីមួយៗ ចូលរួមក្នុងភាពជាដៃគូតាមរបៀបថ្មី ។ |
| **ព្រមព្រៀងគ្នាជាក្រុម ក្នុងការកែសំរួលចំពោះកិច្ចព្រមព្រៀងភាពជាដៃគូ ដើម្បីទទួលខុសត្រូវលើរបកគំហើញពីដំណើរការត្រួតពិនិត្យ** | • **សរសេរកិច្ចព្រមព្រៀងដៃគូសាជាថ្មី** ដើម្បីឆ្លុះបញ្ចាំងពីគោលដៅថ្មី ផ្លាស់ប្តូរការផ្តង់ចិត្ត ឬ សកម្មភាពថ្មី ។<br>• **ពង្រីកភាពជាដៃគូ**-ដាក់បញ្ចូលដៃគូថ្មីៗ ឬ ដោយការផ្សព្វផ្សាយសកម្មភាព និង សមិទ្ធផលរបស់វាជាសាធារណៈ និង គាំទ្រអ្នកផ្សេងដែលបង្កើតការផ្តួចផ្តើមស្រដៀងគ្នា ។<br>• **បង្កើតផែនការបញ្ចប់ ឬ យុទ្ធសាស្ត្របន្ត**-សំរាប់គំរោង ឬ ភាពជាដៃគូ ឬ សំរាប់អង្គការដៃគូមួយ ឬ ច្រើន ។ បន្ត មានន័យថា ការងារមានលទ្ធផលល្អ មិនមែនបកស្រាយថា បរាជ័យទេ ។ ភាពជាដៃគូដែលមានសុខភាព ត្រូវទប់ទល់នឹងការបិទការផ្លាស់ប្តូរ ការចាកចេញក្នុងបែបថ្លៃប្រឌិត និងក្នុងបែបវិជ្ជមាន ។ |

**ចំណាំ**

ក្នុងនាមជាអ្នកពិនិត្យមើលឡើងវិញមកពីខាងក្រៅ ដែលផ្តល់តែគំនិតរបស់ខ្លួន អាចធ្វើឱ្យទំនាក់ទំនងដៃគូងាយនឹងប្រេះស្រាំ ។ ដៃគូអាចដឹងច្បាស់អំពីអ្វីគួរ និង អ្វីមិនគួរ ដោយបញ្ចេញទស្សនៈរបស់គេ ។ នៅពេលដែលគេមានអារម្មណ៍ថាមានសុវត្ថិភាព គេមានភាពស្មោះត្រង់ចំពោះការបង្ហាញទស្សនៈរបស់គេ និង បើកចំហចំពោះអ្វីៗដែលអាចផ្លាស់ប្តូរទៅបាន ។ ដូច្នេះការពិនិត្យភាពជាដៃគូឡើងវិញ គួរតែជាដំណើរការខាងក្នុង ដោយឱ្យអ្នកពិនិត្យមកពីក្រៅ ធ្វើត្រឹមជាអ្នកសំរបសំរួល ជាជាងធ្វើជាអ្នកប៉ាន់ប្រមាណ ។

# កំណត់ត្រា

# ឧបករណ៍ ៧ គំរូករណីសិក្សា

| | |
|---|---|
| **ព័ត៌មាន** | ឈ្មោះអ្នកផ្ដួចផ្ដើម ដៃគូ (លំអិត) អ្នកពាក់ព័ន្ធផ្សេងៗទៀត (លំអិត) កាលបរិច្ឆេទសំខាន់ៗ ទីកន្លែង |
| **ប្រវត្តិ** | តើបញ្ហាអ្វី ដែលនាំឱ្យមានការផ្ដួចផ្ដើមភាពជាដៃគូ ? នរណាចាប់ផ្ដើមវា ? តើគោលការណ៍ និង គុណតំលៃសំខាន់ៗអ្វីខ្លះដែលបានព្រមព្រៀង ? តើវាមានគោលដៅ និង គោលបំណងអ្វី ? តើជំហានដំបូងៗមានអ្វីខ្លះ ? |
| **សកម្មភាព** | តើភាពជាដៃគូបានធ្វើអ្វីខ្លះ ? តើសកម្មភាពទាំងនោះចាត់ចែងរបៀបណា ? តើមកដល់ពេលនេះ បានទទួលលទ្ធផលរយៈពេលខ្លី និង លទ្ធផលរយៈពេលវែងដូចម្ដេចខ្លះ ? តើអ្វីទៀតដែលរំពឹងថានឹងទទួលបាន ? |
| **តួនាទី** | តើអ្នកចូលរួមសំខាន់ៗជានរណា ? ហើយតើគេមានតួនាទីអ្វី ?<br>តើមានការផ្លាស់ប្ដូរយ៉ាងដូចម្ដេចរហូតដល់ពេលនេះ ? |
| **គណនេយ្យភាព** | ក្នុងមធ្យោបាយណា ដែលការផ្ដួចផ្ដើមនេះមានគណនេយ្យភាព ? តើវាមានការប៉ាន់ប្រមាណផលប៉ះពាល់ប្រសិទ្ធភាពដោយរបៀបណា ? តើភាពជាដៃគូ អាចត្រូវបានធ្វើការពិនិត្យឡើងវិញយ៉ាងដូចម្ដេច ?<br>តើដំណើរការសំរេចចិត្តសំខាន់ៗ (រាប់បញ្ចូលទាំងការផ្លាស់ប្ដូរ) មានអ្វីខ្លះ ? |
| **ការប្រឈម** | ក្នុងជីវិតភាពជាដៃគូ តើមានការប្រឈមសំខាន់ៗអ្វីខ្លះ ? តើគេដោះស្រាយវាដោយរបៀបណា ?<br>តើការប្រឈមអ្វីទៀតដែលនៅសេសសល់ ? |
| **ធនធាន** | តើការផ្ដួចផ្ដើមនេះមានធនធានដូចម្ដេចដែរ (ថវិកា និង សំភារៈដែលបានដាក់ចូល) ? តើមានការផ្ដល់ជំនួយពីខាងក្រៅដែរឬទេ ? ប្រសិនបើមាន តើមកពីណា សមាមាត្រទំហំប៉ុណ្ណា ? តើក្នុងវិសាលភាពប៉ុណ្ណាដែលធនធានអាចបន្តជាថ្មី និង ឬក៏ តើគំនិតផ្ដួចផ្ដើមនេះមាននិរន្តរភាពដែរឬទេ ? បច្ចុប្បន្ន ? និងក្នុងពេលណាមួយនាអនាគត ? |
| **អនាគត** | តើផែនការអភិវឌ្ឍក្នុងរយៈពេលខ្លីមានអ្វីខ្លះ ? តើមានផែនការយូរអង្វែង ហើយឬនៅ ?<br>តើដៃគូគេមានយុទ្ធសាស្ត្របន្តហើយឬនៅ ? តើការផ្ដួចផ្ដើមនេះមានកាលកំណត់សំរាប់ធ្វើប្រតិបត្តិការទេ ?<br>តើត្រូវការរយៈពេលប៉ុន្មាន ដើម្បីអនុវត្តយុទ្ធសាស្ត្របន្តទៅមុខទៀត ឬ ក៏ត្រូវប្រើយុទ្ធសាស្ត្រដកថយ ? |
| **ផលសំរេច** | តើអ្វីដែលជាសមិទ្ធផលសំខាន់ៗ ? |
| **ទំនាក់ទំនងលំអិត** | តើអាចទាក់ទងជាមួយនរណា សំរាប់ព័ត៌មានបន្ថែមពេលអនាគត ? និងដោយរបៀបណា ? |

**ចំណាំ**

ក្នុងការសម្ភាសន៍ជាមួយមនុស្សសំខាន់ៗ (ដើម្បីប្រមូលយកព័ត៌មាន) សូមកុំភ្លេច :

- ប្រាប់អ្នកដែលយើងសម្ភាសន៍ថា តើអ្នកជានរណា ហើយហេតុអ្វីអ្នកសួរសំណួរទាំងនេះ
- ប្រើសំណួរបើក ប្រសើរជាងសំណួរបិទ : សំណួរបើកអញ្ជើញគេឱ្យបរិយាយប្រាប់ដល់យើង តែសំណួរបិទគ្រាន់តែអញ្ជើញគេឱ្យឆ្លើយដល់យើងតែ បាទ និង ទេប៉ុណ្ណោះ
- ចូរធ្វើខ្លួនជាអ្នកស្ដាប់យ៉ាងសកម្ម : ប្រុងប្រយ័ត្នស្ដាប់ និង កុំព្យាយាមរកនឹកគិតសួរសំណួរបន្ទាប់ទៀត
- ធ្វើការកត់ត្រានៅពេលដែលមានការសំរាក ដូច្នេះត្រូវសំលឹងមើលមុខអ្នកដែលយើងសំភាសន៍ មិនត្រូវមើលកំណត់ត្រារបស់យើងខណៈពេលដែលគេនិយាយ
- ផ្ដល់ចំឡើយត្រលប់នូវអ្វីដែលលោកអ្នកឮ ដើម្បីធានាថាអ្នកយល់ដឹងត្រឹមត្រូវ ហើយឱ្យគេបន្ថែមនូវអ្វីដែលគេភ្លេច ។

# កំណត់ត្រា

# ឧបករណ៍ ៨

## បញ្ជីសម្រង់ការប្រាស្រ័យទាក់ទង

### អ្នកចូលរួមសំខាន់ៗ

- ដៃគូ ☐
- បុគ្គលិកគំរោង ☐
- បុគ្គលិកផ្សេងៗទៀតក្នុងអង្គភាពដៃគូ ☐
- អ្នកពាក់ព័ន្ធក្នុងគំរោង ☐
- អ្នកទទួលផលពីគំរោង ☐
- ក្រុមសហគមន៍ ☐
- ស្ថាប័នផ្តល់ហិរញ្ញប្បទានក្រៅដៃគូ ☐
- ឥស្សរជនសាធារណៈ ☐
- អ្នកបង្កើតគោលនយោបាយ ☐
- រដ្ឋាភិបាលថ្នាក់ជាតិ ថ្នាក់តំបន់ មូលដ្ឋាន ☐
- ដៃគូថ្មីដែលមានសក្តានុពល ☐
- អង្គការជាតិ ☐
- ស្ថាប័នសិក្សា ☐
- ភ្នាក់ងារអន្តរជាតិ ☐
- ផ្សេងៗ ? ☐

### ជំរើសនានាក្នុងការប្រាស្រ័យទាក់ទង

- ការសន្ទនា ☐
- ការប្រជុំជាសាធារណៈ ☐
- សិក្ខាសាលា ☐
- សកម្មភាពកសាងសមត្ថភាព ☐
- ព្រឹត្តិការណ៍ជាប្រវត្តិសាស្ត្រសំខាន់ៗ ☐
- ទស្សនកិច្ចដល់កន្លែង ☐
- ផ្ទាំងផ្សាយពាណិជ្ជកម្ម ☐
- វិទ្យុ ទូរទស្សន៍ ☐
- វីឌីអូ ឌីវីឌី ☐
- គេហទំព័រ ☐
- ស៊ីឌី ☐
- ករណីសិក្សា ☐
- ព្រឹត្តិប័ត្រព័ត៌មាន ☐
- បោះពុម្ពផ្សាយ ☐
- ផ្សេងៗ ? ☐

### សារ សំខាន់ៗ

- *យើងបានរៀនពីគុណតំលៃកិច្ចសហប្រតិបត្តិការលោកអ្នកគួរសាកល្បងមើល* ☐
- *យើងបានដោះស្រាយបញ្ហាសំខាន់ៗ ហើយវាមានប្រសិទ្ធភាពជាងអភិក្រមដែលធ្លាប់ប្រើកាលពីអតីតកាល* ☐
- *ភស្តុតាងរបស់យើងបង្ហាញថា អន្តរាគមន៍នេះមានផលប៉ះពាល់ជាវិជ្ជមាន និងជាក់ស្តែងដល់អ្នកដែលត្រូវការ* ☐
- *សំណួរទាំងអស់ផ្តោតលើភាពជាអ្នកដឹកនាំ និង ការប្តេជ្ញាធ្វើការជាមួយគ្នាដើម្បីផ្លាស់ប្តូរ* ☐
- *អភិក្រមនេះមានប្រសិទ្ធភាព និង និរន្តរភាព* ☐
- *នេះជាដំណោះស្រាយមូលដ្ឋានសំរាប់ការប្រឈមនៅមូលដ្ឋាន* ☐
- *ទម្រង់នៃកិច្ចសហប្រតិបត្តិការនេះ ជំរុញឱ្យមានការចូលរួមកាន់តែខ្លាំង ហើយផ្តល់អំណាចដល់អ្នកដែលយើងស្វែងរកជំនួយ* ☐
- ផ្សេងៗ ? ☐

**ចំណាំ**

វាមានហេតុផលចាំបាច់មួយចំនួនសំរាប់ការផ្សព្វផ្សាយភាពជាដៃគូ ឬ សកម្មភាពរបស់វា ហើយហេតុផលទាំងនេះត្រូវការការត្រិះរិះពិចារណា តែការដែលឆាប់នឹងធ្វើការផ្សព្វផ្សាយពេក នោះអាចជាសម្ពាធយ៉ាងធ្ងន់ទៅលើភាពជាដៃគូ ហើយអាចកើតមានផលប៉ះពាល់ជាអវិជ្ជមានដែលនឹកស្មានមិនដល់ខ្លះៗ ។ ដៃគូត្រូវធ្វើការប៉ាន់ប្រមាណហានិភ័យ និង ផលប្រយោជន៍នៃការបោះពុម្ពផ្សព្វផ្សាយការងាររបស់គេ ហើយធានាថាគ្រប់ដៃគូទាំងអស់យល់ស្របគ្នា និង ប្រកាន់ខ្ជាប់ជាមួយនឹងយុទ្ធសាស្ត្រដែលបានព្រមព្រៀងគ្នា ។

# កំណត់ត្រា

# ឯកសារយោង

សៀវភៅជំនួយស្មារតីការកសាងភាពជាដៃគូរៀបរៀងចេញពីឯកសារ ដែលបានបោះពុម្ពផ្សាយមុនៗ ចំនួន ៣ គឺ :

• ការគ្រប់គ្រងភាពជាដៃគូ : ឧបករណ៍សំរាប់ចងក្រងរដ្ឋាភិបាល ផ្នែកឯកជន និង ផ្នែកសង្គមស៊ីវិល ធ្វើជាដៃគូអភិវឌ្ឍ រៀបរៀងដោយលោកស្រី រ៉ូស ថេនីសុន និង
បោះពុម្ពដោយ : វេទិកាអ្នកដឹកនាំធុរកិច្ច រាជាធិរាជក្រុងវេល ឆ្នាំ ១៩៩៨

• ហត្ថាជំនួយ : អន្តរការីនៃភាពជាដៃគូសំរាប់ការអភិវឌ្ឍប្រកបដោយនិរន្តរភាព
រៀបរៀងដោយ : លោកស្រី រ៉ូស ថេនីសុន និង លូកា វ៉ាល
បោះពុម្ពដោយ : ការិយាល័យព័ត៌មានសាធារណៈអង្គការសហប្រជាជាតិ ឆ្នាំ ២០០០

• ស្ថាប័នភាពជាដៃគូ : មេរៀនពីខ្សែត្រៀមជួរមុខ រៀបរៀងដោយលោកស្រី រ៉ូស ថេនីសុន
បោះពុម្ពដោយ : វេទិកាអ្នកដឹកនាំធុរកិច្ចអន្តរជាតិ ឆ្នាំ ២០០៣

ឯកសារជំនួយផ្សេងៗទៀត :

• មធ្យោបាយធ្វើខ្លួនឱ្យមានសេរីភាព រៀបរៀងដោយ បេន អ៊ុករី
បោះពុម្ពដោយ : ហ្វូនិក

• ប្រវត្តិសង្ខេបនៃអ្វីៗទាំងអស់ : រៀបរៀងដោយលោក គិន វីលប័រ
បោះពុម្ពដោយ : រោងពុម្ព សាំហាឡា

# សេចក្តីថ្លែងអំណរគុណ


ការបោះពុម្ពផ្សាយលើកទី ១ នៃសៀវភៅជំនួយស្មារតីការកសាងភាពជាដៃគូបានទទួលសិទ្ធិ និង ជំនួយឧបត្ថម្ភពីបណ្តាញសកលដើម្បីបង្កើនជីវជាតិចំណីអាហារ (GAIN) ។ GAIN ក៏បានផ្តល់ជំនួយក្នុងការបកប្រែសៀវភៅជាច្រើន ដែលអាចទាញយកពីគេហទំព័រ : www.thepartneringinitiative.org

ឯកសារនេះ បានរៀបរៀងចេញពីបទពិសោធន៍នៃអ្នកអនុវត្តផ្ទាល់ ដែលមកពីជុំវិញពិភពលោក ក៏ប៉ុន្តែសូមថ្លែងអំណរគុណជាពិសេសចំពោះលោក ម៉ៃខើល យ៉ាកុប ដែលបានជួយសរសេរប្រអប់ ៧ : ការនិយាយរឿង ។ អរគុណចំពោះលោក អាឡាំង ហ្គូទីយឺ ដែលបានជួយចងក្រងឧបករណ៍ទី ២ និង ចំពោះលោកស្រី បាបារា ទូក្លើរ សំរាប់ការចំណាយពេលជួយកែសំរួលអត្ថបទទាំងស្រុង និង ព្រមទាំងបានចូលរួមជាមួយ អង្គការ UNDP ជួយផ្តល់គំនិតក្នុងជំពូក ៤ និង ឧបករណ៍ទី ៥ ។

អ្នកនិពន្ធក៏សូមអរគុណដោយកតញ្ញូបំផុតចំពោះការឱ្យយោបល់ត្រឡប់ ដែលមិនអាចកាត់ថ្លៃបានពីលោក បណ្ឌិត សឹកគិរីមែន និង ក្រុមការងាររបស់គាត់លោក គូលីស៊ី ហ្វទីហ្វីកាស៊ី (ឥណ្ឌូនេស៊ី) និង ពីបណ្ឌិត ជូអាន រីវឺរា ដូម៉ាកូ នាយក Ejecutivo del CINyS and Guadalupe Rodriguez (ម៉ិកស៊ីកូ) ក៏ដូចជាសមាជិកក្រុមប្រឹក្សាភិបាល (GAIN) និង ដៃគូដែលបានឆ្លើយតបក្នុងការព្រាងបោះពុម្ពលើកដំបូង ។

គំរោងនេះបានទទួលការគាំទ្រលើកទឹកចិត្តពី (មនុស្ស ៦០ នាក់ មកពី ១៥ ប្រទេស) អ្នកដែលបានមកចូលរួម សិក្ខាសាលា GAIN នៅក្រុងជេនីវ៉ា ខែកញ្ញា ឆ្នាំ ២០០៣ ។ ជាមួយការលើកទឹកចិត្តនេះ បានជម្រុញឱ្យមានការ បោះពុម្ពសៀវភៅជំនួយស្មារតីការកសាងភាពដៃគូនេះជាភាសាផ្សេងៗជាច្រើន ដែលមានក្នុងទម្រង់អេឡិចត្រូនិច ។


យើងប្រាថ្នាចង់ឱ្យសៀវភៅនេះបានទៅដល់ដៃ (ដោយផ្ទាល់ ឬ ដោយការនឹកគិត) អ្នកដែលអនុវត្តភាពជាដៃគូទាំងអស់ តាមរយៈការប្រើបណ្តាញ និង ប្រព័ន្ធចែកចាយរបស់អង្គភាពជាដៃគូទាំងអស់

ផលិតដោយ ៖

## កម្មវិធីផ្តួចផ្តើមភាពជាដៃគូ

កម្មវិធីផ្តួចផ្តើមភាពជាដៃគូ ជាកម្មវិធីសកលរបស់វេទិកាអ្នកដឹកនាំធុរកិច្ចអន្តរជាតិ (IBLF) ។ ពេលកើតដំបូង កម្មវិធីធ្វើការជាមួយគ្រប់វិស័យទាំងអស់ ចាប់តាំងពីកំរិតយុទ្ធសាស្ត្រ កំរិតប្រតិបត្តិការ និង កំរិតបុគ្គលម្នាក់ៗផ្ទាល់ ដើម្បីលើកកំពស់ និង គាំទ្រភាពជាដៃគូអន្តរវិស័យដែលសមស្របមានប្រសិទ្ធភាព និង នវានុវត្តន៍ ហើយនឹងបានធ្វើជាមជ្ឈមណ្ឌលសកលសំរាប់ការផ្លាស់ប្តូរចំណេះដឹងអំពីការកសាងភាពជាដៃគូ ។

សំរាប់ព័ត៌មានបន្ថែម ៖ www.ThePartneringInitiative.org

ចូលរួមសហការជាមួយ ៖

## វេទិកាអ្នកដឹកនាំធុរកិច្ចអន្តរជាតិ (IBLF)

IBLF ធ្វើការជាមួយផ្នែកឯកជន រដ្ឋាភិបាល និង ផ្នែកសង្គមស៊ីវិល ដើម្បីលើកកំពស់ការចូលរួមចំណែករបស់ក្រុមហ៊ុននៅក្នុងការអភិវឌ្ឍប្រកបដោយនិរន្តរភាព ។ ជាអង្គការឯករាជ្យមិនរកប្រាក់ចំណេញ ។ បច្ចុប្បន្នមានការគាំទ្រពីក្រុមហ៊ុនធំៗ និង នាំមុខគេក្នុងពិភពលោក ចំនួនជាង ១០០ ក្រុមហ៊ុន ។ តាំងពីបានបង្កើតឡើងក្នុងឆ្នាំ ១៩៩០ IBLF បានបង្កើតកេរ្តិ៍ឈ្មោះល្បីជាអន្តរជាតិ ក្នុងការនាំមុខគេលើការងារកសាងភាពជាដៃគូអន្តរវិស័យ ។

សំរាប់ព័ត៌មានបន្ថែម ៖ www.iblf.org

## កម្មវិធីអភិវឌ្ឍសហប្រជាជាតិ (UNDP)

UNDP ជាបណ្តាញអង្គការអភិវឌ្ឍសហប្រជាជាតិ ជាអង្គការដែលជួយឧបត្ថម្ភសំរាប់កាផ្លាស់ប្តូរ និង ភ្ជាប់ប្រទេសនានាទៅនឹងចំណេះដឹង បទពិសោធន៍ និង ធនធាន ដើម្បីជួយឱ្យមនុស្សកសាងជីវិតបានកាន់តែប្រសើរឡើង ។ អង្គការនេះធ្វើសកម្មភាពក្នុង ១៦៦ ប្រទេស ធ្វើការជាមួយគេដើម្បីឱ្យគេរកដំណោះស្រាយដោយខ្លួនឯង ភ្ជាប់ជាមួយដំណោះស្រាយជាសកល និង លើការប្រឈមចំពោះកិច្ចការអភិវឌ្ឍថ្នាក់ជាតិ ។ មេដឹកនាំពិភពលោកបានធ្វើសច្ចាប្រណិធានថានឹងសំរេចឱ្យបាននូវគោលដៅអភិវឌ្ឍសហស្សវត្សរ៍ ដោយរាប់បញ្ចូលទាំងគោលដៅកំពូលនៃការកាត់បន្ថយភាពក្រីក្រឱ្យបានពាក់កណ្តាលក្នុងឆ្នាំ ២០១៥ ។ បណ្តាញអង្គការ UNDP ធ្វើការតភ្ជាប់ និង សំរបសំរួលកិច្ចខិតខំប្រឹងប្រែងជាសកល និង ថ្នាក់ជាតិ ដើម្បីឱ្យសំរេចនូវគោលដៅនេះ ។

សំរាប់ព័ត៌មានបន្ថែម ៖ www.undp.org

## វិទ្យាស្ថានបំរើអ្នកសំរបសំរួលការងារអភិវឌ្ឍន៍ (VBNK)

VBNK ជាអង្គការរៀនសូត្រកម្ពុជាដែលនាំមុខគេក្នុងការអភិវឌ្ឍសមត្ថភាព ។ VBNK ផ្តល់ការបណ្តុះបណ្តាល និង ប្រឹក្សាយោបល់ ដើម្បីឆ្លើយតបចំពោះតំរូវការអភិវឌ្ឍន៍សមត្ថភាពទាំងបុគ្គល និង អង្គភាព ។ VBNK នៅតែមានលក្ខណៈពិសេសជាងគេក្នុងចំណោមអ្នកផ្តល់សេវាកម្មទាំងអស់ ចំពោះសេវាកម្មជាច្រើន និង ចំពោះវិធីសាស្ត្របែបនវានុវត្តន៍ដែលឆ្លើយតបចំពោះការប្រឈមនៃការកសាងសមត្ថភាពនៅក្នុងវិស័យអភិវឌ្ឍន៍សង្គមនៅកម្ពុជា ។

សំរាប់ព័ត៌មានបន្ថែម ៖ www.vbnk.org